# ទស្សនាវដ្តីកសិកម្ម

# THE AGRICULTURE MAGAZINE



ឆ្នាំទី ១៦ ត្រីមាសទី ៣ (កក្កដា-កញ្ញា) ឆ្នាំ ២០១៧ លេខ ៦៣

អាសយដ្ឋានលេខ:២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (០២៣) ២១១ ៣៥១/ទូរសារលេខ : (៨៥៥)២៣ ២១៧ ៣២០
គេហទំព័រ : http://www.maff.gov.kh
e-mail : info@maff.gov.kh





# ការផ្សាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

# មាតិកា ទំព័រ


- លិខិតថ្លែងអំណរគុណ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ផ្ញើជូនឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ ២០១៧..........០១
- របាយការណ៍ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធី "រុក្ខទិវា" នៅភូមិក្រាំងក្រូច ឃុំទួលព្រេច ស្រុកអង្គស្នួល ខេត្តកណ្តាល..........០២
- របាយការណ៍ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឱកាសប្រារព្ធ " ទិវាមច្ឆជាតិ "នៅអាងទឹកទំនប់ពហុបំណងបាត់ដំបង ទំនប់សេកសក ភូមិទឹកសាប ឃុំផ្លូវមាស ស្រុករតនមណ្ឌល ខេត្តបាត់ដំបង..........០៦
- ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីសំណេះសំណាលជាមួយនិស្សិតកម្មសិក្សានៅប្រទេសអ៊ីស្រាអែល ជំនាន់ទី១០ ឆ្នាំសិក្សា ២០១៧ - ២០១៨ នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម..........១១
- ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីបើក សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាង ផែនការយុទ្ធសាស្ត្ររយៈពេល១០ឆ្នាំ របស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម ២០១៧-២០២៦ នៅទន្លេបាសាក់២..........១៦
- ដំណាំមន (MULBERRY) (បន្តពីទស្សនាវដ្តីកសិកម្មលេខ ៦២)..........២១
- ការចិញ្ចឹមដង្កូវនាង (បន្តពីទស្សនាវដ្តីកសិកម្មលេខ ៦២)..........២៧
- រុក្ខជាតិឱសថកកោះ..........៣៧
- រុក្ខជាតិឱសថកញ្ឆាន់អាចមិជ្រូក..........៣៨
- ផែនការសកម្មភាពអភិរក្សខ្លាធំ នៅកម្ពុជា..........៣៩
- របាយការស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំនព្វមាស ឆ្នាំ២០១៧ និងទិសដៅអនុវត្តបន្ត..........៤៦
- សកម្មភាពថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ..........៦១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ម.ព.ឯ.ក AIDOC
Code: 062-004
Date:
Donated by:

រដ្ឋសភា

**<u>ផ្ញើជូន</u>**

**ឯកឧត្តម វេង សាខុន**

**រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

*<u>ជាទីស្រឡាញ់រាប់អាន។</u>*

ខ្ញុំបានទទួលរួចហើយនូវលិខិតលេខ ៥៣៩០ កសក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានផ្ដល់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្ររង ចំនួន ៥០កន្លែង នៅសាលាជាតិកសិកម្មព្រែកលៀប សម្រាប់ឆ្នាំសិក្សា ២០១៧-២០១៨ ដល់ខ្ញុំ ដើម្បីផ្ដល់ជូនកូនចៅប្រជាពលរដ្ឋក្រីក្រ គ្មានលទ្ធភាពបង់ថ្លៃបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរចំពោះទឹកចិត្តសប្បុរសធម៌របស់ឯកឧត្តម ដែលបានផ្ដល់អាហារូបករណ៍ សម្រាប់ការអភិវឌ្ឍធនធានមនុស្ស ឲ្យមានចំណេះដឹងប្រកបដោយគុណភាព ដើម្បីបន្តចូលរួមកសាង និងអភិវឌ្ឍប្រទេសជាតិ ស្របតាមគោលនយោបាយដ៏ឧត្តុង្គឧត្តមរបស់រាជរដ្ឋាភិបាល ។

ខ្ញុំសូមជូនពរ ឯកឧត្តមរដ្ឋមន្ត្រី ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការទាំងអស់ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រកបបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

រាជធានីភ្នំពេញ. ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១៧

**ប្រធានរដ្ឋសភា**

**សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន**

វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូរសារ: (៨៥៥-២៣) ២២០ ៦២៩ សារអេឡិចត្រូនិច: sg@national-assembly.org.kh គេហទំព័រ: www.national-assembly.org.kh

# របាយការណ៍
# ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធី "រុក្ខទិវា" នៅភូមិក្រាំងក្រូច ឃុំទួលព្រេច ស្រុកអង្គស្នួល ខេត្តកណ្តាល
## ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៧

- សូមក្រាបថ្វាយបង្គំព្រះតេជព្រះគុណ ព្រះមេគណ ព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ
- សូមក្រាបថ្វាយបង្គំ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

**សូមគោរព** :

- សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់
- សម្តេចអគ្គមហាពញាចក្រី កិត្តិព្រឹទ្ធបណ្ឌិត ហេង សំរិន ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរព ដ៏ខ្ពង់ខ្ពស់
- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់
- សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ តំណាងស្ថាប័ននីតិប្បញ្ញត្តិ សម្តេច ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា រាជរដ្ឋាភិបាល ជាទីគោរព
- ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ ក្មួយៗសិស្សានុសិស្ស និងបងប្អូនជនរួម ជាតិទាំងអស់ជាទីមេត្រី



ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងពិធី "រុក្ខទិវា" នៅភូមិក្រាំងក្រូច ឃុំទួលព្រេច ស្រុកអង្គស្នួល ខេត្តកណ្តាល

ជាបឋម ខ្ញុំព្រះករុណាខ្ញុំ តាងនាមឱ្យថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរថ្នាក់ក្រោមជាតិ និងបងប្អូនជនរួមជាតិទាំងអស់ដែលមានវត្តមាននៅទីនេះ មានមហាកិត្តិយសដ៏ ឧត្តុង្គឧត្តម និងមានសេចក្តីរំភើបសោមនស្សរីករាយជាអនេកប្បការ សូមសម្តែងនូវអភិវន្ទនាការ ចំពោះព្រះរាជវត្តមានដ៏ ថ្លៃថ្លាបំផុតរបស់ ព្រះករុណាព្រះបាទ **សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតដែលព្រះអង្គសព្វព្រះរាជហឬទ័យយាងជាព្រះរាជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធី "រុក្ខទិវា" នៅភូមិក្រាំងក្រូច ឃុំទួលព្រេច ស្រុកអង្គស្នួល ខេត្តកណ្តាល ដ៏មហានក្ខត្តឫក្សនេះ។ ទន្ទឹមនេះ ខ្ញុំព្រះករុណាខ្ញុំ សូម សម្តែងនូវបដិសណ្ឋារកិច្ចដ៏កក់ក្តៅ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានសម្តេច ទ្រង់ ឯកឧត្តម លោក ជំទាវ សមាជិក សមាជិកានៃព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ និងបងប្អូនជនរួមជាតិទាំងអស់ ដែលបានអញ្ជើញមកចូលរួមនៅក្នុងពិធី ដ៏វិសេសវិសាលនេះ។

ឆ្លៀតក្នុងឱកាសដ៏មហាប្រសើរថ្ងៃថ្លានេះ ខ្ញុំព្រះករុណាខ្ញុំ សូមពិតពុទ្ធដីកា ទូលថ្វាយ និងជម្រាបជូនថា រហូតមក ដល់ឆ្នាំ ២០១៦ ពិធីរុក្ខទិវាត្រូវបានរៀបចំឡើងចំនួន ២៦លើករួចមកហើយ លើផ្ទៃដីសរុបជាង ៤៥២ហិកតា។ សម្រាប់ ឆ្នាំ ២០១៧នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានកិច្ចសហការជាមួយក្រសួងព្រះបរមរាជវាំង អាជ្ញាធរខេត្តកណ្តាល បានកំណត់យកទីតាំងស្ថិតនៅភូមិក្រាំងក្រូច



ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា យាងក្នុងពិធីបុណ្យរុក្ខទិវា ស្ថិតនៅភូមិក្រាំងគ្រូច ឃុំទួលព្រេច ស្រុកអង្គស្នួល ខេត្តកណ្តាល

ឃុំទួលព្រេច ស្រុកអង្គស្នួល ខេត្តកណ្តាលនេះ ដើម្បីប្រារព្ធពិធីរុក្ខទិវាលើកទី២៧ នៅលើផ្ទៃដីទំហំ ១០ហិកតា ក្នុងគោលបំណងបំផុសស្មារតីចូលរួមស្តារ និងដាំឈើឡើងវិញ ធ្វើ ឱ្យប្រសើរឡើងនូវសោភ័ណភាពទេសភាពធម្មជាតិ បរិស្ថាន រក្សានិយតភាពប្រភពទឹក និងចូលរួមកាត់បន្ថយការឡើងកម្តៅនៅភពផែនដី និងការប្រែប្រួលអាកាសធាតុ។ ចំណែកកូនឈើ ដែលត្រូវយកមកដាំនៅក្នុងពិធីនេះ រួមមានប្រភេទឈើក្រញូង ធ្នង់ និងគីនីន សរុបចំនួន ៨ ៨៣០ដើម។ ខ្ញុំព្រះករុណាខ្ញុំ សូមពិតពុទ្ធដីកា ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ទូលថ្វាយ និងជម្រាបជូនអង្គពិធីទាំងមូលមេត្តា ជ្រាបអំពីប្រវត្តិនៃទីតាំងប្រារព្ធពិធីរុក្ខទិវាថ្ងៃនេះ ដូចតទៅ៖ ទីតាំងនេះ កាលដើមឡើយ នៅជំនាន់អាណានិគមបារាំង បានយកដីទំហំ ៤០០ហិកតា ធ្វើជាចម្ការពិសោធន៍ដាំកូនកៅស៊ូ។ ក្នុងផ្ទៃដីទំហំ ៤០០ហិកតានេះ ដាំបានតែ ៣០ហិកតា ប៉ុណ្ណោះ ពីព្រោះដីនៅទីនេះកូនកៅស៊ូដុះលូតលាស់យឺតនិងត្រូវទឹកលិចនៅរដូវវស្សា ពុំសមស្របទៅនឹងដំណាំកៅស៊ូ។ ក្រោយឆ្នាំ១៩៥៣ បារាំងបានប្រគល់ចម្ការនេះ មកឱ្យរដ្ឋគ្រប់គ្រងវិញ ពេលនោះប្រជាពលរដ្ឋរស់នៅតំបន់នេះ បានហៅ ចម្ការនេះថា ចម្ការបារាំងតៗគ្នារៀងរហូតមក។ ចម្ការបារាំងស្ថិតនៅក្នុងទឹកដីឃុំទួលព្រេច ស្រុកអង្គស្នួល ខេត្តកណ្តាល ហើយសព្វថ្ងៃនេះហៅថា ចម្ការដាំឈើទួលព្រេច តែប្រជាពលរដ្ឋស្គាល់តែចម្ការបារាំងទេ។ បន្ទាប់មក រដ្ឋបានដាំដើមឈើឡើងវិញ ដោយយកកូនឈើប្រភេទគ្រើល ត្បែង ត្រសេក ស្វាយព្រៃ ពពេល ធ្នង់ មកដាំចម្រុះជាមួយព្រៃធម្មជាតិ ហើយប៉ុន្មានឆ្នាំក្រោយមក តំបន់នេះក្លាយជាព្រៃដុះខៀវស្រងាត់ ធ្វើឱ្យសត្វព្រៃមួយចំនួនដូចជា ឈ្លូស ជ្រូកព្រៃ ចចក ស្វាន... ។ល។ និងសត្វស្លាបជាច្រើនប្រភេទ ចូលមករស់នៅតំបន់នេះ។ ក្រោយឆ្នាំ១៩៦០ មានគ្រួសារមួយជាកម្មករអណ្តែតយាមព្រៃនៅចម្ការបារាំងនេះ ហើយក្នុងពេលនោះដែរ រដ្ឋបានចាត់តាំងឱ្យលោកម៉េច(ឬហៅថីម៉េច) ជាអ្នកទទួលខុសត្រូវមើលថែទាំចំការ បារាំងនេះ ពេលនោះ ពុំមានប្រជាពលរដ្ឋណាហ៊ានចូលមកកាប់ឈើ និង បរបាញ់សត្វព្រៃឡើយ។ ចាប់ពី ឆ្នាំ១៩៧០ ដល់១៩៧៥ ចម្ការបារាំងបានក្លាយជាជុំរំលាក់ខ្លួនរបស់ខ្មែរក្រហម ហើយមានយន្តហោះអាមេរិកបានមក ទម្លាក់គ្រាប់បែកបណ្តាលឱ្យភ្លើងឆេះខូចខាតព្រៃអស់ជាច្រើនហិកតា។ ក្រោយឆ្នាំ១៩៧៥ របបប៉ុល ពត បានរៀបចំភូមិ នៅតាមបណ្តោយផ្លូវជាតិ ជាប់ព្រំប្រទល់ចម្ការដាំឈើ ហើយបានកាប់ឈើក្នុងចម្ការ ដើម្បីសាងសង់លំនៅដ្ឋាន។ ក្រោយ ឆ្នាំ១៩៧៩ ក៏នៅមានការកាប់ឈើ ក្នុងចំការបារាំង ដើម្បីគាស់រានដី ធ្វើស្រែចម្ការ ដោយពុំមាន ការបែងចែកពីរដ្ឋអំណាច ណាឡើយ។ រហូតមកដល់ឆ្នាំ១៩៨៣ ចំការឈើបានក្លាយជាវាលស្មៅល្វឹងល្វើយ សូម្បីតែគល់ក៏គាស់អស់គ្មានសល់។ ស្ថិតក្នុងស្ថានភាពបែបនេះ នៅឆ្នាំ១៩៨៥ រដ្ឋបានបង្កើតជាស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើ ទួលព្រេច នៅលើផ្ទៃដី ទំហំ ៣៥៨ហិកតា ដោយបានធ្វើការដាំឈើឡើងវិញ មានជាអាទិ៍ ប្រភេទអាកាស្យា ប្រេងខ្យល់ និង អង្កាញ់ ដើម្បីស្តារ ព្រៃឈើឡើងវិញនៅក្នុងតំបន់នេះ។

- ព្រះតេជព្រះគុណ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ
- ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត
- អង្គពិធីទាំងមូល ជាទីមេត្រី

ខ្ញុំព្រះករុណាខ្ញុំ សូមពិតពុទ្ធដីកាទូលថ្វាយ និងជម្រាបជូនថា នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ និងម៉ឺង ម៉ាត់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បាននិង កំពុងបន្តធ្វើកំណែទម្រង់វិស័យព្រៃឈើ ដោយផ្តោតលើការគ្រប់គ្រង និងអភិរក្សធនធានព្រៃឈើ ដើម្បីធានាចីរភាពនៃ កំណើនសេដ្ឋកិច្ចជាតិ



ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា យាងទតពិព័រណ៍ផលិតផលកសិកម្ម ក្នុងពិធីបុណ្យរុក្ខទិវា ស្ថិតនៅភូមិក្រាំងគ្រូច ឃុំទួលព្រេច ស្រុកអង្គស្នួល ខេត្តកណ្តាល

និងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជននៅជនបទ តាមរយៈការបង្កើតនិងពង្រឹងសហគមន៍ ព្រៃឈើ ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងទប់ស្កាត់បទល្មើស ព្រៃឈើ និងពង្រឹងប្រសិទ្ធភាពគ្រប់គ្រងព្រៃបម្រុងទុក។

ឆ្លើយតបទៅនឹងគោលនយោបាយខាងលើ រាជរដ្ឋាភិបាលបានកំណត់ស្ថាប័នអភិរក្សព្រៃឈើមានក្រសួងបរិស្ថាន និងស្ថាប័នអភិវឌ្ឍន៍មានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយសម្រេចផ្ទេរតំបន់ព្រៃការពារនិងអភិរក្សព្រៃឈើចំនួន ១៣កន្លែង និងតំបន់ព្រៃផ្តល់ផលចំនួន ៥កន្លែង ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជូនក្រសួងបរិស្ថានគ្រប់គ្រង និងបានផ្ទេរតំបន់សម្បទានដីសេដ្ឋកិច្ចចំនួន៧៣កន្លែង ពីក្រសួងបរិស្ថាន ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគ្រប់គ្រងបន្ត តាមរយៈអនុក្រឹត្យលេខ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦។ នៅក្នុងឆ្នាំ២០១៦ កន្លងមកនេះ រដ្ឋបាលព្រៃឈើដែលជាអង្គភាពជំនាញរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានយកចិត្តទុក ដាក់អនុវត្តលើសកម្មភាពជាច្រើន ដោយសម្រេចបាននូវសមិទ្ធផលគួរឱ្យកត់សំគាល់ រួមមាន ការបោះបង្គោលព្រំប្រទល់ ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍បានចំនួន ៥៧៤បង្គោល មានប្រវែង ៨៤គីឡូម៉ែត្រ បានដាំដើមឈើជាចំការលើផ្ទៃដីសរុប ទំហំ ៩២៥ហិកតា ក្នុងនោះ រដ្ឋបាលព្រៃឈើដាំបាន ៣៥០ហិកតា និងក្រុមហ៊ុនដាំឈើដៃគូដាំបាន ៥៧៥ហិកតា។ ទន្ទឹមនេះ បានបណ្តុះកូនឈើចម្រុះប្រភេទនិងចែកជូនប្រជាពលរដ្ឋដាំបានចំនួនជាង ១,៥លានដើម ចុះកិច្ចព្រមព្រៀង ព្រៃសហគមន៍បាន៩កន្លែង លើផ្ទៃដីសរុប ២ ៥៨៨ហិកតា និងបានអនុម័តផែនការគ្រប់គ្រងព្រៃសហគមន៍ ២៣កន្លែង លើផ្ទៃដីសរុប ១២ ០០៤ហិកតា។ រីឯការផ្គត់ផ្គង់ឈើមូល ឈើអារគ្រប់ប្រភេទ កូនឈើ និងអុសសម្រាប់ប្រើប្រាស់នៅ ក្នុងស្រុក គឺបានមកពីការឈូសឆាយសម្អាតដីក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច និងអាងស្តុកទឹកនៃ គម្រោងវារីអគ្គិសនី។

ក្រៅពីការងារខាងលើ សមត្ថកិច្ចជំនាញរដ្ឋបាលព្រៃឈើបានសហការជាមួយកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រះរាជអាជ្ញាអមសាលាដំបូង និងអាជ្ញាធរខេត្ត ចុះបង្ក្រាបបទល្មើសព្រៃឈើគ្រប់ប្រភេទនៅទូទាំងប្រទេស បានចំនួន ១ ៤៩០ករណី ចាប់ឃាត់និងរឹបអូសឈើគ្រប់ប្រភេទសរុបចំនួន ១៣ ៤៨៣ម³ និងបានដាក់ដេញថ្លៃជាសាធារណៈ តាម នីតិវិធី។ ដីព្រៃឈើបានរំលោភបំពានដោយខុសច្បាប់មានចំនួន ២០៨ករណី លើផ្ទៃដីសរុបទំហំ ៥ ២១៣ហិកតា ត្រូវ បានបញ្ជូនទៅតុលាការ និងដកហូតរណារយន្តបានចំនួន ២៩៥គ្រឿង។ ក្រៅពីនេះ រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននឹងកំពុងអនុវត្តគម្រោងសហប្រតិបត្តិការក្រោមជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសពីដៃគូ អភិវឌ្ឍន៍នានា រួមមាន គម្រោងសិក្សាស្រាវជ្រាវបម្រែបម្រួលវដ្តទឹកក្នុងតំបន់អាងទន្លេមេគង្គ គម្រោងច្រករបៀងអភិរក្ស ជីវៈចម្រុះមហាអនុតំបន់មេគង្គ គម្រោងជំរុញការងារស្តារព្រៃឈើនៅកម្ពុជា-វៀតណាម តាមរយៈការបង្កើតឡូតិ៍បង្ហាញ និងការធ្វើឱ្យប្រសើរឡើងប្រព័ន្ធចែកចាយគ្រាប់ពូជឈើ គម្រោងរៀបចំផែនការគ្រប់គ្រងព្រៃឈើក្នុងតំបន់ទីជម្រាលស្ទឹង ព្រែកត្នោត គម្រោងបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវសេនេទិចព្រៃឈើដើម្បីស្តារប្រភេទឈើសំខាន់ៗនៅកម្ពុជា គម្រោង ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពតាមរយៈយន្តការរេដបូកនៅខេត្តកំពង់ធំ គម្រោងសមភាគីដោះលែងសត្វ ព្រៃនៅខេត្តកោះកុង និងសៀមរាប គម្រោងសមភាគីអភិរក្សព្រៃឈើនិងសត្វព្រៃនៅខេត្តមណ្ឌលគិរី ព្រះវិហារ កោះកុង និងខេត្តកំពង់ស្ពឺ...។ល។ បន្ថែមពីនេះទៀត ការបង្ក្រាបបទល្មើសព្រៃឈើ មានសកម្មភាពមុតស្រួច ពិសេសការចូលរួម សហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការជាតិដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើដែលដឹកនាំដោយឯកឧត្តម សៅ សុខា។



ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា យាងដាំកូនឈើជានិម្មិតរូប ក្នុងពិធីបុណ្យរុក្ខទិវា ស្ថិតនៅភូមិក្រាំងក្រូច ឃុំទួលព្រេច ស្រុកអង្គស្នួល ខេត្តកណ្ដាល

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរគុណ និងសូមអំពាវនាវដល់អាជ្ញាធរថ្នាក់ក្រោមជាតិ និងគ្រប់ដៃគូពាក់ព័ន្ធទាំងអស់យកចិត្តទុកដាក់បន្ថែមទៀត អនុវត្តរាល់លិខិតបទដ្ឋានគតិយុត្តទាំងឡាយជាធរមាន ចូល រួមទប់ស្កាត់បទល្មើសព្រៃឈើ-សត្វព្រៃ និងការកាប់រាន ដុត ឈូសឆាយហ៊ុមព័ទ្ធដីព្រៃឈើដើម្បីរំាតយកដីធ្វើជាកម្មសិទ្ធិ ដោយខុសច្បាប់ និងចូលរួមដាំដើមឈើឡើងវិញ នៅក្នុងបរិបទនៃការចូលរួមកាត់បន្ថយការឡើងកម្ដៅនៅភពផែនដី និងបម្រែបម្រួលអាកាសធាតុ។

- ព្រះតេជព្រះគុណ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ
- ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត
- អង្គពិធីទាំងមូល ជាទីមេត្រី

ជាថ្មីម្ដងទៀត ក្នុងនាមខ្ញុំព្រះករុណាខ្ញុំផ្ទាល់ និងតាងនាមឲ្យថ្នាក់ដឹកនាំមន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ព្រមទាំងបងប្អូនជនរួមជាតិទាំងអស់ សូមថ្លែងអំណរព្រះគុណដ៏ជ្រាលជ្រៅបំផុតចំពោះព្រះរាជវត្តមាន **ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងឱកាសដែលព្រះអង្គបានយាងមកចូលរួមក្នុងពិធីរុក្ខទិវាជាប្រវត្តិសាស្ត្រ នៅលើទឹកដីស្រុកអង្គស្នួល ខេត្តកណ្ដាល ដ៏មហោឡារិកនាពេលនេះ ជាមហាកិត្តិយសដ៏ធំធេង និងផ្ដល់នូវភាពកក់ក្ដៅសម្រាប់ប្រជារាស្ត្រខេត្តកណ្ដាលទាំងមូល ក៏ដូចជាបងប្អូនជនរួមជាតិនៅទូទាំងប្រទេស និងជាសក្ខីភាពបង្ហាញពីការយកព្រះទ័យទុកដាក់ខ្ពស់បំផុតរបស់ព្រះករុណាចំពោះសម្បត្តិព្រៃឈើជាតិ និង ប្រជារាស្ត្ររបស់ព្រះអង្គ។ ទន្ទឹមនឹងនេះ ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសម្ដេច ព្រះអង្គម្ចាស់ ទ្រង់ ឯកឧត្ដម លោក ជំទាវ លោក លោកស្រី តំណាងប្រទេសអ្នកផ្ដល់ជំនួយ អង្គការជាតិ សហគមន៍អន្តរជាតិ និងវិស័យឯកជន ដែលបាន ចូលរួមយ៉ាងសស្រាក់សស្រាំក្នុងការស្ដារ និងអភិវឌ្ឍន៍វិស័យព្រៃឈើនិងសត្វព្រៃនៅកម្ពុជា និងសូមអំពាវនាវបន្តជួយ លើវិស័យនេះបន្ថែមទៀត។

ជាទីបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ សូមលំឱនកាយ វាចាចិត្តគោរពបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី និងវត្ថុស័ក្តិសិទ្ធិក្នុងលោក ពិសេសទេវតារក្សាព្រះមហាស្វេតច្ឆ័ត្រ និងព្រះរាជបល្ល័ង្ក ព្រះបារមីអតីតព្រះមហាក្សត្រ ព្រះបរមរតនកោដ្ឋ ព្រះមហាក្សត្រីយានីគ្រប់ព្រះអង្គ សូមតាមជួយប្រោះព្រំបីបាច់ថែរក្សា ព្រះករុណាជាអម្ចាស់ជីវិត លើត្បូង ព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេច ព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និងសុភមង្គល ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូម ព្រះអង្គទាំងទ្វេរ ទ្រង់មានព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា និងព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីទ្រង់ គង់ប្រថាប់នៅក្នុងព្រះបរមសិរីរាជសម្បត្តិ សម្រាប់ជាម្លប់ដ៏ត្រជាក់ត្រជុំសុខដុមរមនារបស់ប្រជារាស្ត្រព្រះអង្គជានិច្ចនិរន្តរ៍ តរៀងទៅ។ សូមប្រគេនពរ ព្រះតេជគុណ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងប្រសិទ្ធពរជ័យសិរីមង្គលជូនចំពោះសម្ដេច ទ្រង់ ឯកឧត្ដម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ និងបងប្អូនជនរួមជាតិទាំងអស់ សូមទទួល បាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

***សូមអរព្រះគុណ និងអរគុណ!***

# របាយការណ៍
# ឯកឧត្តម វេង សាខុន
# រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឱកាសប្រារព្ធ " ទិវាមច្ឆជាតិ " នៅអាងទឹកទំនប់ពហុបំណងបាត់ដំបង ទំនប់សេកសក ភូមិទឹកសាប ឃុំផ្លូវមាស ស្រុករតនមណ្ឌល ខេត្តបាត់ដំបង

ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៧

- សូមក្រាបថ្វាយបង្គំ ព្រះតេជព្រះគុណ ព្រះមេគណ និងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ

**សូមគោរព** :

- សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាតំណាងដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់
- ឯកឧត្តម លោកជំទាវ តំណាងស្ថាប័ននីតិប្បញ្ញត្តិ ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តមលោកជំទាវរដ្ឋមន្ត្រី
- ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ ក្មួយៗសិស្សានុសិស្ស និងបងប្អូនជនរួមជាតិទាំងអស់ជាទីមេត្រី!



ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងឱកាសប្រារព្ធ " ទិវាមច្ឆជាតិ " នៅអាងទឹកទំនប់ពហុបំណងបាត់ដំបង ទំនប់សេកសក ភូមិទឹកសាប ឃុំផ្លូវមាស ស្រុករតនមណ្ឌល ខេត្តបាត់ដំបង

ជាបឋម តាងនាមឱ្យថ្នាក់ដឹកនាំ មន្ត្រីរាជការ និយោជិតនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំព្រះករុណាខ្ញុំ សូមសម្ដែងនូវគារវកិច្ច និងកត្តញ្ញុតាធម៌ដ៏ជ្រាលជ្រៅចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធី " **ទិវាមច្ឆជាតិ ១កក្កដា** " នៅអាងទឹកទំនប់ពហុបំណងបាត់ដំបង ទំនប់សេកសក ភូមិទឹកសាប ឃុំផ្លូវមាស ស្រុករតនមណ្ឌល ខេត្តបាត់ដំបងនាពេលនេះ និងសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះវត្តមានដ៏ថ្លៃថ្លារបស់ឯកឧត្តម លោកជំទាវ សមាជិកនៃព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត លោក លោកស្រីអង្គការជាតិ អន្តរជាតិ មន្ត្រីរាជការ សិស្សានុសិស្ស និងបងប្អូនជនរួមជាតិ ដែលបាន អញ្ជើញចូលរួម យ៉ាងមហោឡារិកក្នុងពិធីដ៏មានអត្ថន័យនេះ ក្នុងគោលបំណងបំផុសចលនាបងប្អូនប្រជាពលរដ្ឋគ្រប់ៗរូបឲ្យចូលរួមក្នុងការថែរក្សាពូជត្រី ការអភិរក្សជីវចម្រុះ ក៏ដូចជាវារិជាតផ្សេងៗទៀត ឱ្យបានគង់វង្សដើម្បីធានានិរន្តរភាពធនធានជលផលឱ្យបានគ្រប់គ្រាន់សម្រាប់តម្រូវការរបស់ប្រជាជនយើង។

ស្ថិតក្នុងបរិយាកាស ដ៏មហានក្ខត្តឫក្សនេះ ខ្ញុំព្រះករុណាខ្ញុំ សូមអនុញ្ញាតពិតពុទ្ធដីកា និងជម្រាបជូនអង្គពិធីទាំងមូលមេត្តាជ្រាបថា អាងទឹកទំនប់ពហុបំណងបាត់ដំបង ឬទំនប់សេកសកនេះ មានចម្ងាយប្រមាណ៥៤គីឡូម៉ែត្រពីទីរួមខេត្តបាត់ដំបង ស្ថិតនៅភូមិទឹកសាប ឃុំផ្លូវមាស ស្រុករតនមណ្ឌល ខេត្តបាត់ដំបង។ អាងទឹកនេះអាចរក្សាទឹកបាន



ប្រជាពលរដ្ឋ និងអជ្ញាធរដែនដីចូលរួមក្នុងឱកាសប្រារព្ធ " ទិវាមច្ឆជាតិ " នៅអាងទឹកទំនប់ពហុបំណងបាត់ដំបង ទំនប់សេកសក ភូមិទឹកសាប ឃុំផ្លូវមាស ស្រុករតនមណ្ឌល ខេត្តបាត់ដំបង

ដោយទំនប់តភ្ជាប់ពីភ្នំជីប៉ាងទៅភ្នំកូប មានកម្ពស់១០ ម៉ែត្រ និងបណ្តោយ៣ ៣០០ម៉ែត្រ ដែលបានកសាងឡើងចាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៤ ដោយក្រសួងធនធានទឹក និងឧតុនិយម សហការជាមួយក្រុមហ៊ុន Guangdong Foreign Construction Co.Ltd នៃសាធារណរដ្ឋប្រជាមានិតចិន ហើយការសាងសង់នេះទើបតែត្រូវបានបញ្ចប់ជាស្ថាពរនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៧។ កាលបរិច្ឆេទនេះ ក៏ជាការរំឭកឱ្យយើងនឹកឃើញផងដែរនូវប្រវត្តិនៃថ្ងៃ១៨ មីនា ១៩៧០ ដែលរបបលន់ នល់ បានទម្លាក់របបសង្គមរាស្ត្រនិយមរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះបរមរតនកោដ្ឋ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។ អាងទឹកនេះមានទំហំជាង ៣ ០០០ហិកតា អាចស្តុកទឹក បានប្រមាណ ១២៧,៣៥លានម៉ែត្រត្រីគុណ និងអាចផ្គត់ផ្គង់ទឹកប្រមាណ ២៨៦លានម៉ែត្រត្រីគុណ ក្នុងនោះ ៤២លានម៉ែត្រត្រីគុណ សម្រាប់ប្រើប្រាស់ក្នុងការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ១លានម៉ែត្រត្រីគុណសម្រាប់វិស័យឧស្សាហកម្ម និង២៤៣ លានម៉ែត្រត្រីគុណសម្រាប់វិស័យកសិកម្ម។ ទឹកដែលស្តុកទុកក្នុងអាងនេះ ត្រូវបង្ហូរទៅតាមដងស្ទឹងសង្កែ ហើយបន្តចែកចាយតាមប្រព័ន្ធប្រឡាយមេ និងប្រឡាយរងដើម្បីស្រោចស្រពផ្ទៃដីស្រែប្រាំង និងស្រែវស្សាចំនួន ៤៧ ០០០ហិកតា នៅក្នុងស្រុករតនមណ្ឌល បាណន់ សង្កែ និងស្រុកមោងឫស្សី។ ក្រៅពីការស្រោចស្រពតំបន់នេះក៏អាចជួយកាត់បន្ថយទឹកជំនន់ ជាតំបន់សម្រាប់ការធ្វើនេសាទ ផ្គត់ផ្គង់ទឹកសម្រាប់ប្រើប្រាស់ក្នុងក្រុងបាត់ដំបង ព្រមទាំងអាចទាញយកថាមពលវារីអគ្គិសនី និងទាក់ទាញភ្ញៀវទេសចរណ៍ទៀតផង។ គួររំឭកផងដែរថាដោយសារតំបន់នេះមានទេសភាពស្រស់ត្រកាលដែលបងប្អូនចូលចិត្តមកទស្សនាកម្សាន្តទៀតនោះ នៅមុនសម័យខ្មែរក្រហម អធិរាជសំឡេងមាស ស៊ីន ស៊ីសាមុត ក៏បានបន្សល់ទុកនូវបទចម្រៀងដ៏ពិរោះរណ្តំមកទល់ពេលនេះ គឺបទ អនុស្សាវរីយ៍សេកសក និងរំដួលដងស្ទឹងសង្កែ តរៀងរហូតមកដល់បច្ចុប្បន្ននេះ។

- ព្រះតេជព្រះគុណ ព្រះមេគណ និងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការ:
- សម្តេចក្រឡាហោម ជាទីគោរពដ៏ខ្ពង់ខ្ពស់
- អង្គពិធីទាំងមូលជាទីមេត្រី!

ពាក់ព័ន្ធនឹងភាពសម្បូរបែបនៃធនធានជលផលក្នុងប្រទេសកម្ពុជានាប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ពិសេសបឹងទន្លេសាប " ជាដួងព្រលឹងនៃវប្បធម៌និងសេដ្ឋកិច្ច" ជាទីសម្បូរមច្ឆជាតិបំផុតជាងបឹង ជាងទន្លេឯទៀតក្នុងលោកនិងកំពុងត្រូវបានទទួលរងសម្ពាធកាន់តែធ្ងន់ធ្ងរទៅៗជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ ចំពោះមុខនៃបញ្ហាប្រឈមនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតនិងឈ្លាសវៃបំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការប្រើប្រាស់និងទាញយកផលឲ្យបានសមស្រប និងដោយសមធម៌ចំពោះសេចក្តីត្រូវការផ្នែកសេដ្ឋកិច្ចសង្គម និងការកាត់បន្ថយភាពក្រីក្របានដាក់ចេញនូវគោលនយោបាយកំណែទម្រង់ស៊ីជម្រៅលើការគ្រប់គ្រងវិស័យជលផល ចាប់តាំងពីឆ្នាំ២០០០ ដោយបានកាត់ផ្ទៃឡូត៍នេសាទ ទាំងអស់ដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហគមន៍នេសាទ និង មួយផ្នែកទៀតកំណត់ជាកន្លែងអភិរក្ស។

ឆ្លើយតប ទៅនឹងចក្ខុវិស័យ ខាងលើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានរដ្ឋបាលជលផលជាសេនាធិការ បានរិះរកគ្រប់មធ្យោបាយដើម្បីធានានូវការគ្រប់គ្រងជលផល និងធនធានជលផល ជំរុញកិច្ចអភិវឌ្ឍន៍វារីវប្បកម្ម ផលិតកម្ម និងការកែច្នៃលើកស្ទួយជីវភាពរស់នៅរបស់ពលរដ្ឋ ក្នុងសហគមន៍មូលដ្ឋាន ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវចម្រុះផងទាំងមរតកវប្បធម៌ធម្មជាតិផង ប្រកបដោយនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ពិតមែនតែនៅមានបញ្ហាប្រឈម



ត្រីមេពូជត្រៀមលែងក្នុងឱកាសប្រារព្ធ " ទិវាមច្ឆជាតិ " នៅអាងទឹកទំនប់ពហុបំណងបាត់ដំបង ទំនប់សេកសក ភូមិទឹកសាប ឃុំផ្លូវមាស ស្រុករតនមណ្ឌល ខេត្តបាត់ដំបង

ដែលទាមទារឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ចូលរួមសហការប្រកបដោយការទទួលខុសត្រូវខ្ពស់ ដើម្បីធានានិរន្តរភាពសេដ្ឋកិច្ចសង្គមបរិស្ថាននៃអាងទន្លេ និង កាត់បន្ថយភាពក្រីក្រ។ និយាយដោយឡែក ពាក់ព័ន្ធនឹងស្ថានភាព នៃការគ្រប់គ្រង ការអភិរក្សនិងអភិវឌ្ឍន៍វិស័យជលផល ក៏ដូចជាសមិទ្ធផលផ្សេងៗដែលរដ្ឋបាលជលផលសម្រេចបានជាផ្លែផ្កានោះ ខ្ញុំព្រះករុណាខ្ញុំ សូមអនុញ្ញាតរាយការណ៍ជូនអង្គពិធីទាំងមូលមេត្តាជ្រាបថា ចាប់តាំងពីឆ្នាំ ២០០០ សហគមន៍នេសាទត្រូវបានលើកទឹកចិត្តឱ្យបង្កើតឡើង រហូតមកដល់បច្ចុប្បន្ននេះមានចំនួន ៥១៦សហគមន៍ ដែលមានសមាជិកសរុបចំនួនជាង ៣៣២ ពាន់នាក់ ក្នុងនោះសហគមន៍នេសាទទឹកសាបមានចំនួន ៤៧៧ និង សហគមន៍នេសាទសមុទ្រមានចំនួន៣៩។ សហគមន៍នេះ ទទួលបានការគាំទ្រផ្នែកបច្ចេកទេសពីរដ្ឋបាលជលផល និងដៃគូអភិវឌ្ឍន៍នានាដើម្បីពង្រឹងសមត្ថភាព គ្រប់គ្រង និង អនុវត្តផែនការសកម្មភាពសហគមន៍នេសាទគ្រប់ជ្រុងជ្រោយ។

ដោយឡែក កន្លែងអភិរក្សជលផលថ្មីមានចំនួន ៥៨ កន្លែងត្រូវបានបង្កើតឡើងនៅបឹងទន្លេសាប និងតាមដងទន្លេមេគង្គដែលសរុបទូទាំងប្រទេសមានចំនួន ៦៣១កន្លែង ក្នុងនោះសហគមន៍នេសាទដែលថែរក្សា និងការពារត្រីពូជមានចំនួន ៤៨៤កន្លែង។ អន្លង់ត្រីមេពូជចំនួន ៩៧កន្លែងនៅទន្លេមេគង្គលើបានរៀបចំគ្រប់គ្រង និងផ្សព្វផ្សាយដល់សហគមន៍ប្រជានេសាទ និងអាជ្ញាធរមូលដ្ឋានឱ្យបានយល់ដឹងអំពីសារៈសំខាន់នៃត្រីមេពូជ និងជំរុញទប់ស្កាត់ រាល់សកម្មភាព បង្កគ្រោះមហន្តរាយដល់ត្រីមេពូជ។ ជារឿយៗ សកម្មភាពល្មើសនេសាទ យកត្រីមេពូជក្នុងដែននេសាទ ត្រូវបានកើតមានជាញឹកញាប់នៅក្នុងកន្លែងអភិរក្សនិងអន្លង់ត្រី។ ម្យ៉ាងទៀត ទឹកបឹងទន្លេសាបមានភាពកខ្វក់ និងចំហាយឧស្ម័នតាមរយៈនៃការកាប់រានព្រៃលិចទឹក លំហូរចូលនៃជី ថ្នាំកសិកម្ម និងកាកសំណល់នានាមានកម្រិតខ្ពស់ ពិសេសក្នុងរដូវប្រាំងជាកត្តានាំឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ធនធានមច្ឆជាតិដែលយើងទាំងអស់គ្នា ត្រូវចូលរួមថែរក្សាបរិស្ថាន ខាងលើនេះឱ្យបានល្អប្រសើរ។ ស្ថិតក្នុងបរិបទដែលមានកំណើនប្រជាជនពី១ឆ្នាំទៅ១ឆ្នាំ គួបផ្សំទៅនឹងបម្រែបម្រួល ធាតុអាកាសការប្រែប្រួលបរិស្ថាន និងធនធានធម្មជាតិផងនោះ គឺជាកត្តានាំឱ្យមានការថយចុះផលធនធានជលផលផងដែរ។ យ៉ាងណាក៏ដោយការលើកកម្ពស់វារីវប្បកម្ម ដែលមានចែងយ៉ាងច្បាស់ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកំពុងបំពេញតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមវិភាគទានដល់ផលិតផលត្រីទូទាំងប្រទេស និងធានាដល់សន្តិសុខស្បៀង។ ជាក់ស្តែងនៅឆ្នាំ២០១៦ បរិមាណផលត្រីមានប្រមាណ ៨០១ ពាន់តោន ក្នុងនោះទឹកសាបប្រមាណ ៥០៩ពាន់ តោន សមុទ្រចំនួនប្រមាណ ១២០ ពាន់តោន និងវារីវប្បកម្មមានប្រមាណ ១៧២ ពាន់តោន គឺមានការកើនឡើងប្រមាណ ៦,៧%។ អ្នកចិញ្ចឹមត្រីមានចំនួនជាង ៧ ម៉ឺននាក់ ក្នុងនោះជាង ២០០នាក់បានក្លាយជាគ្រូបង្គោល និងជាគ្រូផ្សព្វផ្សាយបច្ចេកទេសនៅមូលដ្ឋានផ្ទាល់តែម្តង។ រីឯទីតាំងភ្ញាស់បង្កាត់ត្រីមានចំនួន៣០៧កន្លែង ក្នុងនោះ ២៩៤កន្លែងជារបស់ប្រជាពលរដ្ឋ ដែលមានសមត្ថភាព ផលិតកូនត្រីពូជប្រមាណ ១៩៤លានក្បាល។ ទន្ទឹមនេះរដ្ឋបាលជលផលបានខិតខំប្រឹងប្រែងបង្កើត និងពង្រឹងការគ្រប់គ្រងស្រះសហគមន៍ជម្រកត្រីបានចំនួន ៧៤៤ ស្រះនៅទូទាំងប្រទេស ដើម្បីអភិរក្សត្រីមេពូជតាមរយៈការជីកស្តារស្រះរួមគ្នានៅក្នុងភូមិឬឃុំ និងធ្វើឱ្យទិន្នផលត្រីកើនឡើងតាមវាលស្រែ។

ជាមួយនេះ រដ្ឋបាលជលផលបានប្រឹងប្រែងចុះជំរុញអនុវត្តច្បាប់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជាប្រចាំដោយមានកិច្ចសហការពីអាជ្ញាធរមូលដ្ឋានស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ជាក់ស្តែងនៅក្នុងឆ្នាំ២០១៦ បទល្មើសជលផលចំនួន ៣ ៦៥០ករណីត្រូវបានបង្ក្រាប ប្រៀបធៀបឆ្នាំ២០១៥ ថយចុះ ៣២៤ ករណីក្នុង





នោះបានបំផ្លាញចោលវត្ថុតាងចំនួន ៣ ០៩៦ករណី ពិន័យអន្តរការណ៍ចំនួន ៣៨៥ករណី បញ្ជូនទៅតុលាការចំនួន ១៦៩ករណី ដាក់ពន្ធនាគារចំនួន ១០១នាក់។ ដោយឡែកនៅក្នុងឆ្នាំ២០១៧នេះ ការបង្ក្រាបបទល្មើសជុំវិញបឹងទន្លេសាបដោយមានការអញ្ជើញចូលរួម ចុះត្រួតពិនិត្យយ៉ាងសកម្មពីសំណាក់សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី **ស ខេង** ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលខ្ញុំព្រះករុណាខ្ញុំក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឆន្ទៈមុះមុតនិងការចំណាយពេលវេលាដ៏មមាញឹករបស់ សម្តេចក្រឡាហោម រួមទាំងស្ថាប័នពាក់ព័ន្ធ កងកម្លាំងប្រដាប់អាវុធ ដែលបានសហការចុះបង្ក្រាបបទល្មើសជលផលប្រកបដោយជោគជ័យ និងស្មារតីទទួលខុសត្រូវ។

សូមជម្រាបជូនផងដែរថា បច្ចុប្បន្ននេះរដ្ឋបាលជលផលមានមន្ត្រីរាជការសរុបចំនួន ១ ០២០នាក់ ហើយចំនួននេះមានការថយចុះធៀបទៅនឹងឆ្នាំ២០០៨ ដែលមានចំនួន ១ ៣៥៨នាក់ និងឆ្នាំ២០០២ មានចំនួន ១ ៥០០នាក់។ អនុវត្តតាមគោលការណ៍កំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ក្រសួងក៏បានធ្វើវិសហមជ្ឈការក្នុងការផ្ទេរភារកិច្ចខណ្ឌរដ្ឋបាលជលផលនិងខណ្ឌរដ្ឋបាលព្រៃឈើដែលមានមន្ត្រីរាជការសរុបចំនួន ១៤០៥ នាក់ ក្នុងនោះខណ្ឌរដ្ឋបាលជលផលចំនួន ៥០៥ នាក់និងខណ្ឌរដ្ឋបាលព្រៃឈើចំនួន ៩០០ នាក់រួមទាំងថវិកាផងដែរឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ព្រមទាំងធ្វើវិសោធនកម្មច្បាប់ស្តីពីជលផលក្រោមការដឹកនាំផ្ទាល់ពីសម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី។

ពាក់ព័ន្ធ ទៅនឹងការងារខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទកន្លងមកបានខិតខំស្រាវជ្រាវ អំពីបញ្ហាគន្លឹះនិងបញ្ហាប្រឈមនានាសម្រាប់ជាមូលដ្ឋានកែលម្អធ្វើឱ្យប្រសើរឡើងលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍវិស័យជលផលក្នុងក្របខ័ណ្ឌកំណែទម្រង់ ស៊ីជម្រៅ របស់រាជរដ្ឋាភិបាលមានជាអាទិ៍៖ (១). ការជំរុញអនុវត្តច្បាប់នៅមានកម្រិតដោយកង្វះខាតហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយអនុវត្តការងារ រួមទាំងចំនួនមន្ត្រីរាជការដែលជាសមត្ថកិច្ចនៅថ្នាក់ក្រោមជាតិពុំទាន់គ្រប់គ្រាន់ ដើម្បីឱ្យសមាមាត្រទៅនឹងវិសាលភាពនៃការទទួលខុសត្រូវ (២).មានការវិនិយោគតិចតួចទាំងលើធនធានជលផល និងការកសាងសមត្ថភាពស្ថាប័ន (៣).មានចំណុចខ្វះចន្លោះផ្នែកច្បាប់ និងលិខិតបទដ្ឋានទាក់ទងនឹងសុវត្ថិភាពចំណីអាហារ និងគុណភាពផលិតផល (៤).មូលដ្ឋានធនធានជលផលអាចមានការថយចុះដោយបទល្មើសនេសាទ និងទម្លាប់មិនទទួលខុសត្រូវនៃការធ្វើនេសាទ ព្រមទាំងភាពមិនអនុគ្រោះនៃផលប៉ះពាល់ទៅលើបរិស្ថានមានកម្រិតខ្ពស់ រួមទាំងការអភិវឌ្ឍវារីវប្បកម្មដែលត្រូវការពេលវេលា និងធនធានវិនិយោគបន្ថែម (៥).នៅមានភាពខ្វះខាតទាំងមធ្យោបាយ សម្ភារព្រមទាំងការលើកទឹកចិត្តចំពោះមន្ត្រីរាជការដែលជាកិច្ចការដ៏សំខាន់ និងចាំបាច់មិនអាចមើលរំលងបានឡើយ។

ទន្ទឹមនឹងនេះ កិច្ចដំណើរការនៃការធ្វើកំណែទម្រង់លើវិស័យជលផលគឺត្រូវការពេលវេលាវែង និងសមស្របមួយដើម្បីធានាឲ្យមានប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងនិរន្តរភាព ហើយតម្រូវឲ្យមានការតាំងចិត្តដ៏មោះមុតពីយើងទាំងអស់គ្នាផងដែរ។ ជាមួយនេះ ខ្ញុំព្រះករុណាខ្ញុំជឿជាក់ថា ដើម្បីភាពជោគជ័យនៃរបៀបវារៈកំណែទម្រង់ ការចូលរួមរបស់ភាគីពាក់ព័ន្ធនីមួយៗ គឺមានភាពចាំបាច់ណាស់ព្រោះវាជាធាតុចូលដ៏មានសារៈសំខាន់ដើម្បីធានាឲ្យមានស្វ័យភាពក្នុងការគ្រប់គ្រង និងចាត់ចែងប្រកបដោយប្រសិទ្ធភាព។ ឆ្លើយតប

ចំពោះការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ដើម្បីកំណើនការងារ សមធម៌ និង ប្រសិទ្ធភាព និងជាទិសដៅអនុវត្តបន្ត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននិងកំពុងជំរុញការយកចិត្តទុកដាក់ធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍វិស័យជលផលកម្ពុជា ដោយអនុលោមតាមក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១៥-២០២៤ សំដៅធានារក្សាចីរភាពនៃធនធានជលផលទាំងក្នុងដែនទឹកសាប និងសមុទ្រដើម្បីបំពេញសេចក្តីត្រូវការរបស់ប្រជាជន និងទីផ្សារនាំចេញដោយផ្តោតលើសសរស្តម្ភបីគឺ៖(១).ជលផលទឹកសាប និងសមុទ្រ (២). វារីវប្បកម្មទឹកសាប និងសមុទ្រ និង(៣). ការកែច្នៃ និងពាណិជ្ជកម្ម ប្រកបដោយគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈជាចម្បង។

- សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់!
- អង្គពិធីទាំងមូលជាទីមេត្រី !

ខ្ញុំព្រះករុណាខ្ញុំ សូមអនុញ្ញាតពិតពុទ្ធដីកា និងសូមគោរពជម្រាបជូន សម្តេចក្រឡាហោម និងអង្គពិធីទាំងមូលមេត្តាជ្រាបថា ក្នុងទិវាមច្ឆជាតិលើកទី១៥នេះ យើងនឹងរៀបចំពិធីលែងកូនត្រីចម្រុះចំនួន១លានក្បាល កូនបង្កង១សែនក្បាល និងមេត្រីពូជមួយចំនួនដូចជាត្រីគល់រាំង ត្រីប្រា ត្រីឆ្កិន ត្រីកាហែ ត្រីព្រលូង ត្រីអណ្តែង ត្រីក្រាញ់ ត្រីផ្ទក់ អន្ទង់ កង្កែប និងអណ្តើក ។ល។ ដើម្បីធ្វើឲ្យអាងទឹកសេកសកនេះសម្បូរទៅដោយមច្ឆជាតិចម្រុះសម្រាប់បំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់នេះ។

ជាថ្មីម្តងទៀត ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរព្រះគុណ និងអរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចខិតខំប្រឹងប្រែងពីសំណាក់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន បណ្តាប្រទេសជាមិត្ត អង្គការជាតិ អន្តរជាតិ ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់ដែលបានជួយជ្រោមជ្រែងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានជលផលឱ្យមាននិរន្តរភាព សម្រាប់ផលប្រយោជន៍ របស់យើងទាំងអស់គ្នា និងបុត្រធីតាជំនាន់ក្រោយៗទៀត។

ជាមួយនេះដែរ ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំព្រះករុណាខ្ញុំសូមប្រគេនពរ ព្រះតេជព្រះគុណគ្រប់ព្រះអង្គ និងសូមគោរពជូនពរបវរមហាប្រសើរជូន **សម្តេចតេជោ**



សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញលែងត្រី ក្នុងឱកាសប្រារព្ធ " ទិវាមច្ឆជាតិ " នៅអាងទឹកទំនប់ពហុបំណងបាត់ដំបង ទំនប់សេកសក ភូមិទឹកសាប ឃុំផ្លូវមាស ស្រុករតនមណ្ឌល ខេត្តបាត់ដំបង

**ហ៊ុន សែន** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត សម្តេចក្រឡាហោម** និងលោកជំទាវជាទីគោរពដ៏ខ្ពង់ខ្ពស់ ព្រមទាំងបុត្រាបុត្រី ចៅៗជាទីស្រឡាញ់ សូមបានប្រកបដោយសិរីសួស្តី ជ័យមង្គល វិបុលសុខមហាប្រសើរ កាយពលមាំមួន ប្រាជ្ញាឈ្លាសវៃ និងទទួលនូវជ័យជម្នះថ្មីៗ ថែមទៀតជានិច្ចនិរន្តរ៍តរៀងទៅ។

សូមគោរពជូនពរ បវរប្រសើរដល់គណៈអធិបតី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ បងប្អូនជនរួមជាតិ លោកគ្រូ អ្នកគ្រូ និងក្មួយៗសិស្សានុសិស្សទាំងអស់ សូមទទួលនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ជាទីបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជាអាជ្ញាធរដែនដី មន្ត្រីរាជការ អ្នកមុខអ្នកការ និងប្រជាពលរដ្ឋនៅក្នុងខេត្តបាត់ដំបងទាំងមូលមានមោទនភាព និងមានកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមអនុញ្ញាតគោរពអញ្ជើញ **សម្តេចក្រឡាហោម**ឧបនាយករដ្ឋមន្ត្រី មេត្តាផ្តល់នូវមតិសំណេះសំណាល និងអនុសាសន៍គន្លឹះ ដើម្បីជាប្រទីបសម្រាប់យើងខ្ញុំទាំងអស់គ្នា បន្តអនុវត្តកំណែទម្រង់ស៊ីជម្រៅលើវិស័យជលផលឱ្យទទួលបានជោគជ័យបន្ថែមទៀតប្រកបដោយផ្លែផ្កានាពេលខាងមុខ៕

**សូមគោរពអញ្ជើញសម្តេចក្រឡាហោម**

***សូមអរព្រះគុណ និងសូមអរគុណ!***

# សុន្ទរកថា
# ឯកឧត្តម វេង សាខុន
# រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ក្នុងពិធីសំណេះសំណាលជាមួយនិស្សិតកម្មសិក្សានៅប្រទេសអ៊ីស្រាអែល ជំនាន់ទី១០ ឆ្នាំសិក្សា ២០១៧ - ២០១៨

សាកលវិទ្យាល័យភូមិន្ទកសិកម្ម ថ្ងៃព្រហស្បតិ៍ ទី២៤ ខែសីហា ឆ្នាំ២០១៧

**សូមគោរព៖**

- គណៈអធិបតី
- ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា
- សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងក្មួយៗនិស្សិតទាំងអស់ជាទីមេត្រី!




ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីភាពក្នុងពិធីសំណេះសំណាលជាមួយនិស្សិតកម្មសិក្សានៅប្រទេសអ៊ីស្រាអែល ជំនាន់ទី១០ ឆ្នាំសិក្សា ២០១៧ - ២០១៨

ថ្ងៃនេះ ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយ ដោយបានមកចូលរួម ក្នុងពិធីសំណេះសំណាល ជាមួយក្មួយៗនិស្សិត ដែលត្រៀមខ្លួនចេញទៅបំពេញកម្មសិក្សានៅប្រទេសអ៊ីស្រាអែល ក្នុងឆ្នាំសិក្សាថ្មី ២០១៧-២០១៨ នាពេលឆាប់ៗខាងមុខនេះ។ ជាមួយនេះ ខ្ញុំសូមសម្តែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ក្មួយៗនិស្សិតទាំងអស់ដែលបានឆ្លៀតឱកាសដ៏មានតម្លៃអញ្ជើញចូលរួមយ៉ាងឱឡារិកក្នុងព្រឹត្តិការណ៍ដ៏មានអត្ថន័យនេះ។

ជាមួយនេះដែរ ខ្ញុំបានកត់សម្គាល់ឃើញថា សាកលវិទ្យាល័យភូមិន្ទកសិកម្មបានខិតខំពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយនឹងសាកលវិទ្យាល័យ និងគ្រឹះស្ថានដៃគូអន្តរជាតិនានា យ៉ាងសស្រាក់សស្រាំ មានលក្ខណៈទូលំទូលាយ ហើយទទួលបាននូវលទ្ធផលជាផ្លែផ្កា ប្រកបដោយមោទនភាព។ ជាក់ស្តែងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយក្រុមហ៊ុន សិក្សាកសិកម្ម Agro-studies របស់ប្រទេសអ៊ីស្រាអែល ក្នុងការផ្តល់ឱកាសដល់និស្សិតឆ្នាំទី៣ ដែលកំពុងសិក្សានៅក្នុងសាកលវិទ្យាល័យភូមិន្ទកសិកម្ម ឱ្យបានទៅចូលរួមធ្វើកម្មសិក្សា រយៈពេល១១ខែ នៅប្រទេសអ៊ីស្រាអែលជារៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ២០០៨ រៀងរហូតមកដល់ពេលនេះ មានរយៈពេល១០ឆ្នាំហើយ ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមវាយតម្លៃខ្ពស់ និងកោតសរសើរ ចំពោះក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំ មន្ត្រីរាជការ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងសាលាជាតិកសិកម្មទាំងពីរ ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម ប្រកបដោយការទទួលខុសត្រូវខ្ពស់ក្នុងការអប់រំ បណ្តុះបណ្តាលដល់ក្មួយៗនិស្សិត ដើម្បីឱ្យក្លាយទៅជាធនធានមនុស្ស ដ៏ល្អប្រសើរបំផុត ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍វិស័យកសិកម្មកម្ពុជាយើង ឱ្យមានការរីកចម្រើនឡើងស្របតាមការវិវឌ្ឍន៍នៃសេដ្ឋកិច្ចជាតិ ក្នុងបរិបទនៃសាកលភាវូបនីយកម្ម។

**អង្គពិធីទាំងមូលជាទីមេត្រី!**

នៅក្នុងដំណើរការជំរុញកំណើនសេដ្ឋកិច្ចជាតិ និងការកាត់បន្ថយភាពក្រីក្រ រាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈនិងការប្ដេជ្ញាចិត្តខ្ពស់ណាស់ក្នុងការពង្រីកមូលដ្ឋានកំណើនដែលក្នុងនោះបានចាត់ទុកវិស័យកសិកម្ម ជាវិស័យអាទិភាពគ្រប់កាលៈទេសៈ ជាមូលដ្ឋាននៃការធានា និងពន្លឿនកំណើនសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព។ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលបានដាក់ចេញនៅក្នុងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ គឺតម្រង់ទិសទៅរកការធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជាតាមអភិក្រមនិងក្នុងវិសាលភាពនិងល្បឿនថ្មី ដើម្បីបន្តប្រែក្លាយវិស័យនេះពីដំណាក់កាលនៃការអភិវឌ្ឍតាមបែបវិបុលកម្ម បើកទូលាយ ពោលគឺពឹងផ្អែកជាសំខាន់លើធនធានមានស្រាប់ និងពឹងផ្អែកលើការប្រើប្រាស់ធាតុចូលកសិកម្មតាមបែបប្រពៃណី ឈានទៅរកដំណាក់កាលថ្មីដែលផ្ដោតលើផលិតកម្មតាមបែបប្រពលវប្បកម្ម ស៊ីជម្រៅ ពោលគឺពឹងផ្អែកជាសំខាន់លើការប្រើប្រាស់បច្ចេកទេស បច្ចេកវិទ្យាថ្មី យន្តូបនីយកម្ម ការស្រាវជ្រាវផ្សព្វផ្សាយនិងអភិវឌ្ឍ ដើម្បីលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម ពាណិជ្ជូបនីយកម្មកសិកម្ម និងធានាចីរភាពបរិស្ថាននិងធនធានធម្មជាតិ។

ពិតណាស់ថា វិស័យកសិកម្មកម្ពុជាកំពុងស្ថិតនៅក្នុងដំណាក់កាលដែលមានការផ្លាស់ប្ដូរជាវិជ្ជមានគួរឱ្យកត់សម្គាល់ក៏ដោយ ក៏វិស័យនេះនៅបន្តជួបបញ្ហាប្រឈមមួយចំនួនទៀត ពិសេសភាពងាយរងគ្រោះនៃប្រព័ន្ធដាំដុះ ធាតុចូលកសិកម្មនៅមានតម្លៃខ្ពស់ ផលិតភាពនិងតម្លៃបន្ថែមនៅទាប ផលប៉ះពាល់ពីបម្រែបម្រួលធាតុអាកាស កង្វះខាតហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធស្រោចស្រពសមស្របនៅតំបន់ដែលពុំមានប្រភពទឹកគ្រប់គ្រាន់ ការធ្លាក់ចុះតម្លៃកសិផល។ល។ ដែលចាំបាច់តម្រូវឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀតក្នុងការស្វែងរកដំណោះស្រាយប្រកបដោយប្រសិទ្ធភាពចំពោះបញ្ហាប្រឈមទាំងនោះ។ ពិតណាស់ថា វិស័យកសិកម្មកម្ពុជាយើងនៅមានសក្ដានុពលធំធេងណាស់ក្នុងការចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិនិងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋប្រសិនបើយើងគិតពីធនធានដីនិងទឹកដែលយើងមាន។ ដូច្នេះយើងត្រូវខិតស្រាវជ្រាវរិះរកមធ្យោបាយ ទាំងខាងក្របខណ្ឌគោលនយោបាយ យុទ្ធសាស្រ្ត លិខិតបទដ្ឋានគតិយុត្ត បច្ចេកទេស និងការអនុវត្តល្អៗសម្រាប់តម្រង់ទិស នៃការទាញយកប្រយោជន៍ពីធន



ឯកឧត្តម វេង សាខុន រដ្ឋមន្រ្តី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងពិធីសំណេះសំណាលជាមួយនិស្សិតកម្មសិក្សានៅប្រទេសអ៊ីស្រាអែល ជំនាន់ទី១០ ឆ្នាំសិក្សា ២០១៧ - ២០១៨

ធានដ៏សំខាន់ទាំងនេះប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ច និងនិរន្តរភាពខ្ពស់បំផុត ដើម្បីពង្រីកសក្ដានុពល នៃការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិក្នុងរយៈពេលមធ្យមនិងវែងប្រកបដោយភាពប្រកួតប្រជែង ឆ្ពោះទៅចូលរួមចំណែកសម្រេចបាននូវមហិច្ឆតា នៃ"ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០" ដែលកម្ពុជានឹងក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់។

ក្នុងបរិបទបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលតែងតែបានចាត់ទុកថា ការអភិវឌ្ឍន៍ធនធានមនុស្ស គឺជាកន្សោមអាទិភាពនិងជាគ្រឹះដ៏សំខាន់បំផុតមួយ ដើម្បីបង្កើនសក្ដានុពល នៃមូលធនបញ្ញា និងជាមធ្យោបាយឈានទៅសម្រេចឱ្យបាននូវបេសកកម្មដ៏ឧត្ដុង្គឧត្ដម គឺការអភិវឌ្ឍន៍លើគ្រប់វិស័យឱ្យប្រកបដោយប្រសិទ្ធភាព និងចីរភាព។ ជាងនេះទៅទៀត ប្រមុខរាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃបំផុតរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា តែងតែក្រើនរំឭកប្រកបដោយសុទិដ្ឋិនិយមថា " យុវជនកម្ពុជានឹងដើរទាន់យុវជនអាស៊ានអំពីចំណេះដឹង បើទោះបីថាគម្លាតប្រាក់ចំណូលរវាងប្រទេសកម្ពុជា និងអាស៊ានមិនស្មើគ្នាក៏ដោយ។ ប៉ុន្តែគម្លាតខួរក្បាល គឺពិតជាអាចកាត់បន្ថយបាន ព្រោះយុវជនកម្ពុជាកំពុងតែស្រេកឃ្លានចំណេះដឹងយ៉ាងខ្លាំងសម្រាប់អនាគតរបស់ពួកគេ " ។ ដូច្នេះធនធានមនុស្ស គឺជាកត្តាសំខាន់ចាំបាច់មិនអាចខ្វះបាន។ ទោះបីប្រទេសសម្បូរដោយធនធានធម្មជាតិ យ៉ាងណាក៏ដោយ បើខ្វះធនធាន



និស្សិតចូលរួមក្នុងពិធីសំណេះសំណាលជាមួយនិស្សិតកម្មសិក្សា នៅប្រទេសអ៊ីស្រាអែល ជំនាន់ទី១០ ឆ្នាំសិក្សា ២០១៧ - ២០១៨

មនុស្ស គឺយើងមិនអាចប្រែក្លាយធនធានធម្មជាតិនោះឱ្យទៅជាគុណប្រយោជន៍សម្រាប់អភិវឌ្ឍប្រទេសជាតិបានឡើយ។ ជាការពិត ឧត្តមភាពប្រកួតប្រជែង របស់ប្រជាជាតិមួយ អាស្រ័យជាសំខាន់លើកត្តាធនធានមនុស្ស ដែលមានចំណេះដឹងខ្ពស់ ទូលំទូលាយ មានភាពច្នៃប្រឌិត និងជំនាញច្បាស់លាស់។ ដោយមើលឃើញពីមហិច្ឆតានេះ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយ ឧស្សាហកម្ម ២០១៥-២០២៥ ដែលបញ្ហានេះបានក្លាយទៅជាប្រធានបទធំ ដើម្បីឆ្លើយតបជាមួយបច្ចេកវិជ្ជាទំនើប និង បានធ្វើការបណ្ដុះបណ្ដាលធនធានមនុស្ស ឱ្យស្របទៅនឹងការវិនិយោគពីក្រៅប្រទេស។

**អង្គពិធីទាំងមូលជាទីមេត្រី!**

យើងទាំងអស់គ្នា បានជ្រាបរួចហើយថា ប្រទេសអ៊ីស្រាអែល ជាប្រទេសមួយដែលមានសក្ដានុពលខ្លាំង និងប្រើប្រាស់បច្ចេកវិទ្យាទំនើបក្នុងវិស័យកសិកម្ម។ តាមរយៈការស្រាវជ្រាវឯកសារផ្សេងៗបានឱ្យយើងដឹងថា ប្រទេសអ៊ីស្រាអែល ជាប់លំដាប់ថ្នាក់ទី១៧ក្នុងចំណោមប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿនក្នុងពិភពលោក។ តាំងពីឆ្នាំ ២០០២មក ប្រទេសនេះ បានទទួលពានរង្វាន់ណូបែលផ្នែកវិទ្យាសាស្ត្រចំនួន៦ និងជាប្រទេសឈានមុខលំដាប់ពិភពលោក ខាងផ្នែកថាមពលពន្លឺព្រះអាទិត្យនិងបច្ចេកវិទ្យាប្រើប្រាស់ទឹក។ ដើម្បីដោះស្រាយបញ្ហាទឹក អាកាសធាតុ និងទីតាំងភូមិសាស្ត្រមិនអំណោយផលផងនោះ អ៊ីស្រាអែលបានធ្វើការវិនិយោគយ៉ាងច្រើន ទៅលើកិច្ចការស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រ។ ជាលទ្ធផល ប្រទេសនេះបានបង្កើត នូវប្រព័ន្ធស្រោចស្រពជាដំណក់ទឹកដែលត្រូវបានគេទទួលស្គាល់ជាសាកលថា ជាប្រព័ន្ធដែលមានសមត្ថភាពក្នុងការសន្សំសំចៃទឹក និងផ្ដល់អត្ថប្រយោជន៍សម្រាប់កសិកម្មទំនើប។ ម្យ៉ាងទៀត បើទោះជាផ្ទៃដីគ្របដណ្ដប់ដោយវាលខ្សាច់ ខ្វះទឹក និងអាកាសធាតុមិនអំណោយផលដល់ការធ្វើកសិកម្មក៏ដោយ ក៏ប្រទេសនេះនៅតែមានការអភិវឌ្ឍផ្នែកកសិកម្មបានយ៉ាងខ្លាំងក្លាគួរឱ្យកត់សម្គាល់ផងដែរ។សូមរំឭកជូនផងដែរថា ខ្ញុំបានទៅធ្វើទស្សនកិច្ចជាផ្លូវការនៅប្រទេសអ៊ីស្រាអែល និងបានចូលរួមក្នុងកម្មវិធីបិទវគ្គបញ្ចប់ការសិក្សារបស់និស្សិតយើងកាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦កន្លងទៅ ហើយជាបន្តបន្ទាប់ខ្ញុំបានជួបពិភាក្សាជាច្រើនលើក ជាមួយឯកឧត្តមឯកអគ្គរដ្ឋទូត អ៊ីស្រាអែល ដើម្បីជំរុញកិច្ចសហប្រតិបត្តិការរវាងប្រទេសយើងទាំងពីរ។ ជាលទ្ធផល សាកលវិទ្យាល័យ យើងបានទទួលកូតានិស្សិតកម្មសិក្សាកើនពី១៦០នាក់ក្នុងឆ្នាំ២០១៦ មក២១២ នាក់ នៅឆ្នាំ២០១៧នេះ និងបានបង្កើតគម្រោងរយៈពេល២ឆ្នាំ ដើម្បីបណ្ដុះបណ្ដាលធនធានមនុស្សរយៈពេលខ្លី នៅក្នុងសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដែលនឹងត្រូវចាប់ផ្ដើមអនុវត្តមុនដំណាច់ឆ្នាំ២០១៧នេះ និងគ្រោងសាងសង់កសិដ្ឋានដំណាំគំរូមួយនៅក្នុងសាកលវិទ្យាល័យភូមិន្ទកសិកម្មផងដែរ។

ថ្ងៃនេះទៀតសោត យើងបានប្រារព្ធពិធីសំណេះសំណាលជាមួយនិស្សិត ដែលត្រៀមចេញទៅធ្វើកម្មសិក្សានៅប្រទេសអ៊ីស្រាអែល ជំនាន់ទី១០ ។ តាមរយៈរបាយ



ឯកឧត្តម ង៉ោ ប៊ុនថាន សាកលវិទ្យាធិការ សាកលវិទ្យាល័យភូមិន្ទកសិកម្ម ថ្លែងក្នុងពិធីសំណេះសំណាលជាមួយនិស្សិតកម្មសិក្សានៅប្រទេសអ៊ីស្រាអែល ជំនាន់ទី១០ ឆ្នាំសិក្សា ២០១៧ - ២០១៨

ការណ៍របស់ ឯកឧត្តម ង៉ោ ប៊ុនថាន សាកលវិទ្យាធិការបាន បង្ហាញថា និស្សិតចូលរួមកម្មសិក្សា នាពេលនេះមានចំនួន ២១២នាក់ ដែលមាននិស្សិតជានារីចំនួន២៥នាក់ ក្នុងនោះ មាននិស្សិតមកពីសាលាជាតិកសិកម្មព្រែកលៀប ចំនួន ១០ នាក់ និង សាលាជាតិកសិកម្មកំពង់ចាមចំនួន១០នាក់ ហើយ ក៏ជាលើកដំបូងដែរសម្រាប់សាលាជាតិកសិកម្មទាំងពីរ ដែល បានទទួលការបែងចែកកូតា ពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម ហើយនិស្សិតទាំងអស់នឹងត្រូវចេញដំណើរចំនួន៦លើក ដែល លើកទី១ចំនួន១៤នាក់នឹងត្រូវចេញនៅថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៧ខាងមុខនេះ ។ តាមរបាយការណ៍ក៏បានបង្ហាញដែរ ថា នៅប្រទេសអ៊ីស្រាអែល ក្មួយៗនឹងត្រូវចូលរៀនមុខវិជ្ជា សំខាន់ៗមួយចំនួនដូចជាៈ ស្តង់ដារកសិកម្មអន្តរជាតិ សេដ្ឋកិច្ចកសិកម្ម ការការពារដំណាំ គម្រោងស្រាវជ្រាវ អភិរក្សធនធានដី មូលដ្ឋានគ្រឹះនៃប្រព័ន្ធស្រោចស្រពបែបទំនើបបច្ចេកទេសក្រោយពេលប្រមូលផលបន្លែនិងផ្លែឈើ ការធ្វើកសិកម្ម ឈើហូបផ្លែ កសិកម្មសមស្រប និងអនុវត្តផ្ទាល់នៅក្នុងកសិដ្ឋាន រួមមាន ការចិញ្ចឹមសត្វ សាកវប្បកម្ម ដំណាំផ្កា ផលិតកម្មផ្សិត ផលិតកម្មគ្រាប់ពូជ ការប្រមូលផលនិងការវេចខ្ចប់ជាដើម ដែល មុខវិជ្ជាទាំងនេះ សុទ្ធតែជាមុខវិជ្ជាមានសារៈសំខាន់ណាស់ សម្រាប់ជាបទពិសោធន៍នៅកម្ពុជាយើងនាពេលបច្ចុប្បន្ននេះ ដែលយើងត្រូវយកចំណេះដឹងនេះទៅផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ប្រជាកសិករយើងក្នុងការលើកកម្ពស់ពិពិធភាវូបនីយកម្មកសិកម្មនិងកាត់បន្ថយចំណាកស្រុកនៅតំបន់ជនបទ ។

គួរកត់សម្គាល់ថា គោលបំណងសំខាន់នៃកម្មសិក្សា នេះ គឺដើម្បីផ្តល់ឱកាសឱ្យក្មួយៗនិស្សិតបានសិក្សារៀនសូត្រ នៅក្នុងសាលាជាមួយសាស្ត្រាចារ្យបរទេស និងបានអនុវត្ត ផ្ទាល់នៅក្នុងកសិដ្ឋាន និងក្នុងផលិតកម្មផ្ទាល់ ដែលក្មួយៗអាច ទទួលបាននូវបទពិសោធន៍ ចំណេះដឹង ចំណេះធ្វើជាក់ស្តែង និងអាចសន្សំ ដើមទុនបានខ្លះៗ ដើម្បីយកមករៀបចំកសាង ការងាររបស់ខ្លួន នៅក្នុងប្រទេសយើង នាពេលបញ្ចប់ការ សិក្សា ។ ពិតណាស់ថា កម្មសិក្សារយៈពេល១១ខែនេះ គឺជា ពេលវេលាមួយដ៏វែង និងមានការលំបាកស្មុគស្មាញជាច្រើន រួមទាំងការរស់នៅឆ្ងាយពីក្រុមគ្រួសារផង ក៏ប៉ុន្តែវាជាវិញ្ញាសា មួយដ៏ល្អ ដែលយុវនិស្សិតត្រូវតែប្រឡូក ហែលឆ្លងកាត់ ដើម្បី លត់ដំខ្លួនយើងឱ្យក្លាយជាធនធានមនុស្សមួយដ៏រឹងមាំ ជាក្តី សង្ឃឹមរបស់ក្រុមគ្រួសារ និងសង្គមជាតិ នាពេលអនាគត។




ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្នុងពិធីសំណេះសំណាលជាមួយនិស្សិតកម្មសិក្សានៅ ប្រទេសអ៊ីស្រាអែល ជំនាន់ទី១០ ឆ្នាំសិក្សា ២០១៧ - ២០១៨

តាមខ្ញុំដឹងសាកលវិទ្យាល័យ មានការជ្រើសរើសតែនិស្សិត ស្ម័គ្រចិត្ត និងធ្វើតែស្តយកតែនិស្សិតមានសមត្ថភាព ហើយ បានណែនាំពន្យល់អំពីរបៀបធ្វើកម្មសិក្សានេះ យ៉ាងច្បាស់លាស់រួចហើយ។ ដូចនេះនិស្សិតទាំង២១២នាក់នេះ គឺជា និស្សិតជ័យលាភី ដែលយើងត្រូវតែមានមោទនភាពខ្ពស់ចំពោះ ខ្លួនយើង ។ សូមក្មួយនិស្សិតជៀសវាងឱ្យបាន នៅពេលទៅ ដល់អ៊ីស្រាអែលហើយ ជួបការលំបាកក្នុងការរៀនសូត្រ ធ្វើ ការងារ លំបាករស់នៅ មិនខិតខំប្រឹងប្រែងតស៊ូទៅមុខ តែបែរ ជាងាកក្រោយរករឿងថា ចាញ់បោកសាកលវិទ្យាល័យ ឬចោទ សាកលវិទ្យាល័យថាជួញដូរមនុស្ស ឬរត់ពន្ធមនុស្សទៅវិញ ដូចករណីនិស្សិតម្នាក់កាលពីឆ្នាំកន្លងមកនេះ ។

ទោះជាយ៉ាងណា ដើម្បីជាជំនួយស្មារតីដល់ក្មួយៗ និស្សិត ដែលជាទំពាំងស្នងឬស្សីនៃមាតុភូមិកម្ពុជាយើង ក្នុង នាមថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំ មានសេចក្តីរីករាយ សូមផ្តល់នូវអនុសាសន៍គន្លឹះមួយចំនួន ដល់ក្មួយៗយកទៅពិចារណាអនុវត្តដូចតទៅៈ

ទី១.ត្រូវខិតខំសិក្សារៀនសូត្រ និងក្រេបជញ្ជក់យក បទពិសោធន៍ និងចំណេះដឹង ចំណេះធ្វើផ្សេងៗ ទាំងបច្ចេកទេសកសិកម្ម និងការគ្រប់គ្រងដឹកនាំកសិដ្ឋាន ដើម្បីពង្រឹង គុណភាពសិក្សា សមត្ថភាពចំណេះដឹង និងទេពកោសល្យ ជំនាញសម្រាប់អនាគតរបស់ខ្លួនយើង ស្របនឹងសុភាសិត បុរាណបានពោលថា "វិជ្ជាវិសេសលើសទ្រព្យធន ចោរមិន អាចប្លន់លុកលួចបាន វិជ្ជាគ្មានថ្លៃនឹងប្រមាណ ប្រើចេះតែ បានគ្រប់វេលា" ។








ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីសំណេះសំណាលជាមួយនិស្សិតកម្មសិក្សានៅប្រទេសអ៊ីស្រាអែល ជំនាន់ទី១០ ឆ្នាំសិក្សា ២០១៧ - ២០១៨

ទី២. ត្រូវគោរពច្បាប់ទម្លាប់របស់ប្រទេសគេ វិន័យក្នុងការងារ ឧស្សាហ៍ព្យាយាម និងធ្វើឱ្យគេចូលចិត្តស្រឡាញ់រាប់អានជាតិសាសន៍ខ្មែរយើង។ ត្រូវយកចិត្តទុកដាក់ខ្ពស់លើបញ្ហាសុខភាពផ្ទាល់ខ្លួន និងសុវត្ថិភាពការងារជាចម្បង ពីព្រោះក្មួយៗនៅក្មេងហើយឃ្លាតឆ្ងាយពីក្រុមគ្រួសារ។ ត្រូវចេះថែរក្សា ជួយយកអាសារគ្នាទៅវិញទៅមក ក្នុងស្មារតីសាមគ្គីភាពភាតរភាព ឱ្យបានល្អប្រសើរ តាមដំបូន្មានដូនតាយើងដែលបានពោលថា " នៅផ្ទះម្ដាយទីទៃ នៅព្រៃម្ដាយតែមួយ" និងត្រូវមានទំនាក់ទំនង មកសាកលវិទ្យាល័យ និងក្រុមគ្រួសារវិញឱ្យបានជាប់ជាប្រចាំកុំឱ្យបាត់ដំណឹង។ ។

ទី៣.ត្រូវមានកិច្ចសហប្រតិបត្តិការល្អ ជាមួយមិត្តនិស្សិតអន្តរជាតិទាំងអស់ ដែលរស់នៅរៀនសូត្រ និងបំពេញការងារជាមួយគ្នា និង មិនត្រូវចូលរួមពាក់ព័ន្ធជាមួយរឿងនយោបាយ នៅក្នុងប្រទេសគេឡើយ ព្រមទាំងត្រូវថែរក្សាប្រពៃណី វប្បធម៌ជាតិ និងទំនៀមទម្លាប់ដែលជាកេរ្តិ៍មរតករបស់ខ្មែរយើងឱ្យបានខ្ជាប់ខ្ជួន។

ទី៤.ត្រូវសិក្សាជាក្រុម រួមគ្នាធ្វើការស្រាវជ្រាវបំពេញបន្ថែមលើទ្រឹស្តី ដែលបានសិក្សាកន្លងមក ធ្វើឲ្យប្រាកដថាសមត្ថភាពរបស់ខ្លួននឹងអាចរួមចំណែកសកម្មក្នុងការអភិវឌ្ឍន៍សង្គមជាតិ ក្រោយពីបានបញ្ចប់ការសិក្សានេះ។

ទី៥.ត្រូវចងចាំថា ប្រទេសជាតិនឹងផ្ញើសេចក្តីសង្ឃឹមទាំងស្រុងទៅលើក្មួយៗជំនាន់ក្រោយនេះហើយ។ ក្មួយៗនឹងត្រូវប្រឡូកនៅក្នុងសាលារៀននៃជីវិតជាក់ស្តែង ដើម្បីកសាងជីវភាពផ្ទាល់ខ្លួនផង វាសនាអនាគត របស់គ្រួសារផង និងដើម្បីបំពេញការងារតាមវិជ្ជាជីវៈរបស់ខ្លួន ដែលជាការចូលរួមចំណែកក្នុងការកសាង និង អភិវឌ្ឍន៍ប្រទេសជាតិក្នុងនាមជាពលរដ្ឋពេញលេញម្នាក់។ ដូច្នេះ ក្មួយៗត្រូវបន្តប្រកាន់ខ្ជាប់នូវស្មារតីតស៊ូព្យាយាម អំណត់ អត់ធន់ សកម្មប្រយុទ្ធនៅក្នុងការងារ និងត្រូវមានគំនិតច្នៃប្រឌិត ស្របនឹងកំណាព្យមួយបានពោលថា" ចេះមែនហើយតែនៅឡើយមិនទាន់ចេះព្រោះចំណេះច្រើនលើសលុបគ្រប់បែបយ៉ាង នឹងគណនារាប់មិនបានមានជាតាង កុំអាលអាងថាចេះសព្វគ្រប់អស់ហើយ"។

ជាទីបញ្ចប់ ជាមួយនឹងការអបអរសាទរ ចំពោះក្មួយនិស្សិតដែលនឹងត្រូវទៅបំពេញកម្មសិក្សានៅប្រទេសអ៊ីស្រាអែលនាពេលខាងមុខនេះ ខ្ញុំសូមជូនពរគណៈអធិបតី អង្គពិធីទាំងមូល និងក្មួយៗនិស្សិតទាំងអស់ សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ សេចក្តីសុខចម្រើន ជាពិសេសសូមជួបប្រទះតែនឹងពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ សូមឱ្យដំណើរបំពេញបេសកកម្មធ្វើកម្មសិក្សារបស់ក្មួយៗ និស្សិតជំនាន់ទី១០នេះ ទទួលបានជោគជ័យល្អប្រសើរ តាមក្តីសង្ឃឹមរំពឹងទុករបស់យើងទាំងអស់គ្នា និងមានសុវត្ថិភាពខ្ពស់គ្រប់ៗរូបជានិរន្តរ៍ ។

***សូមអរគុណ!***

# សុន្ទរកថា
# ឯកឧត្តម វេង សាខុន
# រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ក្នុងពិធីបើក សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាង
# ផែនការយុទ្ធសាស្ត្ររយៈពេល១០ឆ្នាំ របស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម ២០១៧-២០២៦

ទន្លេបាសាក់២ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧

**សូមគោរព ៖**

- គណៈអធិបតី
- ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ
- សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងក្មួយៗនិស្សិតទាំងអស់ជាទីមេត្រី!




ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីបើក សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងផែនការយុទ្ធសាស្ត្ររយៈពេល១០ឆ្នាំ របស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម ២០១៧-២០២៦

ថ្ងៃនេះខ្ញុំពិតជាមានមោទនភាព និង សេចក្តីសោមនស្សរីករាយជាអនេក ដោយបានចូលរួមក្នុងកម្មវិធីបើកសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ផែនការយុទ្ធសាស្ត្ររយៈពេលវែង១០ឆ្នាំ របស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម នាពេលនេះ។ ជាមួយនេះ ខ្ញុំសូមសម្តែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ដៃគូរអភិវឌ្ឍន៍ ក្មួយៗនិស្សិតទាំងអស់ដែលបានឆ្លៀតឱកាស ដ៏មានតម្លៃអញ្ជើញចូលរួមយ៉ាងកុះករ ក្នុងអង្គសិក្ខាសាលាដ៏មានសារៈសំខាន់នេះ។ ពិតណាស់ថា ការផ្តួចផ្តើមបង្កើតឱ្យមានសិក្ខាសាលាពិគ្រោះយោបល់នាពេលនេះ គឺដើម្បីពិនិត្យមើលអំពីវឌ្ឍនភាព កាលានុវត្តភាព បញ្ហាប្រឈម ការប្រមូលធាតុចូលពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ក្នុងបុព្វហេតុ ផ្តល់ផលប្រយោជន៍រួម ជាពុទ្ធិសម្រាប់រៀបចំធ្វើផែនការយុទ្ធសាស្ត្រ រយៈពេលវែង ដើម្បីអភិវឌ្ឍន៍សាកលវិទ្យាល័យភូមិន្ទកសិកម្ម ឱ្យកាន់តែមានការរីកចម្រើនឡើងបន្ថែមទៀត ក្នុងរយៈពេល១០ឆ្នាំនាពេលខាងមុខ ឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល។

ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមរំឭកជូនថា សាកលវិទ្យាល័យភូមិន្ទកសិកម្ម គឺជាគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមានភាតព្វកិច្ចបណ្តុះបណ្តាលបច្ចេកទេសកសិកម្មដ៏ធំមួយ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបានដើរតួជាប្រវត្តិសាស្ត្រ ក្នុងការផ្គត់ផ្គង់ធនធានមនុស្សគ្រប់កម្រិត ដើម្បីបម្រើការងារជាអ្នកបច្ចេកទេសកសិកម្ម និងរួមចំណែកក្នុងការអភិវឌ្ឍវិស័យកសិកម្មជាតិយើងគ្រប់កាលៈទេសៈ។ សាកលវិទ្យាល័យនេះបានប្រែក្លាយ និងបានវិវត្តខ្លួនប្រកបដោយភាពម្ចាស់ការធ្វើឱ្យមានការរីកចម្រើនជាបណ្តើរៗ ស្របតាមសម័យកាលចាប់តាំងពីបដិសន្ធិនាឆ្នាំ១៩៦៤មក ពោលគឺចាប់ផ្តើមបណ្តុះបណ្តាលដំបូងត្រឹមតែថ្នាក់ វិស្វករកសិកម្ម និងថ្នាក់បរិញ្ញាបត្រ ហើយរហូតមកដល់បច្ចុប្បន្ននេះ គឺមានសមត្ថភាពបណ្តុះបណ្តាល ថ្នាក់បរិញ្ញាជាន់ខ្ពស់ (Master

Degree) និងថ្នាក់បណ្ឌិត (PhD) ថែមទៀតផង។

អង្គពិធីទាំងមូលជាទីមេត្រី!

យោងតាមរបាយការណ៍ របស់ឯកឧត្តមសាកលវិទ្យាធិការ **ង៉ោ ប៊ុនថាន** បានបង្ហាញថា ក្នុងរយៈពេលជាង៣០ឆ្នាំកន្លងមកនេះ ជាពិសេសចាប់ពីត្រឹមឆ្នាំ២០០១មក សាកលវិទ្យាល័យភូមិន្ទកសិកម្មបានអនុវត្តតាមផែនការយុទ្ធសាស្ត្រលើកទី១ ឆ្នាំ២០០១-២០១០ និង ផែនការយុទ្ធសាស្ត្រលើកទី២ ឆ្នាំ២០១១-២០១៥ ដោយទទួលបានជោគជ័យប្រកបដោយផ្លែផ្កា និងសមិទ្ធផលធំៗ ជាច្រើនគួរកត់សម្គាល់ ជាពិសេសគឺ ការកសាងធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធសិក្សា មន្ទីរពិសោធន៍ ស្ថានីយ៍អនុវត្តន៍និងស្រាវជ្រាវ និងការទទួលស្គាល់លើឆាកអន្តរជាតិ។ ជាមួយនេះខ្ញុំសូមសម្តែងនូវមូលវិចារណ៍ប្រកបដោយភាពកក់ក្តៅ ព្រមទាំងការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំ មន្ត្រី សាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទកសិកម្មទាំងអស់ដែលបានតស៊ូប្តូរផ្តាច់រហូតសម្រេចបាននូវសមិទ្ធផលធំៗ ជាបន្តបន្ទាប់ក្នុងការកសាង និងអភិវឌ្ឍន៍ធនធានមនុស្ស សម្រាប់វិស័យកសិកម្មដ៏មានសក្តានុពលនេះ។ ប្រាកដណាស់ថា កិច្ចការនេះបានកើតមានឡើងពីការប្រមូលផ្តុំនូវបញ្ញាញាណ ស្មារតីសហការរួមគ្នា ការរិះរកនូវវិធានការ កាលានុវត្តភាពថ្មីៗប្រកបដោយសង្គតិភាពជាមួយនឹង គោលដៅយុទ្ធសាស្ត្រក្នុងវិស័យកសិកម្ម សំដៅលើកកម្ពស់ប្រសិទ្ធភាព និងរួមចំណែកសំខាន់ដល់ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យកសិកម្មដែលជាវិស័យអាទិភាពមួយរបស់រាជរដ្ឋាភិបាលដើម្បីរួមចំណែកបង្កើនល្បឿនដល់កំណើនសេដ្ឋកិច្ច និងអភិវឌ្ឍសង្គមជាតិប្រកបដោយចីរភាព។

ពិតណាស់ថា ការអភិវឌ្ឍប្រទេសជាតិឲ្យមានការរីកចម្រើនបាន ចាំបាច់យើងត្រូវមានធនធានមនុស្សគ្រប់គ្រាន់ ប្រកបដោយចំណេះដឹង ចំណេះធ្វើ កាយសម្បទាមាំមួន មានសីលធម៌ល្អ ចរិយាសម្បត្តិល្អ គុណធម៌ថ្លៃថ្លា និងចេះសាមគ្គីសហការរួមរស់និងធ្វើការជាមួយគ្នាដោយសុខសន្តិភាព ។ ដើម្បីទទួលបាននូវធនធានមនុស្សបែបនេះ យើងត្រូវតែខិតខំផ្តល់សេវាអប់រំដល់ប្រជាពលរដ្ឋគ្រប់រូប គ្រប់វ័យ តាមគ្រប់រូបភាពប្រកបដោយគុណភាពខ្ពស់ និងការទទួលខុសត្រូវ។ ជាងនេះទៅទៀត រាជរដ្ឋាភិបាលកម្ពុជាយើងយល់យ៉ាងច្បាស់ថា ការងារអភិវឌ្ឍន៍ធនធានមនុស្សគឺជាកត្តាស្នូលក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៥នៃរដ្ឋសភា ដែលជាមគ្គុទ្ទេសដ៏ច្បាស់លាស់សម្រាប់តម្រែតម្រង់សកម្មភាព របស់គ្រប់តួអង្គ អភិវឌ្ឍន៍ទាំងអស់ក្នុងគោលដៅបន្ត និងពង្រឹងកិច្ចអភិវឌ្ឍប្រកបដោយចីរភាពសម្រាប់រយៈពេលវែង ដើម្បីកំណើនសេដ្ឋកិច្ចជាតិ បន្តបង្កើតការងារ កាត់បន្ថយការធ្វើចំណាកស្រុក បែងចែកផលកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងធានាឱ្យបាននូវប្រសិទ្ធភាពនៃស្ថាប័នសាធារណៈនិងការគ្រប់គ្រងធនធានគ្រប់ប្រភេទ។



ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងពិធីបើក សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាង ផែនការយុទ្ធសាស្ត្ររយៈពេល១០ឆ្នាំ របស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម ២០១៧-២០២៦

ដោយឡែក យោងតាមបទអន្តរាគមន៍របស់លោក **ស្រី វុឌ្ឍី** ប្រធាននាយកដ្ឋានផែនការនិងស្ថិតិនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអគ្គនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា បានបង្ហាញឱ្យយើងឃើញថា នៅចំពោះមុខនេះ វិស័យកសិកម្មមានទិសដៅការងារមួយច្បាស់លាស់ដែលត្រូវសម្រេចឱ្យបានសម្រាប់ពហុប្រយោជន៍ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិឱ្យបានខ្លាំងក្លាបន្ថែមទៀត ក៏ដូចជាទិសដៅក្នុងការពង្រឹងគុណភាពអប់រំថ្នាក់ឧត្តមសិក្សាកម្ពុជា ឱ្យមានសមត្ថភាព និងគុណភាពអប់រំតាមនិយាមអន្តរជាតិ ដែលអាចប្រកួតប្រជែងក្នុងតំបន់ និងអន្តរជាតិបាន។ ផ្អែកលើបទអន្តរាគមន៍ទាំងពីរនេះ និង មតិយោបល់ល្អៗ ដែលនឹងទទួលបានពីការពិភាក្សាក្នុងអង្គសិក្ខាសាលានាពេល



សិក្ខាកាមអញ្ជើញចូលរួមក្នុងពិធីបើកសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាង ផែនការយុទ្ធសាស្ត្ររយៈពេល១០ឆ្នាំ របស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម ២០១៧-២០២៦

នេះ ខ្ញុំយល់ថា សាកលវិទ្យាល័យពិតជាអាចបង្កើតបាននូវផែនការយុទ្ធសាស្ត្ររយៈពេល១០ឆ្នាំរបស់ខ្លួនមួយ ដែលសមស្របឆ្លើយតបទៅនឹងគោលនយោបាយនិងយុទ្ធសាស្ត្ររបស់ឧត្តមសិក្សាជាតិ ដើម្បីបណ្តុះបណ្តាលធនធានមនុស្សដែលមានសមត្ថភាពគ្រប់គ្រាន់ ស្របតាមសេចក្តីត្រូវការសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម តាមគោលនយោបាយនិងផែនការយុទ្ធសាស្ត្ររបស់វិស័យកសិកម្មនាពេលបច្ចុប្បន្ន និងទៅអនាគតផងដែរក្នុងបរិបទនៃសាកលភាវូបនីយកម្ម។

**អង្គពិធីទាំងមូលជាទីមេត្រី!**

នៅក្នុងកាលៈទេសៈបច្ចុប្បន្ននេះ យើងបានដឹងហើយថា មនុស្សជិត៨០០ លាននាក់នៅតែទទួលរងនូវភាពអត់ឃ្លាន ហើយជិត២ពាន់លាននាក់ខ្វះអាហារូបត្ថម្ភដែលភាគច្រើននៃពួកគេ គឺជាស្ត្រី និងកុមារ។ ជាការឆ្លើយតប យើងមានគោលដៅប្រកបដោយមហិច្ឆតាថ្មីមួយមុនពេលយើងសម្លឹងឆ្ពោះទៅរកឆ្នាំ២០៣០ ក្នុងការលើកកម្ពស់ សន្តិសុខស្បៀង និងការលើកកម្ពស់វិស័យកសិកម្មប្រកបដោយចីរភាព។ ប៉ុន្តែយើងក៏ត្រូវទទួលស្គាល់អំពីទិដ្ឋភាពអវិជ្ជមានលើបរិស្ថាន និងសុខភាពមនុស្ស ការធ្លាក់ចុះគុណភាពដី ឬរហោស្ថានកម្ម ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ខ្ពស់ ការប្រែប្រួលធាតុអាកាស ការធ្លាក់ចុះតម្លៃកសិផល ការវិភាគទៅលើមុខរបរថ្មីៗ ការបាត់បង់ជីវចម្រុះភាពអត់ឃ្លាន កង្វះអាហារូបត្ថម្ភនៅតែកើតមានជាបន្ត។ នេះជាបញ្ហាគន្លឹះមួយដែលយើងត្រូវអនុវត្តការធ្វើពិពិធកម្មដំណាំ និងការបង្កើនជីវចម្រុះ ដើម្បីកសាងប្រព័ន្ធអេកូឡូស៊ីប្រកបដោយភាតរបរិស្ថាន និងធានានិរន្តរភាពធនធានដីកសិកម្មសម្រាប់រយៈពេលយូរអង្វែង។ ជាកត្តាសត្យានុម័ត ការរៀបចំផែនការយុទ្ធសាស្ត្ររយៈពេល១០ឆ្នាំ របស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម គួរពិចារណាទៅលើទិដ្ឋភាពរួមខាងលើនេះផងដែរ ។ ទន្ទឹមនឹងនេះ ខ្ញុំសូមឆ្លៀតយកឱកាសដ៏វិសេសវិសាលនេះ ដើម្បីផ្តល់ជូននូវចក្ខុវិស័យ និងអនុសាសន៍មួយចំនួនបន្ថែមទៀត ជាធាតុចូលសម្រាប់អង្គសិក្ខាសាលាពិភាក្សា ពិគ្រោះយោបល់ ក្នុងការកសាងផែនការយុទ្ធសាស្ត្រ១០ឆ្នាំ របស់សាកលវិទ្យាល័យ មានដូចតទៅ៖

ទី១. ត្រូវពង្រឹងការអប់រំ បណ្តុះបណ្តាលនិស្សិតគ្រប់កម្រិត រួមមានថ្នាក់បរិញ្ញាបត្រ បរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិតឱ្យមានចំណេះដឹងបច្ចេកទេសវិទ្យាសាស្ត្រច្បាស់លាស់ មានទស្សនៈទូលំទូលាយ មានសមត្ថភាពគ្រប់គ្រាន់អាចប្រកួតប្រជែងក្នុងទីផ្សារការងារទាំងក្នុងស្រុកនិងក្រៅស្រុកបាន។ ពិសេស ក្រោយពីបញ្ចប់ការសិក្សា និស្សិតអាចបង្កើតមុខរបរដោយខ្លួនឯង ធ្វើសេវាកម្ម ឬបង្កើតអាជីវកម្មផ្សេងៗពាក់ព័ន្ធនឹងវិស័យកសិកម្ម ផលិតកម្មកសិកម្ម ការថែរក្សាទុកដាក់ផលិតផល ការកែច្នៃផលិតផល និងការវេចខ្ចប់ជាដើម ដើម្បីបង្កើនតម្លៃបន្ថែម (Value Added) រួមទាំងការបង្កើតការងារថ្មីៗជូនយុវជនកម្ពុជាផងដែរ ដែលទាំងអស់នេះក៏ជាផ្នែកមួយនៃការរួមចំណែកអនុវត្តតាម គោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ផងដែរ។

ទី២. ត្រូវយកចិត្តទុកដាក់ខ្ពស់លើការកសាងធនធានសាស្ត្រាចារ្យ និងគ្រូបង្រៀនរបស់ខ្លួន ឱ្យមានជំនាញឯកទេសច្បាស់លាស់ មានចំណេះដឹងថ្មីៗទាន់សម័យ ព្រមទាំងមានកម្រិតសញ្ញាបត្រសមស្របទៅតាម ក្របខណ្ឌគុណវឌ្ឍន៍ជាតិដែលបានកំណត់ សម្រាប់អនុវត្តក្នុងបទដ្ឋានសាកលវិទ្យាល័យ។ ត្រូវបណ្តុះស្មារតី ទទួលខុសត្រូវសង្គម (Social Responsibility) ដល់សាស្ត្រាចារ្យនិងលោកគ្រូ អ្នកគ្រូរបស់យើងឱ្យបានខ្ពស់ មានន័យថាលោកគ្រូ អ្នកគ្រូត្រូវធ្វើជាគំរូល្អជាអ្នកបណ្តុះបណ្តាលធនធានមនុស្ស ជាអ្នកតម្រង់ទិសវិជ្ជាជីវៈរបស់យុវជនជំនាន់ថ្មី ធ្វើយ៉ាងណាឱ្យពួកគេទទួលបាននូវការអប់រំបណ្តុះបណ្តាលដ៏ល្អមួយ មានលក្ខណៈពេញលេញគ្រប់ជ្រុងជ្រោយច្បាស់លាស់ រួមទាំងជំនាញរឹង និង ជំនាញទន់គ្រប់បែបយ៉ាង ដើម្បីឱ្យពួកគេក្លាយខ្លួនទៅជាធនធានមនុស្សថ្មី ពលរដ្ឋល្អ សម្រាប់បន្តដឹកនាំនិងកសាងសេដ្ឋកិច្ច



ឯកឧត្ដមសាកលវិទ្យាធិការ ង៉ោ ប៊ុនថាន ក្នុងពិធីបើក សិក្ខាសាលាពិគ្រោះយោបល់លើសេចក្ដីព្រាង នៃការយុទ្ធសាស្ត្ររយៈពេល១០ឆ្នាំ របស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម ២០១៧-២០២៦

ជាតិនាពេលអនាគត ។

ទី៣. ត្រូវប្រែក្លាយសាកលវិទ្យាល័យភូមិន្ទកសិកម្ម ពីការគិតគូរតែលើការបណ្ដុះបណ្ដាលតែមួយមុខ ឱ្យទៅជាសាកលវិទ្យាល័យថ្មីមួយដែលយកចិត្តទុកដាក់ខ្ពស់លើការស្រាវជ្រាវជាចម្បង (Research University) និងការរួមចំណែកផ្ទេរបច្ចេកវិទ្យាកសិកម្មឱ្យដល់កសិករ តាមរយៈការបង្កើតឱ្យមានយន្តការផ្ទៃក្នុងសមស្របមួយ ដើម្បីលើកទឹកចិត្តដល់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូឱ្យចូលរួមយ៉ាងសកម្មក្នុងការស្រាវជ្រាវកសិកម្មគ្រប់ប្រភេទ ដូចជា ការស្រាវជ្រាវសម្រាប់អនុវត្ត (Apply Research) ការស្រាវជ្រាវបែបវិទ្យាសាស្ត្រ (Scientific Research) ឬការស្រាវជ្រាវដើម្បីរៀបចំគោលនយោបាយ (Policy Research) ជាដើម ។ ក្នុងនោះដែរ សាកលវិទ្យាល័យត្រូវកសាងឱ្យបាននូវ កម្មវិធី ឬ ផែនការស្រាវជ្រាវមួយ (Research Agenda) ដែលសមស្របទៅនឹងសភាពការណ៍វិវឌ្ឍន៍នៃសេដ្ឋកិច្ចជាតិ និងទៅតាមសេចក្ដីត្រូវការបច្ចេកទេសវិទ្យាសាស្ត្រ សម្រាប់ដោះស្រាយបញ្ហាប្រឈមនានាដែលបានកើតឡើងនាពេលបច្ចុប្បន្ននេះ និងនៅពេលខាងមុខ ។ ជាពិសេសត្រូវខិតខំសិក្សាស្រាវជ្រាវនវានុវត្តន៍និង ថ្នៃប្រឌិតកម្រិតខ្ពស់ បង្កើតជា កញ្ចប់បច្ចេកវិទ្យាវៃឆ្លាត (Smart Technology) សម្រាប់កសិករ និង ផលិតកររបស់យើងយកទៅអនុវត្ត។ ដើម្បីសម្រេចគោលដៅនេះ សាកលវិទ្យាល័យត្រូវយកចិត្តទុកដាក់ជំរុញការស្រាវជ្រាវនៅកម្រិតថ្នាក់បរិញ្ញាជាន់ខ្ពស់ (Master) និងថ្នាក់បណ្ឌិត(PhD) ឱ្យបានច្រើនដោយគិតគូរទៅលើគុណភាពជាចម្បង និងឆ្លើយតបទៅនឹងមូលបញ្ហាទាំងឡាយដូចបានរៀបរាប់ខាងលើ។

ទី៤. ត្រូវខិតខំបន្តកសាងហេដ្ឋារចនាសម្ព័ន្ធសិក្សាឱ្យបានគ្រប់គ្រាន់ សម្រាប់បម្រើសេចក្ដីត្រូវការក្នុងការសិក្សារៀនសូត្រ ការអនុវត្តន៍ជាក់ស្ដែង និង ការស្រាវជ្រាវ រួមមានបណ្ណាល័យ ឧបករណ៍សម្ភារបង្រៀន មន្ទីរពិសោធន៍ ស្ថានីយ៍ដំណាំ កសិដ្ឋានចិញ្ចឹមសត្វនិងចិញ្ចឹមត្រីជាដើម។ ក្រៅពីនេះ ត្រូវខិតខំកែលម្អហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដែលទ្រទ្រង់ដល់សុខុមាលភាពនិងជីវភាពរស់នៅរបស់និស្សិត រួមមានដូចជាអន្តេវាសិកដ្ឋាន កីឡាដ្ឋានគ្រប់ប្រភេទ សួនច្បារ អាហារដ្ឋានប្រកបដោយអនាម័យ ហាងលក់សម្ភារសិក្សាផ្សេងៗ។ ត្រូវខិតខំបន្តកៀរគររកមូលនិធិពីប្រភពផ្សេងៗ ដើម្បីកសាងអាគារសិក្សាថ្មីៗបន្ថែម ជំនួសអាគារសិក្សាចាស់ៗ ដែលមានសភាពទ្រុឌទ្រោមសំដៅធ្វើយ៉ាងណាឱ្យបរិស្ថាននៃការសិក្សារៀនសូត្រប្រកបដោយផាសុខភាព និង ទាក់ទាញការចាប់អារម្មណ៍ពីសំណាក់សិស្ស និស្សិត ឱ្យចង់ចូលសិក្សានៅក្នុងសាកលវិទ្យាល័យយើង ។

ទី៥. ត្រូវកែលម្អនិងអភិវឌ្ឍកម្មវិធីសិក្សា ឱ្យមានភាពទាន់សម័យស្របតាមតម្រូវការទីផ្សារ ឆ្លើយតបនឹងគោលនយោបាយអភិវឌ្ឍន៍កសិកម្មជាតិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ដែលបានកំណត់ដោយរាជរដ្ឋាភិបាល។ ក្រៅពីកម្មវិធីសិក្សាល្អ ការងារចាំបាច់ផ្សេងៗទៀតត្រូវតែធ្វើឱ្យបានល្អប្រសើរផងដែរ ដូចជា ខ្លឹមសារមេរៀននៃមុខវិជ្ជានីមួយៗត្រូវតែមានលក្ខណៈស៊ីជម្រៅនិងរៀបរៀងឡើងស្របតាមមូលបញ្ហា (Problem Based Approach) វិធីសាស្ត្របង្រៀនត្រូវតែទាន់សម័យ (Update) ត្រូវបង្វឹកនិស្សិតឱ្យស្ទាត់ជំនាញក្នុងការសិក្សាស្រាវជ្រាវ ចង់ចេះចង់ដឹងបង្កើតបានជាវប្បធម៌ស្រាវជ្រាវដ៏ល្អមួយក្នុងសាកលវិទ្យាល័យ ហើយទ្រឹស្ដីត្រូវផ្សាភ្ជាប់និងការអនុវត្តន៍ ព្រមទាំងត្រូវផ្ដល់ឱកាសឱ្យនិស្សិតមានពេលវេលាគ្រប់គ្រាន់ក្នុងការធ្វើកម្មសិក្សាជាដើម ជាពិសេសការរំកិលសេវាកម្មបច្ចេកទេសឱ្យទៅដល់មជ្ឈដ្ឋានកសិករផ្ទាល់តែម្ដង។

ទី៦. ត្រូវយកចិត្តទុកដាក់ខ្ពស់លើការងារអភិបាលកិច្ចល្អ (Good Governance) នៅគ្រប់កម្រិត ទាំងកម្រិតសាកលវិទ្យាល័យ មហាវិទ្យាល័យ រហូតដល់ការិយាល័យឬ

ដេប៉ាតឺម៉ង់។ ត្រូវយកចិត្តទុកដាក់ ធ្វើឱ្យបានលឿន មានប្រសិទ្ធភាព និង ទទួលខុសត្រូវខ្ពស់លើសេវាកម្មទាំងអស់របស់និស្សិត និង អតិថិជនគ្រប់ៗរូប។

ទី៧. ត្រូវបន្តយកចិត្តទុកដាក់លើកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ ជាពិសេសត្រូវបង្កើតឱ្យមានយន្តការភ្ជាប់ទំនាក់ទំនងជាមួយអង្គភាពជំនាញតាមវិស័យ ភាពជាដៃគូរវាងសាកលវិទ្យាល័យនិងវិស័យឯកជន PPP ( Public Private Partnership ) ដើម្បីផ្ដល់ឱកាសដល់សាស្ត្រាចារ្យនិងនិស្សិតបានសិក្សារៀនសូត្រការងារជាក់ស្ដែង បន្ថែមពីស្ថាប័នរដ្ឋ វិស័យឯកជន ហើយវិស័យឯកជនក៏ត្រូវចូលរួមចំណែកក្នុងការកសាងធនធានមនុស្ស ក៏ដូចជាទទួលបានបច្ចេកទេស និងរបកគំហើញថ្មីៗ ពីសាកលវិទ្យាល័យ ទៅវិញទៅមកផងដែរ។ ទន្ទឹមនឹងនេះក៏ត្រូវជំរុញការធ្វើអន្តរជាតូបនីយកម្ម ( Internationalization ) ពោលគឺផ្សារភ្ជាប់រវាងសាកលវិទ្យាល័យយើងទៅនឹងសហគមន៍សាកលវិទ្យាល័យអន្តរជាតិ ជាពិសេសក្នុងតំបន់ តាមរយៈការបញ្ជូននិស្សិតនិងសាស្ត្រាចារ្យទៅសាកលវិទ្យាល័យដៃគូ និង ការទទួលយកសាស្ត្រាចារ្យ និង និស្សិតពីសាកលវិទ្យាល័យដៃគូមកវិញ។ ដើម្បីធ្វើបានដូចនេះយើងចាំបាច់ត្រូវពង្រឹងសមត្ថភាពភាសាបរទេសរបស់យើងឱ្យបានល្អប្រសើរ ហើយក្នុងផែនការយុទ្ធសាស្ត្រថ្មីនេះគួរបង្កើតឱ្យមានកម្មវិធីសិក្សាខ្លះដំណើរការជាភាសាបរទេសដែលអាចពង្រឹងសមត្ថភាពនិស្សិតកម្ពុជាយើងលើឆាកអន្តរជាតិ និងអាចស្រូបបាននូវនិស្សិតបរទេសមករៀនជាមួយយើងផងដែរ។

### អង្គពិធីទាំងមូលជាទីមេត្រី!

ជាកត្តាសត្យានុម័ត និងអត្តនោម័ត ឧត្តមភាពប្រកួតប្រជែងរបស់ប្រជាជាតិមួយ គឺអាស្រ័យជាសំខាន់លើកត្តាធនធានមនុស្សដែលមានចំណេះដឹងខ្ពស់ទូលំទូលាយប្រកបដោយភាពច្នៃប្រឌិត និងជំនាញច្បាស់លាស់។និយាយរួមតម្លៃនៃការអប់រំដោយប្រាកដប្រជា គឺនៅតែជាកត្តា ឬមធ្យោបាយសម្រាប់អភិវឌ្ឍបុគ្គលភាព និងអភិវឌ្ឍសង្គមសេដ្ឋកិច្ចជាតិជានិច្ច។

ជាថ្មីម្ដងទៀត ខ្ញុំជឿជាក់ថាការពិភាក្សារបស់អង្គសិក្ខាសាលារយៈពេលពីរថ្ងៃនេះ ប្រាកដជាឆ្លើយតបទៅនឹងយុទ្ធសាស្ត្រទាំងឡាយដូចដែលខ្ញុំបានរៀបរាប់ខាងលើ ពិសេសផែនការមេអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០៣០ ក្រោមចក្ខុវិស័យ



ប្រកបដោយតថភាពពោលគឺធ្វើយ៉ាងណាដើម្បីប្រែក្លាយកសិកម្មកម្ពុជា ជាកសិកម្មទំនើប មានលក្ខណៈប្រកួតប្រជែងប្រកបដោយបរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាពដែលចូលរួមចំណែកក្នុងការផ្ដល់សន្តិសុខ និងសុវត្ថិភាពស្បៀង ព្រមទាំងអាហារូបត្ថម្ភ សម្រាប់វិបុលភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់សាកលវិទ្យាល័យក្នុងការកសាងផែនការយុទ្ធសាស្ត្រ ១០ឆ្នាំនេះ និងសូមអរគុណចំពោះការចូលរួមរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់ដែលបានចំណាយពេលវេលាចូលរួមក្នុងអង្គសិក្ខាសាលានេះក្នុងស្មារតីស្ថាបនា និងផលប្រយោជន៍រួម។

ជាទីបញ្ចប់ ជាមួយនឹងការប្រកាសបើកអង្គសិក្ខាសាលាពិគ្រោះយោបល់ ស្ដីពីការកសាងផែនការយុទ្ធសាស្ត្ររយៈពេលវែង១០ឆ្នាំ របស់សាកលវិទ្យាល័យភូមិន្ទកសិកម្មនាពេលនេះ ខ្ញុំសង្ឃឹមថាអង្គសិក្ខាសាលានឹងប្រព្រឹត្តទៅប្រកបដោយលទ្ធផលល្អប្រសើរ នឹងនាំមកនូវមតិយោបល់ និងបទពិសោធន៍ថ្មីៗថែមទៀត ដើម្បីប្រមូលធាតុចូលទាំងអស់ យកមករៀបចំធ្វើផែនការយុទ្ធសាស្ត្រ ឱ្យមានលក្ខណៈសមស្របគ្រប់ជ្រុងជ្រោយឆ្លើយតបទៅនឹងការចង់បាន ចង់ឃើញរបស់យើងទាំងអស់គ្នា ទៅតាមការវិវត្តរីកចម្រើននារយៈពេល១០ឆ្នាំខាងមុខនេះ។ខ្ញុំសូមប្រសិទ្ធពរជ័យ ជូនឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ អន្តរជាតិ សមាជិក សមាជិកានៃអង្គសិក្ខាសាលាទាំងមូល សូមទទួលនូវសិរីសួស្ដី ជ័យមង្គល វិបុលសុខគ្រប់ប្រការ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**

# ដំណាំមន

# MULBERRY

ដោយ៖ លោក ខាន់ សំបាន, លោក ឃិន ច័ន្ទសុធី
នាយកដ្ឋានដំណាំឧស្សាហកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

បន្តពីទស្សនាវដ្តីកសិកម្ម លេខ ៦២

### ៨.១ ប្រភេទនៃការតាក់តែង



| រាងដូចកណ្តាប់ដៃ | | រាងមិនដូចកណ្តាប់ដៃ |
|---|---|---|
| ធ្វើឱ្យភ្នែកមិនទាន់ដុះចាប់ផ្តើមដុះ នៅក្បែរគល់ ពន្លកតិចតែរឹងមាំងាយស្រួលពត់រាង និងគ្រប់គ្រងសត្វល្អិតចង្រៃ | ពន្លកសម្រាប់ដុះជាមែក កន្លែងដែលត្រូវកាត់ចំនួនរបស់មែកដុះលូតលាស់សម្រាប់អនុវត្តការដាំដុះ | ភ្នែកធម្មតា ១០ ស.ម ខាងលើគល់មែកច្រើនតែខ្សោយពិបាកនឹងកំណត់រាង |

### ៨.២ គោលការណ៍កែសម្រួលដើមដែលនៅសល់

| ការកាត់វែង (ទុក ៣-៥ម) | កាត់ខ្លី (ក្បែរគល់) |
|---|---|
| មែកនៃដើមនៅខ្ចីមែកមានទំហំធំមែកផ្នែកខាងលើ<br>មែកនៃដើមដែលខ្លាំង | មែកនៃដើមចាស់មែកមានទំហំតូចៗមែកនៅខាងក្រោម<br>មែកនៃដើមខ្សោយ |

### ៨.៣ វិធីសាស្ត្រកាត់មែក

ដើម្បីកែសម្រួលមែកដែលនៅសល់ មែកត្រូវកាត់ឱ្យបានសមស្របដូចខាងក្រោម៖




វិធីកាត់តែងមែកកម្ពស់ខុសគ្នា




○ ៖វិធីកាត់ដែលល្អ , × ៖វិធីកាត់គួរជៀសវាង

## ៩. ការប្រើប្រាស់ជី

បរិមាណ និងភាពញឹកញាប់នៃការប្រើប្រាស់ជីអាស្រ័យលើការលូតលាស់របស់ដើមមន ការតាក់តែងមែក វិធីសាស្ត្រប្រមូលផល ទឹកភ្លៀង ប្រភេទដី និងលក្ខខ័ណ្ឌអាកាសធាតុ។

### ៩.១ តំបន់ត្រូពិច: បរិមាណជី និងវិធីសាស្ត្រប្រើប្រាស់ត្រូវបានបង្ហាញដូចខាងក្រោម:

- នៅដំណាក់កាលទីI: ត្រូវប្រើ ៥០-៥០-៥០ គីឡូក្រាម/ហិកតា
- នៅដំណាក់កាលទីII: ត្រូវប្រើ ៥០-០-០ គីឡូក្រាម/ហិកតា
- នៅដំណាក់កាលទីIII: ៥០-៥០-៥០ គីឡូក្រាម/ហិកតា
- នៅដំណាក់កាលទីIV: ៥០-០-០ គីឡូក្រាម/ហិកតា
- នៅដំណាក់កាលទីV: ៥០-០-០ គីឡូក្រាម/ហិកតា




### ៩.២ វិធីសាស្ត្រប្រើប្រាស់

- ការបាច: នៅចំការមនដែលមានដីរាបស្មើ ជីត្រូវបានគេបាចនៅចន្លោះគុម្ពនៃដើមមន។ ដីនិងជីត្រូវលាយជាមួយគ្នាដោយប្រើចប។ វិធីសាស្ត្រនេះសមស្របសម្រាប់មនពេញវ័យ។



ការបាចជុំវិញៈ សមស្របសម្រាប់ដីជំរាល និងមននៅតូច។ ត្រូវជីករណ្ដៅរាក់ៗក្បែរគល់មនរួចដាក់ជីក្នុងរណ្ដៅនោះនិងកប់ដីពីលើ។




សារធាតុសរីរាង្គៈ ជីកំប៉ុស្តត្រូវដាក់ក្នុងរណ្ដៅដាក់នៅចន្លោះនៃជួររបស់មន។ ចំបើងនិងជីស្រស់យកពីរុក្ខជាតិតូចៗ ឬស្លឹកឈើ អាចដាក់នៅពីលើរណ្ដៅជី កំប៉ុស្តនោះ។




## ១០. ការគ្រប់គ្រងទឹក

កម្ពស់ទឹកភ្លៀងសមស្របប្រចាំថ្ងៃគឺ ៤-៥ម.ម នៅរដូវដុះលូតលាស់។ ការស្រោចស្រពត្រូវការអនុវត្តប្រសិនបើកម្ពស់ទឹកភ្លៀងទាបជាងកំរិតកំណត់។ ការស្រោចស្រពជាមធ្យមពី ២០០-២៥០t/ha រៀងរាល់ ៤-៥ថ្ងៃម្ដង។ ការប្រើគម្របដីដោយសារធាតុសរីរាង្គគ្របដីអាចកាត់បន្ថយការរំហួតទឹក និងបង្កើនវន្ទសម្រាប់ផ្ទុកទឹកនៅក្នុងដីបាន។

## ១១. ការគ្រប់គ្រងស្មៅ និងវិធានការការពារ

ស្មៅប្រជែងស្រូបយកសារធាតុចិញ្ចឹម ពន្លឺ និងទឹកពីដំណាំមន។ វិធានការគីមី វិធានការមេកានិច និងវិធានការក្សេត្រសាស្ត្រ ត្រូវបានប្រើដើម្បីកំចាត់ស្មៅចង្រៃ ហើយជំរើសនៃការប្រើគឺអាស្រ័យលើកត្តាក្នុងតំបន់។

**១១.១ វិធានការគីមីៈ** ថ្នាំសម្លាប់ស្មៅត្រូវបានបាញ់ផ្នែកខាងលើនៃផ្ទៃដីដើម្បីការពារកុំឱ្យស្មៅដុះ ឬអាចប្រើដោយផ្ទាល់លើស្មៅកំពុងលូតលាស់ ប៉ុន្តែភាពចាំបាច់បំផុតត្រូវការពារកុំឱ្យថ្នាំប៉ះស្លឹកមន។

**១១.២ វិធានការក្សេត្រសាស្ត្រៈ** ចំបើង និងសារធាតុសរីរាង្គផ្សេងៗ ត្រូវបានដាក់គ្របផ្ទាល់លើដីដើម្បីការពារកុំឱ្យស្មៅដុះដោយសារស្មៅពុំអាចស្រូបយក ពន្លឺព្រះអាទិត្យនោះបាន។ វិធីនេះជួយបង្កើតមមោកដល់ដី និងសមស្របបំផុតសម្រាប់ដីជម្រាល។ ប្រសិនបើមានសត្វល្អិតចង្រៃនៅក្នុងគំរបដីនេះយើងអាចប្រើថ្នាំសម្លាប់សត្វល្អិតបាន។

## ១២. ការប្រមូលផល

មានវិធីសាស្ត្រ២យ៉ាងក្នុងការប្រមូលផលស្លឹកមន។ ជម្រើសនីមួយៗអាស្រ័យលើលក្ខខណ្ឌធម្មជាតិ វិធីសាស្ត្រចិញ្ចឹមដង្កូវនាង និងការចំណាយលើពលកម្មពេលប្រមូលផល។ល។ ការជ្រើសរើសត្រួយ និងស្លឹកបន្ទាប់ពីត្រួយក៏ជាកត្តាសំខាន់សម្រាប់ចិញ្ចឹមដង្កូវនៅតូចៗ (ដំណាក់កាលទីមួយ) រីឯស្លឹកបន្តបន្ទាប់សម្រាប់ដង្កូវនៅដំណាក់កាលបន្តទៀតរហូតដល់ស្លឹកចាស់សម្រាប់ចិញ្ចឹមដង្កូវពេញវ័យនៅដំណាក់កាលទី៥មុនវាឡើងសំបុក។

១២.១ វិធីសាស្ត្របេះស្លឹក: វិធីសាស្ត្រនេះពិតជាត្រូវការចំណាយកម្លាំងច្រើន។ ការបេះស្លឹកត្រូវបានគេធ្វើឡើងនៅរដូវភ្លៀងធ្លាក់ និងរដូវរំហើយ និងការបេះមែកត្រួយនៅកំឡុងរដូវស្លឹកឈើលាស់ដែលជារដូវចិញ្ចឹមដង្កូវនាង។ វិធីសាស្ត្រពិសេសដើម្បីបេះស្លឹកមនគឺកាំបិតជាប់ម្រាមដៃសម្រាប់កាត់ស្លឹក និងមែកស្លឹកទាំងមូល។




១២.២វិធីសាស្ត្រកាត់យកមែក:វិធីសាស្ត្រនេះត្រូវបានគេណែនាំឱ្យអនុវត្តព្រោះវាមិនចំណាយកម្លាំងច្រើន។ការប្រមូលផលអាស្រ័យលើរដូវកាលនៃការចិញ្ចឹមដង្កូវនាង និងវិធីសាស្ត្រ លក្ខខ័ណ្ឌសរីរៈរបស់មន ប្រសិទ្ធភាពនៃការប្រើពលកម្ម និងការដុះលូតលាស់ពន្លកត្រួយថ្មី។



១២.៣ វិធីសាស្ត្រកាត់តែងមែកសម្រាប់កូនដង្កូវទើបញាស់

ស្លឹកខ្ចីទន់លូតលាស់កំឡុងពេលរដូវភ្លៀង។ ដើម្បីផលិតស្លឹកខ្ចីដែលមានគុណភាពសម្រាប់ដង្កូវនាងទើបញាស់នៅរដូវរំហើយគឺជាការចាំបាច់មួយត្រូវអនុវត្តតាមបច្ចេកទេស។ នេះគឺជាការសំខាន់ដើម្បីធានាបាននូវសំបុកដង្កូវនាងដែលមានទិន្នផលល្អ។ វិធីនេះអនុវត្តតែនៅតំបន់ក្តៅបង្គួរតែប៉ុណ្ណោះ។

**វិធីសាស្ត្រកាត់ចុងត្រួយ**

១. មែកមនត្រូវកាត់យ៉ាងហោចណាស់ ២ទៅ៣ខែមុនចិញ្ចឹមដង្កូវនាង

២. នៅពេលត្រួយខ្ចីលាស់បានប្រហែល ១៥ស.ម ត្រូវចាប់ផ្តើមកាត់

៣. កាត់ពន្លកត្រួយ១៥ស.ម ខាងលើមែក។ បេះស្លឹកពាក់កណ្តាលផ្នែកខាងលើ ចំណែកពាក់កណ្តាលនៃផ្នែកខាងក្រោមទុក។

៤. ពេលវេលាសមស្របសម្រាប់អនុវត្តវិធីនេះគឺនៅ ២០-២៥ថ្ងៃ មុនពេលដង្កូវនាងឡើងសំបុក នៅរដូវភ្លៀងឬ ៣០-៣៥ថ្ងៃ មុនពេលឡើងសំបុកនៅរដូវប្រាំង។

៥. បន្ទាប់ពីនោះ២ឬ៣ថ្ងៃ ពន្លកចំហៀងនឹងដុះចេញជាច្រើនដែលអាចសមស្របសម្រាប់កូនដង្កូវទើបញាស់។

៦. បន្ទាប់ពីប្រមូលផល មែកត្រូវបានកាត់ដល់គល់ និងត្រូវដាក់ជីដល់មន។

៧. ដំណាំមនប្រហែល៥០ដើមមនអាចចិញ្ចឹមដង្កូវនាងបាន១ប្រអប់






## ១៣.ប្រមូលផលនៅតំបន់ត្រូពិច និងការកាត់តែងមែក

នៅភាគច្រើននៃតំបន់ត្រូពិច ស្លឹកមនត្រូវបានប្រមូលផលតាមរយៈការបេះជាបន្តពេញមួយឆ្នាំ។ ការបេះបន្តបែបនេះធ្វើឱ្យស្លឹកមិនមានគុណភាព និងចំណាយពលកម្មច្រើន។ ការប្រមូលផលមែកមិនត្រូវបានគេទទួលយកទូលំទូលាយទេ។

### ១៣.១ ចាប់ពីដាំរហូតដល់ពេលប្រមូលផលលើកដំបូង:

ខាងក្រោមនេះបង្ហាញពីការលូតលាស់ដំបូងរបស់ដំណាំមន រហូតដល់ពេលប្រមូលផលលើកដំបូង។ នៅដំណាក់កាលនេះ មនលូតលាស់ដល់ចំណុចកំពូល និងប្រព័ន្ធដំណាំចំរុះ ត្រូវបានគេអនុវត្ត។

- បន្ទាប់ពីដាំបាន៦ខែមនដុះលូតលាស់និងចាប់ផ្តើមបែកមែក
- នៅអាយុ ៩ខែបន្ទាប់ពីដាំ អាចប្រមូលស្លឹកមួយចំនួនសម្រាប់ចិញ្ចឹមដង្កូវនាង កាត់ផ្នែកខាងចុងដើម្បីបង្កើនការលូតលាស់ត្រួយ។
- នៅអាយុ ១១ខែបន្ទាប់ពីដាំ ប្រមូលផលស្លឹកពីមែកបន្ទាប់
- នៅអាយុ ១៥ខែបន្ទាប់ពីដាំប្រមូលផលមែកទីបី
- បន្ទាប់ពីប្រមូលផលអស់ត្រូវកាត់តែងមែក និងបន្ទាប់ពីកាត់តែងមែករួច ស្លឹកអាចប្រមូលផលបាននៅរយៈពេល

២-៣ខែ ម្ដង។

### ១៣.២ វិធីសាស្ត្រដំណាំចំរុះ

ការប្រើវិធីនេះអាស្រ័យលើទំហំសមស្របរបស់ចំការដំណាំមន។

### ១៣.៣ ការប្រមូលផល

តារាងខាងក្រោមបង្ហាញពីចំការនីមួយៗត្រូវបានកាត់អាស្រ័យលើតម្រូវការចិញ្ចឹមដង្កូវនាង។ ចម្ការដែលបានកាត់ត្រូវការរយៈពេល ២-៣ខែដើម្បីដុះឡើងវិញ។

| កូនស្រែ | ទី១ | ទី២ | ទី៣ | ទី៤ | ទី៥ | ទី៦ | ទី៧ | ទី៨ | ទី៩ | ទី១០ | ទី១១ | ទី១២ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| III | | | | | | | | | | | | |
| III | | | | | | | | | | | | |
| IV | | | | | | | | | | | | |
| | | | | | | | | | | | | |

## ឯកសារយោង


១. គង់ សំអឿន, ២០១២.របាយការណ៍វឌ្ឍភាពស្ដីពីលទ្ធផលនៃការអនុវត្តគម្រោងគាំទ្រការស្ដារឡើងវិញវិស័យសូត្រនៅកម្ពុជា

២. គង់ សំអឿន, ២០១០.របាយការណ៍សកម្មភាពអនុវត្តការងារគម្រោងគាំទ្រការស្ដារឡើងវិស័យសូត្រនៅកម្ពុជា

៣. Dr. Sung Gyoo Byung, 2013. Sericultural & Apicultural Materials Division Department of Agricultural Biology, National Academy of Agricultural Science, RDA, Republic of Korea

៤. Alan Backingham,2010. Grow Fruit: Gardens, Yards, Bolconies, Roof terraces, page 162

៥. FAO Agricultural Services Bulletin 80,1990. Sericulture training manual

៦. FAO Agricultural Services Bulletin 73/2,1992. Silkworm rearing

៧. www.en.wikipedia.org/wiki/Morus_( Plant ), 29 August 2014 at 9:40am

៨. www.crfg.org/pubs/ff/mulberry.html, 9 September 2014 at 4:20pm






# ការចិញ្ចឹមដង្កូវនាង

# SILKWORM REARING



ដោយ៖ លោក ខាន់ សំបាន, លោក ឃិន ច័ន្ទសុធី
នាយកដ្ឋានដំណាំឧស្សាហកម្មនៃអគ្គនាយកដ្ឋានកសិកម្ម

**បន្តពីទស្សនាវដ្ដីកសិកម្មលេខ៦២**

### ៥.២.១ ម៉្សៅក្លរ

ការប្រើប្រាស់ម៉្សៅក្លរីនសម្រាប់សម្លាប់មេរោគនិងបាក់តេរីនៅក្នុងបន្ទប់ចិញ្ចឹមដង្កូវនាង គឺគេបាចម៉្សៅក្លរីន ក្នុងបន្ទប់ចិញ្ចឹម ដោយបិទទ្វារ និងបង្អួចនៃបន្ទប់រយៈពេល១ថ្ងៃ ដើម្បីកុំឱ្យជាតិហ្គាសដែលភាយចេញពីក្លរីនភាយ ចេញមកក្រៅដែលធ្វើឱ្យបាត់បង់ប្រសិទ្ធភាពក្នុងការកំចាត់មេរោគនិងបាក់តេរី បន្ទាប់មកទើបចំហរបង្អួចដើម្បីឱ្យខ្យល់បរិសុទ្ធចូលមក និងសម្អាតបន្ទប់ មុនពេលចាប់ផ្ដើមចិញ្ចឹមដង្កូវនាង ក៏ប៉ុន្តែការប្រើម៉្សៅក្លរីនយើងពិបាកដឹងពីអត្រាភាគរយនៃជាតិក្លរីន ដូច្នេះគួប្រើម៉្សៅក្លរីនត្រឹមតែ១%បានហើយ។

### ៥.២.២ សូលុយស្យុងក្លរ

ការបាញ់សូលុយស្យុងក្លរីន១% ដោយប្រើបរិមាណសូលុយស្យុងក្លរីន ២២៥ សម$^3$ ក្នុងក្រឡាផ្ទៃ១ម$^2$ នៃបន្ទប់ចិញ្ចឹមសម្រាប់សម្លាប់មេរោគ និងបាក់តេរីក្នុងបន្ទប់ចិញ្ចឹម ដោយប្រើរយៈពេលពីកន្លះម៉ោងទៅ មួយម៉ោង ព្រមជាមួយគ្នានេះដែរត្រូវបិទបន្ទប់ឱ្យជិត និងមិនឱ្យត្រូវពន្លឺថ្ងៃ បន្ទាប់មកទើបសំអាតបន្ទប់ ហើយឱ្យខ្យល់ស្អាតចេញចូលមុនពេលចាប់ផ្ដើមចិញ្ចឹម។

### ៥.២.៣ សូលុយស្យុងហ្វ័រម៉ាលីន

ការបាញ់សូសុយស្យុងហ្វ័រម៉ាលីន២%ដោយប្រើបរិមាណសូលុស្យុងហ្វ័រម៉ាលីន១៨សម$^3$ក្នុងក្រឡាផ្ទៃ១ម$^2$ នៃបន្ទប់ចិញ្ចឹម សម្រាប់សម្លាប់ មេរោគ និងបាក់តេរី ក៏ប៉ុន្តែ ហ្វ័រម៉ាលីនជាសារធាតុគីមីខ្លាំងវាអាចសម្លាប់ទាំងប្រភេទវីរុសទៀតផង ដូច្នេះពេលដែលគេប្រើ ហ្វ័រម៉ាលីន គេត្រូវបិតទ្វារ បង្អួច ឱ្យជិតក្នុងរយៈពេល២៤ ម៉ោងមុន នឹងចំហរទ្វារបង្អួចដោយទុកតែទ្វារ និងបង្អួចសំណាញ់ឱ្យខ្យល់ស្អាតចេញចូលរយៈពេល១០ថ្ងៃ យ៉ាងតិចមុនចាប់ផ្ដើមចិញ្ចឹមដង្កូវនាង។

## ៦. ការសំអាតធ្នើ និងកន្លែងចិញ្ចឹមដង្កូវនាង

### ៦.១ ពេលវេលានៃការសម្អាតធ្នើចិញ្ចឹម

វាគឺជាការងារចាំបាច់ ដើម្បីសម្អាតនូវពពួកកាកសំណល់ ធ្វើឱ្យវិនាសដល់ដង្កូវនាងមានដូចជា ស្លឹក លាមក ដង្កូវងាប់ ។ល។ ដែលមានច្រើននៅកន្លែងចិញ្ចឹម។ ការសម្អាតទាមទារនូវសណ្ដាប់ធ្នាប់ដើម្បីការពារដង្កូវពីដំណក់ឧស្ម័ន និងវត្ថុមានភ្នាក់ងារបង្កជម្ងឺនៅកន្លែងចិញ្ចឹម។ ការសម្អាតត្រូវបានធ្វើមុនពេលដង្កូវនាងចាប់ផ្ដើមសក និងបន្ទាប់ពីសក អំឡុងពេលវ័យកណ្ដាលរបស់ដង្កូវ។ ជាទូទៅការធ្វើអនាម័យកន្លែងចិញ្ចឹមត្រូវបានអនុវត្តន៍តាំងពី មុនអំឡុងពេលសក និងពេលបន្តបន្ទាប់រហូតដល់ក្រោយពេលសក នៅ ដំណាក់កាលទី១ សកដំណាក់កាលទី២ និង សកដំណាក់កាលទី៣ ពីព្រោះស្លឹកមនដែលផ្ដល់ជាចំណីមានការកើនឡើងច្រើន ជាហេតុធ្វើឱ្យកំទេចស្លឹកដែលធ្វើឱ្យវិនាស និង លាមករបស់ដង្កូវនាងត្រូវបានកើនឡើង។ ដូច្នេះគឺជាការណែនាំដែលការធ្វើអន្តរកាលសម្អាតកន្លែងចិញ្ចឹមត្រូវបានអនុវត្តន៍អំឡុងពេល ដង្កូវនាង ដំណាក់កាលទី៣។

### ៦.២ របៀបសំអាតធ្នើ ឬកញ្រ្ចែងចិញ្ចឹម

ជំហានជាច្រើនក្នុងការធ្វើអនាម័យទំនើឬកញ្រ្ចែងកន្លែងចិញ្ចឹមដង្កូវនាងមានដូចតទៅ៖ ដំបូងយើងក្រាលសំណាញ់

អនាម័យពីលើទំនើ ឬកញ្ច្រែងដោយដាក់ស្លឹកមនស្រស់ពីលើដើម្បីឲ្យដង្កូវនាងវាឡើងមកស៊ីពីព្រោះដង្កូវនាង វាពុំស៊ីស្លឹកចាស់ដែលសល់ទេ បន្ទាប់ពីដង្កូវនាងឡើងមកលើសំណាញ់អស់មកទើបយើងលើកយកសំណាញ់និងដង្កូវនាងប្ដូរទៅកន្លែងផ្សេង(ទំនើ ឬកញ្ច្រែងថ្មី) ទើបយើងសំអាតទំនើឬកញ្ច្រែងចាស់។ ចំពោះករណីការចិញ្ចឹមមានចំនួនច្រើន បន្ទាប់ពីបានផ្ទេរដង្កូវនាងចេញទំនើត្រូវបាចផេះអង្កាមពីលើទំនើចាស់ដើម្បីឱ្យកំទេចស្លឹកដែលនៅសល់រលួយ និងលាមកដង្កូវនាង វានឹងស្ងួតទើបសំអាតជាក្រោយ។





## ៧. ដង់ស៊ីតេក្នុងការចិញ្ចឹម

ភាពឯកសណ្ឋានភាពនៃការលូតលាស់របស់ដង្កូវ អាស្រ័យលើដង់ស៊ីតេនៃការចិញ្ចឹមផងដែរ។ ដង់ស៊ីតេខ្ពស់ ក្នុងមួយកន្លែងនោះជាលទ្ធផលដង្កូវនាងខ្វះចំណី ដូច្នេះពន្យាការលូតលាស់របស់ដង្កូវ។ ដង់ស៊ីតេចិញ្ចឹមទាក់ទងផងដែរទៅនឹងភាពដែលប្រើប្រាស់ជាប្រយោជន៍នៃភាពងាយស្រួលក្នុងការចិញ្ចឹមរួមមាន ឧបករណ៍សម្ភារ និង កម្មករផងដែរ។ ដង់ស៊ីតេខ្ពស់នៃការចិញ្ចឹមគឺអាចធ្វើបានដើម្បីបង្កើនទ្រង់ទ្រាយចិញ្ចឹមក្នុងមួយកន្លែង ដែល ទាមទារកន្លែងទំនេរតិច និង អាហារតិច ប៉ុន្តែការបង្កើនការឲ្យចំណីគឺមានសារៈសំខាន់សម្រាប់ដង្កូវនាង។ ទោះយ៉ាងណាក៏ដោយ ដង់ស៊ីតេចិញ្ចឹមខ្ពស់បានផ្ដល់នូវសំបុកនាងអន់ៗច្រើន ព្រោះតែការលូតលាស់ដង្កូវមិនស្មើគ្នាជាហេតុនាំឲ្យការធ្វើសំបុករបស់ដង្កូវនាងមិនស្រុះគ្នាដែរ។

## ៨. ដំណាក់កាលដង្កូវដេក ឬសក

ការសកឯកសណ្ឋានភាពគឺជាកាលដែលតម្រូវឱ្យមាន សម្រាប់ការចិញ្ចឹមដង្កូវនាង។ ជាទូទៅការសកមានឯកសណ្ឋានភាពនៅពេលញាស់ និងការចិញ្ចឹមបានត្រឹមត្រូវ។ ភាពឯកសណ្ឋានភាពតិចតួចនៃការសក ជំនួសពេលដង្កូវទទួលជម្ងឺ ហើយការសកដង្កូវមិនបានធ្វើដោយដៃត្រឹមត្រូវ។ នៅពេលប្រហែល ៧០ ទៅ ៨០%ត្រូវបានសម្រេចនៅដំណាក់កាលសក បញ្ឈប់ការឱ្យចំណីដង្កូវ ហើយសីតុណ្ហភាពចុះទាបជិត ១-២អង្សាពីសីតុណ្ហភាពធម្មតា។នៅពេលដែលដង្កូវរៀបសក ពួកវាបន្ថយការស្រេកឃ្លានហើយខ្លួនរបស់វាក្លាយជារលោងគឺ រៀបរយសម្រាប់ពួកវាបោះបង់ចោលស្បែកចាស់ចេញ ដូច្នេះ ការធ្វើអនាម័យមុនពេលសកត្រូវតែប្រកាន់ភ្ជាប់។ នៅពេលដង្កូវសក១០០% ហើយពណ៌ក្បាលដង្កូវ ប្រែទៅជាពណ៌ត្នោតចាស់ដង្កូវនាងនិងស្រេកឃ្លានឡើងវិញ។ នេះជាពេលវេលាដែលត្រឹមត្រូវសម្រាប់ឱ្យចំណី ទៅដង្កូវនាង។

អំឡុងពេលដំណាក់កាលសក ត្រូវរក្សាកន្លែងចិញ្ចឹមឱ្យមានខ្យល់ចេញចូលបានល្អ ហើយសីតុណ្ហភាព ២៤អង្សា និងសំណើម ៧០-៧៥% ឲ្យបានត្រឹមត្រូវ។ នៅពេលដែលដង្កូវទាំងអស់មិនបានចូលទៅកន្លែងរបស់វារៀងខ្លួន ទេ ការឱ្យចំណីនិងត្រូវបានធ្វើ។ ការធ្វើអនាម័យកន្លែងចិញ្ចឹមគួរតែបានអនុវត្តន៍លើកដំបូងនៅថ្ងៃទី២ឬទី៣ នៃដង្កូវដំណាក់កាលទី៥។នៅពេលដែលដង្កូវពេញវ័យ ពួកវាវារវើរវាយ ហើយរកកន្លែងកាច់សំបុក។ ដង្កូវនាងពេញវ័យ បញ្ចេញសរសៃអំបោះ ពីមាត់របស់វាដើម្បីបង្កើតជាជើងសម្រាប់សំបុកនាង។ ជើងនេះត្រូវបានហៅថា សសៃសូត្ររបស់សំបុកនាង។ នៅពេលដែលជើងបានសង់ឡើង ត្រគាករបស់ដង្កូវនាងនិងឆ្ពោះទៅទីតាំងខាងក្រៅសម្រាប់ការបញ្ចេញរចាល របស់វា។ សសៃសូត្រសំបុកនាងខុសៗគ្នាទៅតាមពូជដង្កូវនាងនិងទម្រង់នៃគ្រោងសំបុក។ ជាទូទៅ ១-២% នៃទម្ងន់សំបកសំបុក។ ដំណើរការសាងសង់សំបុកដោយដង្កូវនាងហៅថាការកាច់សំបុក។ ប្រសិនបើដង្កូវនាងត្រូវបានរំខានអំឡុងពេលកាច់សំបុកការបន្តនៃសសៃសូត្រអាចខូចហើយដង្កូវអាចឈប់ផលិតសំបុក។ ដូច្នេះ ដង្កូវនាងគួរតែកាន់ថ្នមៗរយៈពេល ២-២.៥ថ្ងៃ បន្ទាប់ពីឡើងសំបុកពិត

ប្រាកដ នៅពេលដែលក្រដាសនៅកន្លែងចិញ្ចឹមបានគ្រោងសម្រាប់ការឡើងសំបុកជាក់លាក់ត្រូវបានផ្លាស់ប្ដូរ។ មានដង្កូវនាងខ្លះជាមួយនិងបញ្ហាសេនេទិចដោយក្រពេញសូត្ររបស់វា។ដង្កូវទាំងនេះទោះបីជាមើលទៅបង្ហាញ ឱ្យឃើញពីសុខភាពល្អ និង មិនបង្កើតសំបុក។ ដង្កូវទាំងនេះត្រូវបានហៅថាគ្មានការកាច់សំបុកដង្កូវនាង។

## ៩. វដ្ដជីវិតនៃសត្វដង្កូវនាង

វដ្ដជីវិតរបស់ដង្កូវនាង មានរយៈពេល ៤៨ ទៅ៥៧ ថ្ងៃក្នុងនោះ

១. វគ្គពង និងញាស់ មានរយៈពេល ១២ - ១៣ ថ្ងៃ

២. វគ្គលូតលាស់- ដង្កូវដំណាក់កាលទី៥ មានរយៈពេល ៧ ថ្ងៃ

- ដង្កូវដំណាក់កាលទី១ មានរយៈពេល ៤ ថ្ងៃ
- ដង្កូវដំណាក់កាលទី២ មានរយៈពេល ៣ ថ្ងៃ
- ដង្កូវដំណាក់កាលទី៣ មានរយៈពេល ៣ ថ្ងៃ
- ដង្កូវដំណាក់កាលទី៤ មានរយៈពេល ៥ ថ្ងៃ

៣. វគ្គឡើងសំបុក មានរយៈពេល ៤ - ៥ ថ្ងៃ

៤. វគ្គដឹកដឿនៅក្នុងសំបុក មានរយៈពេល១០-១៥ថ្ងៃ

៥. វគ្គមេអំបៅ និងបន្ដពូជ

### វដ្ដជីវិតរបស់ដង្កូវនាង





### ៩.១ ការចិញ្ចឹមក្នុងដំណាក់កាលលូតលាស់

#### ៩.១. ១. ចរិតលក្ខណៈក្នុងដំណាក់កាលលូតលាស់

ការរីកធំធាត់របស់ដង្កូវនាងវាប្រែប្រួលទៅតាមវដ្តជីវិតនៃដំណាក់កាលលូតលាស់នីមួយៗ។ ទីមួយត្រូវតែរក្សាសីតុណ្ហភាព និងសំណើម ដោយប្រើឧបករណ៍ស្រូបខ្យល់  និងឧបករណ៍រក្សាសីតុណ្ហភាពទៅតាមតម្រូវការរបស់ដង្កូវនាងតាមដំណាក់កាលនីមួយៗ។ ទីពីរ ដង្កូវវាស៊ីចំណី(ស្លឹកមន) ពីតិចនៅដំណាក់កាលដំបូង ទៅស៊ីចំណីច្រើននៅដំណាក់កាលទី៥ និងវាឈប់ស៊ីចំណីពេលពេញវ័យចាប់ផ្ដើបឡើងសំបុក។

#### ៩.១. ២ បរិយាកាសក្នុងការចិញ្ចឹម

##### ក. សីតុណ្ហភាព

ដង្កូវនាងមិនអាចរស់បានទេនៅសីតុណ្ហភាពខ្ពស់ ចំពោះសីតុណ្ហភាពអំណោយផលសម្រាប់ដង្កូវនាងរីកធំធាត់បានល្អគឺពី២៤ទៅ២៧អង្សារ ចំពោះប្រភេទពូជមួយចំនួនដូចក្នុងតារាងខាងក្រោម៖

| លើក | ពូជដង្កូវនាង | ពីដំណាក់កាលទី១ដល់ទី៣ ( សីតុណ្ហភាព ) | ដង្កូវនាងពីដំណាក់កាលទី៤ ដល់ទី៥ ( សីតុណ្ហភាព ) |
|---|---|---|---|
| ១ | Bivoltine x bivoltine | ២៦ទៅ២៧ 0C | ២៤ទៅ២៦ 0C |
| ២ | Bivoltine x bivoltine<br>ivoltine x polyvoltine | ២៧ទៅ២៨ 0C | ២៦ទៅ២៧ |
| ៣-៦ | Bivoltine x polyvoltine<br>Polyvoltine x polyvoltine | ៣៨ទៅ៣០ 0C | ២៧ទៅ២៨ 0C |
| ៧ | Bivoltine x bivoltine<br>Bivoltine x polyvoltine | ២៧ទៅ២៩ 0C | ២៦ទៅ២៧ 0C |

ក៏ប៉ុន្តែចំពោះពូជក្នុងស្រុកវិញវាអាចលូតលាស់បានល្អក្នុងចន្លោះ សីតុណ្ហភាព៣០អង្សារ។ ក្នុងករណីមាន សីតុណ្ហភាពខ្ពស់ជាងនេះគេត្រូវប្រើឧបករណ៍ដើម្បីរក្សាកំដៅនិងសំណើមសម្រាប់ការសូតលាស់របស់ដង្កូវនាង តែបើគ្មានឧបករណ៍រក្សាកំដៅនិងសំណើមទេគេគួតែរងចាំពេលមកដល់នូវអាកាសធាតុសមស្រប។

### ខ. សំណើមបរិយាកាស

ដង្កូវនាងត្រូវការសំណើមសម្រាប់ជីវិតរបស់វាក្នុងចន្លោះពី៧០ទៅ៧៥% ដែលល្អ តែបើសំណើមវាទាប ឬក៏ខ្ពស់ហួសវាធ្វើឲ្យដង្កូវងាប់ ដូច្នេះគេត្រូវការប្រើឧបករណ៍ស្រូបសំណើមជាជំនួយក្នុងករណីមានសំណើមទាប ឬខ្ពស់ ពេក ព្រោះសំណើមទាំងនេះបណ្ដាលមកពី អាកាសធាតុ ក្ដៅ សើម និងសំណើមចេញពីស្លឹកមនជាចំណី និងភាយពីខ្លួនដង្កូវនាង។

### គ. ខ្យល់

ក្នុងបន្ទប់ចិញ្ចឹមដង្កូវនាងត្រូវការចាំបាច់ឱ្យមានខ្យល់បរិសុទ្ធចេញចូលដើម្បីរក្សាសីតុណ្ហភាព និងសំណើមនៅក្នុងបន្ទប់ក៏ដូចជាជួយកាត់បន្ថយការកើនឡើងនូវបរិមាណឧស្ម័នកាបូនិកក្នុងបន្ទប់ចិញ្ចឹមដែលធ្វើឱ្យដង្កូវនាងវាងាប់និងមួយវិញទៀតក៏មានឥទ្ធិពលទៅលើចំហាយទឹកដែលភាយចេញពីខ្លួនដង្កូវនាងនិងស្លឹកមនពេលដែលយើងផ្ដល់ជាចំណីដោយធ្វើឲ្យសំណើមក្នុងបន្ទប់ចិញ្ចឹមថយចុះផងដែរ តែពេលដង្កូវនាងនៅតូចៗពុំសូវត្រូវការលំហូរខ្យល់ស្អាតប៉ុន្មានទេ លុះដល់ពេលដង្កូវនាងធំទើបត្រូវការលំហូខ្យល់ខ្លាំង ក៏ប៉ុន្តែយើងមិនអាចចិញ្ចឹមដង្កូវនាងនៅតំបន់ដែលមានខ្យល់បក់បោកខ្លាំងបានទេ។ ទន្ទឹមនឹងនេះយើងត្រូវប្រុងប្រយ័ត្នចំពោះការភាយឧស្ម័នការបូនិកដែលមានភាគរយខ្ពស់ក្នុងខ្យល់ ដែលបណ្ដាលមកពីការដុតសំរាម ដុតអុស និងការភាយជាតិហ្គាសឧស្ម័នពុល នៃសារធាតុគីមី និងជាតិហ្គាសរបស់ប្រេងសាំង ចូលទៅក្នុងបន្ទប់ចិញ្ចឹមដង្កូវនាងទេពីព្រោះវាធ្វើឱ្យដង្កូវនាងងាប់។

### ឃ. ពន្លឺ

ដង្កូវនាងពេលមុនញាស់ និងកូនដង្កូវនាងនៅដំណាក់កាលទី១វាពុំត្រូវការពន្លឺទេ ក៏ប៉ន្តែបន្ទាប់ពីនោះមកវាត្រូវការពន្លឺបន្តិចម្ដងៗ ហើយត្រូវការពន្លឺខ្លាំងនៅដំណាក់កាលទី៤ និងទី៥ ពីព្រោះពន្លឺបានជួយជំរុញឱ្យដង្កូវលូតលាស់បានល្អ។ តែដង្កូវនាងវាត្រូវការពន្លឺថ្ងៃទៅតាមប្រភេទនៃពូជនីមួយៗខុសៗគ្នា។

## ១០. ដំណាក់កាលឡើងសំបុក

### ១០.១ ដំណាក់កាលពេញវ័យរបស់ដង្កូវនាង

បន្ទាប់ពីដំណាក់កាលទី៥មួយសប្ដាហ៍ដង្កូវនាងស៊ីចំណីតិចហើយខ្លួនរបស់វាចាប់ផ្ដើមរួញនិងប្រែព័ណ៌ជាថ្លា ដែលនេះជាដំណាក់កាលដង្កូវពេញវ័យ ពោលគឺវាចាប់ផ្ដើមបញ្ចេញសូត្រនិងស្វែងរកសំបុកសម្រាប់ធ្វើ សំបុក។





១០.២ របៀបធ្វើសំបុករបស់ដង្កូវនាង

ពេលដង្កូវនាងពេញវ័យវាចាប់ផ្តើមបញ្ចេញសំឡីសូត្រពីមាត់របស់វាដោយធ្វើចលនាជាមួយនិងជើងដើម្បីបង្កើតជាសំបុកសំឡីមុននឹងចាប់ផ្តើមបង្កើតជាសំបុកដង្កូវនាងដែលយើងអាចស្រាវយកសូត្របាន ។ បរិមាណសំឡីសូត្រនេះអាស្រ័យទៅតាមពូជដង្កូវនាង និងទម្រង់នៃសំបុកសម្រាប់ដង្កូវនាងធ្វើសំបុក រីឯសំឡីសូត្រដែលដង្កូវនាងបញ្ចេញចោលនោះមានប្រហែលពី១ទៅ២%នៃទម្ងន់សរសៃសូត្រសុទ្ធសរុបរបស់សំបុកដង្កូវនាងនីមួយៗ ទាំងអស់នេះជារបៀបធ្វើសំបុករបស់ដង្កូវនាង។ ក្នុងករណីដង្កូវនាងមានអារម្មណ៍មិនល្អឬក៏មានការផ្លាស់ប្តូរវាចុះឡើងពេលវាកំពុងធ្វើសំបុកនោះវាធ្វើឲ្យសរសៃសូត្រដែលដង្កូវវាកំពុងផលិតបែកសរសៃ ឬ ក៏វាឈប់ផលិតសរសៃសូត្រតែម្តង ជាលទ្ធផលសរសៃសូត្រដែលយើងទទួលបានគ្មានគុណភាព។ ដូច្នេះយើងគួរតែចាប់ដង្កូវដាក់លើសំបុកសម្រាប់ដង្កូវនាងធ្វើសំបុកឱ្យបានពី២ទៅ២ថ្ងៃកន្លះមុនវាចាប់ផ្តើមធ្វើសំបុក។ចំពោះដង្កូវឈឺឬដង្កូវមិនគ្រប់លក្ខណៈវាមិនអាចធ្វើសំបុកបានទេ។

១០.៣ លក្ខខណ្ឌចាំបាច់របស់សំបុកសម្រាប់ដង្កូវនាងធ្វើសំបុក

សំបុកសម្រាប់ដង្កូវនាងធ្វើសំបុកគឺគេធ្វើវាពី ឬស្សី មែកឬស្សី មែកឈើ និងក្រដាសកាតុង ពីព្រោះគេត្រូវការប្រើវាមានរយៈពេលយូរ ដូច្នេះសំបុករបស់ដង្កូវនាងទាមទានូវលក្ខខណ្ឌចាំបាច់មួយចំនួនដូចតទៅៈ

- ចំពោះសំបុកធ្វើពីក្រដាសកាតុងគឺរក្សាចន្លោះប្រអប់សម្រាប់ដង្កូវនាងធ្វើសំបុកមានទំហំប៉ុនៗគ្នា។
- ទំហំចន្លោះប្រអប់សម្រាប់ដង្កូវនាងធ្វើសំបុកគួរតែមានទំហំសមស្របឲ្យដង្កូវនាងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើសំបុក។
- ការរៀបចំបន្ទប់សម្រាប់ដង្កូវនាងធ្វើសំបុកគួរតែ មានលក្ខណៈសមស្របទៅតាមតម្រូវការរបស់ដង្កូវនាងក្នុងការធ្វើសំបុក។
- មានភាពងាយស្រួលក្នុងការប្រមូលផលសំបុកដង្កូវនាង។
- គិតពីប្រសិទ្ធភាពសេដ្ឋកិច្ច ភាពធន់ និងងាយស្រូបសំណើម ចំពោះសម្ភារសម្រាប់យកមកធ្វើសំបុកសម្រាប់ដង្កូវនាងធ្វើសំបុក។
- ងាយស្រួលសំអាតសំឡីសូត្រដែលមិនអាចយកមកស្រាវជាសូត្របាន។
- ងាយស្រួលឃើញសំបុកភ្លោះ និងសំបុកដង្កូវនាងខូច។
- មានទំហំតូចងាយស្រួលទុកដាក់។

១០.៤ របៀបឡើងសំបុក





ការឡើងសំបុករបស់ដង្កូវនាងគឺជាពេលដ៏សំខាន់ក្នុងការចិញ្ចឹមដង្កូវនាង ពីព្រោះការឡើងសំបុករបស់ដង្កូវនាង និងកត្តាលក្ខខណ្ឌអាកាសធាតុ វាចាំបាច់ណាស់ ដោយសារវាជះឥទ្ធិពលដល់គុណភាពនៃសំបុកដង្កូវនាង ។ការឡើងសំបុកដង្កូវនាងត្រូវការកំលាំងពលកម្មដើម្បីចាប់ដង្កូវនាងម្ដងមួយៗទៅដាក់លើសំបុកសម្រាប់ឱ្យដង្កូវនាងធ្វើសំបុកពីព្រោះការធ្វើបែបនេះវាងាយស្រួលដល់ដង្កូវនាងក្នុងការធ្វើសំបុក។

### ១០.៥ ការការពារក្នុងដំណាក់កាលដង្កូវឡើងសំបុក

ចំពោះក្រដាសកាសែត និង បន្ទះប្លាស្ទីកដែលបានប្រើសម្រាប់ទ្រាប់ដង្កូវនាងត្រូវប្រមូលចេញពីបន្ទប់ចិញ្ចឹមនៅពេលដង្កូវនាងឡើងសំបុក។ ទន្ទឹមនឹងនេះដែរនូវមានកត្តាចាំបាច់មួយចំនួនពេលដំណាក់កាលដង្កូវនាងវាឡើងសំបុករួមមានសីតុណ្ហភាព សំណើម ឧបករណ៍បូមខ្យល់ ពីព្រោះវាពាក់ពន្ធ័ទៅនឹងគុណភាពសំបុកដង្កូវនាង។ចំពោះ សីតុណ្ហភាពអំណោយផលពេលដង្កូវនាងឡើងសំបុកគឺសីតុណ្ហភាពចន្លោះពី២២ទៅ២៣អង្សាសេ តែបើសីតុណ្ហភាពលើសពី២៥អង្សាសេ នោះគុណភាពសរសៃសូត្រអន់គុណភាព រីឯសំណើមសមស្របសម្រាប់ពេលដង្កូវនាងឡើងសំបុកក្នុងចន្លោះពី៦០ទៅ៧០% ក្នុងករណីមានសំណើមខ្ពស់គេត្រូវយកដង្កូវនាងមកទុកកន្លែងស្ងួត ឬក៏ប្រើឧបករណ៍ស្រូបខ្យល់ជំនួយ។ម្យ៉ាងវិញទៀតមិនត្រូវឲ្យមានខ្យល់បក់ខ្លាំង និងពន្លឺថ្ងៃចាំងចូលទៅក្នុងបន្ទប់ចិញ្ចឹមដង្កូវនាងដោយផ្ទាល់ទេ។





## ១១. ការប្រមូលផល

### ១១.១ ពេលវេលានៃការប្រមូលផលសំបុកដង្កូវនាង

ដង្កូវនាងពីដំណាក់កាលឡើងសំបុកទៅដំណាក់កាលក្លាយខ្លួនជាដឹកឌឿមានកត្តាពីរសំខាន់ គឺសីតុណ្ហភាព និង ពូជរបស់ដង្កូវនាង ក៏ប៉ុន្តែជាទូទៅវាមានចំនួន២ថ្ងៃសម្រាប់ធ្វើសំបុក និង២ថ្ងៃទៀតសម្រាប់ក្លាយខ្លួនវាទៅជាដឹកដឿ ក្នុងសីតុណ្ហភាពអំណោយផល២៥អង្សាសេ ឬអាចលើសនេះទៅតាមពូជនីមួយៗ។កាប្រែខ្លួនទៅជាដឹកដឿដំបូងពណ៌របស់វាសនិងទន់ជាខ្លាំង តែបន្ទាប់ពីរយៈពេល២ទៅ៣ថ្ងៃក្រោយមកដឹកដឿប្រែពណ៌ទៅជាពណ៌ត្នោតនិងចាប់ផ្ដើមរឹង។ ដូច្នេះការប្រមូលផលសំបុកដង្កូវនាងគឺគេប្រមូលវាបន្ទាប់ពីឡើងសំបុកបានរយៈពេល៧ថ្ងៃទើបគុណភាពសរសៃសូត្រល្អ តែបើយើងប្រមូលសំបុកដង្កូវនាងមុនពេលដឹកឌឿវាចាស់នោះ ធ្វើឱ្យសរសៃសូត្រអន់គុណភាព។

### ១១.២ របៀបប្រមូលសំបុកដង្កូវនាង

មុនដំបូងគេត្រូវប្រមូលយកដង្កូវនាងឈឺ ដង្កូវងាប់ និងសំបុកដែលមានដង្កូវនាងងាប់ខាងក្នុងរលួយពីព្រោះវាធ្វើឱ្យប្រឡាក់ដល់សំបុកដែលល្អនាំឱ្យសរសៃសូត្រខូចគុណភាព។ បន្ទាប់ពីសំអាតរួចទើបគេប្រមូលផលសំបុកដង្កូវនាង ដែលល្អតាមក្រោយ។

### ១១.៣ ការសំអាតសំបុកដង្កូវនាង

បន្ទាប់ពីប្រមូលផលសំបុកដង្កូវនាង គេត្រូវសំអាតសំឡីសូត្រ ដែលស្រោបជុំវិញសំបុកដង្កូវនាង ពីព្រោះសំឡី សូត្រនេះមិនអាចស្រាវជាសរសៃសូត្របានទេ។ ម្យ៉ាងវិញទៀតសំឡីសូត្រនេះនឹងស្រូបយកសំណើមក្នុងបរិយាកាសជាហេតុធ្វើឲ្យសរសៃសូត្រខូចគុណភាពដូច្នេះគេត្រូវសំអាតវាភ្លាមបន្ទាប់ពីប្រមូលផលសំបុកដង្កូវនាង។

### ១១.៤ ករណីពិសេសមួយចំនួនចំពោះសំបុកដង្កូវនាង

#### ១១.៤.១ សំបុកភ្លោះ

សំបុកភ្លោះគឺជាសំបុកដែលបានមកពីការធ្វើសំបុកចូលគ្នារវាងដង្កូវពីរឬច្រើនជាងនេះ។ សំបុកទាំងនោះធំនិងជាប់គ្នាក៏ប៉ុន្តែសំបុកទាំងនេះមិនអាចស្រាវសូត្រដែលមានគុណភាពល្អទេពីព្រោះសរសៃសូត្រប្រួមចូលគ្នាពីរ។ កត្តាទាំងនេះវាបណ្ដាលមកពីប្រភេទសំបុកសម្រាប់ដង្កូវនាងធ្វើសំបុក ចំនួនដង្កូវនាងពេលឡើងសំបុក និង តាមប្រភេទពូជដង្កូវនាង។

#### ១១.៤.២ សំបុកប្រឡាក់

សំបុកប្រឡាក់គឺជាស្នាមប្រឡាក់នៅលើផ្ទៃនៃសំបុកដង្កូវនាង ក្នុងរយៈពេលឡើងសំបុក ឬសំបុកសម្រាប់ ដង្កូវនាងធ្វើសំបុកមានផ្ទៃតូចង្អៀត ឬចំនួនដង្កូវនាងឡើងសំបុកច្រើនពេក និងមួយវិញទៀតប្រឡាក់ពេលប្រមូលផលសំបុកដង្កូវនាង។

#### ១១.៤.៣ សំបុកមានស្នាមខាងក្រៅ

ការប្រឡាក់សំបុកដង្កូវនាងលើផ្ទៃខាងក្រៅបណ្ដាលមកពីការប្រឡាក់ដោយឈាម ឬដង្កូវនាងដែលរលួយមកប៉ះនិងសំបុកដង្កូវនាងដែលល្អ កត្តាទាំងនេះបណ្ដាលមកពីប្រភេទនៃសំបុកសម្រាប់ដង្កូវនាងធ្វើសំបុក និង ដង់ស៊ីតេដង្កូវនាងខ្ពស់ពេលវាធ្វើសំបុក។

#### ១១.៤.៤ សំបុកមានស្នាមខាងក្នុង

ការប្រឡាក់ផ្ទៃខាងក្នុងរបស់សំបុកដង្កូវនាងបណ្ដាលមកពីដង្កូវនាងងាប់ក្នុងសំបុក និងពេលដង្កូវនាងក្លាយខ្លួនទៅជាដឹកដឿ ម៉្យាងវិញទៀតការប្រឡាក់ដោយឈាមដង្កូវនាង ដែលងាប់ដោយសារជំងឺ ឬការបែកដឹកដឿ ពេលប្រមូលផល ឬក្នុងពេលដឹកជញ្ជូនសំបុកដង្កូវនាងទៅកែច្នៃនៅកន្លែងឆ្ងាយ។

#### ១១.៤.៥ សំបុកស្ដើងខាងចុង

ចំពោះសំបុកដង្កូវនាងដែលស្ដើងខាងចុងតែម្ខាង ឬសងខាង គឺបណ្ដាលមកពី កត្តាសេនេទិករបស់ពូជ ឬ ពេលភ្ញាស់ពងមានសីតុណ្ហភាពខ្ពស់ ឬដង្កូវទទួលចំណីមិនគ្រប់គ្រាន់នៅដំណាក់កាលលូតលាស់ ឬដង្កូវមានរបួសដោយសារសត្វល្អិត ឬពេលដង្កូវឡើងសំបុកមានសំណើមខ្ពស់ ឬខ្យល់បក់ខ្លាំងទៅលើកន្លែងដែលដង្កូវកំពុងឡើង សំបុក ឬ ក៏មានពន្លឺថ្ងៃខ្លាំងចូលក្នុងបន្ទប់។

#### ១១.៤.៦ សំបុកមិនពេញលក្ខណៈ

ចំពោះសំបុកមិនពេញលក្ខណៈគឺសំបុកដង្កូវនាង វាប៉ោង ឬស្រួច មិនមូលទាំងនេះបណ្ដាលមកពី ប្រអប់ សម្រាប់ដង្កូវនាងធ្វើសំបុកមានរាងមិនស្មើជ្រុង ឬក៏ដង្កូវនាងមានសុខភាពមិនល្អ។

#### ១១.៤.៧ សំបុកមានសំបកស្ដើង

សំបុកដង្កូវនាងដែលមានសំបកស្ដើងបណ្ដាលមកពីកកត្តាចំណី( ស្លឹកមន )មិនល្អ។

#### ១១.៤.៨ សំបុកប្រហោង

ចំពោះសំបុកដង្កូវនាងប្រហោងបណ្ដាលមកពី ដង្កូវប៉ារ៉ាសិត ឬសត្វស្រមោចចោះរន្ធ ដូច្នេះគេត្រូវការពារសត្វទាំងនេះកុំឲ្យចូលទៅក្នុងកន្លែងដង្កូវនាងធ្វើសំបុកពេលប្រមូលផលសំបុកដង្កូវនាង។

#### ១១.៤.៩ សំបុកគ្មានសំបក

ចំពោះសំបុកដង្កូវនាងដែលគ្មានសំបកគឺច្រើនកើតមានចំពោះពូជ multivoltine និងប្រភេទពូជមួយចំនួន ឬមានសីតុណ្ហភាពខ្ពស់ពេលដង្កូវនាងធ្វើសំបុក។ កត្តាទាំងនេះវាជះឥទ្ធិពលលើសំបុកដង្កូវនាងមិនលើសពី៥%ទេ ប៉ុន្តែបើយើងមិនថែរក្សាវាឲ្យបានល្អទេនោះ សំបុកដែលគ្មានសំបកនឹងកើនឡើងជាង៣០% ។

### ១១.៥ លក្ខណៈសំគាល់សំបុកដង្កូវនាង

#### ១១.៥.១ ទម្រង់

ទម្រង់នៃសំបុកដង្កូវនាងវាអាស្រ័យទៅតាមពូជដង្កូវនាងនីមួយៗ ដូចជាពូជរបស់ប្រទេសជប៉ុនរាង ដូចជាសណ្ដែកដី

ពូជរបស់ប្រទេសចិនរាងដូចពងក្រពើ រីឯពូជរបស់អឺរ៉ុបរាងដូចជាពងក្រពើទ្រវែង និងពូជមួយចំនួនទៀតរាងដូចជាស្នូលឬ ភ្លៅ ចំពោះពូជ បង្កាត់វិញទម្រង់សំបុករបស់វា អាស្រ័យទៅតាមមេបារបស់វា។

### ១១.៥.២ ទំហំ

ទំហំនៃសំបុកដង្កូវនាង វាមានលក្ខណៈសំខាន់ណាស់ សម្រាប់វាយតម្លៃនៃសំបុកដង្កូវនាង។ ទំហំនៃសំបុកដង្កូវនាង វាអាស្រ័យតាមពូជដង្កូវនាងនីមួយៗ ពេលវេលាក្នុងការចិញ្ចឹម និងលក្ខខណ្ឌនៃការប្រមូលផល។ជាទូទៅការវាស់ទំហំនៃ សំបុកដង្កូវនាង កំណត់ដោយបរិមាណចំនួនសំបុកដង្កូវនាង ក្នុងមួយលីត្រ ដូចជាប្រភេទពូជ Bivoltine វាមានសំបុកដង្កូវ នាងពី៦០ទៅ១០០សំបុកដង្កូវនាង ក្នុងមួយលីត្រ។

### ១១.៥.៣ ពណ៌

ព័ណ៌នៃសំបុកដង្កូវនាងជាទូទៅគេកំណត់យកពីរពណ៌គឺ ពណ៌ស និង ប្រភេទពណ៌ដែលក្នុងនោះមានពណ៌ បៃតង លឿង មាស និង ផ្កាឈូក។ល។ ប៉ុន្តែភាគច្រើនជាប្រភេទពណ៌ស។

### ១១.៥.៤ ស្នាមជ្រួញ

ស្នាមជ្រួញនៅលើផ្ទៃនៃសំបុកដង្កូវនាងមាន ផ្ទៃគ្រើមខ្លាំង គ្រើម ធម្មតា ផ្ទៃរាជិត និងផ្ទៃរាជិតល្អ។

### ១១.៥.៥ ទម្ងន់នៃសំបុកដង្កូវនាង

ទម្ងន់ នៃសំបុកដង្កូវនាង គឺជាទម្ងន់សរុបរបស់ដឹកឌឿ បូក និងទម្ងន់នៃសរសៃសូត្រជាសំបុក និងទម្ងន់សំបកភ្នាស ស្រោបពីលើដឹកឌឿនិងសរសៃសូត្រ។ ចំពោះទម្ងន់សំបុកដង្កូវនាងដែលបានបង្កាត់នៅជំនាន់ទី១ វាមានទម្ងន់ចន្លោះពី ២ ទៅ ២.៥ក្រាមនៅតំបន់ត្រជាក់ រីឯតំបន់ត្រូពិកវិញវាមានទម្ងន់ចន្លោះពី ១.៥ ទៅ ២ ក្រាម ក្នុងនោះដង្កូវនាងញីមានទម្ងន់ធ្ ន់ជាងដង្កូវនាងឈ្មោល។

### ១១.៥.៦ ទម្ងន់សរសៃសូត្រសំបកសំបុកដង្កូវនាង

ទម្ងន់សរសៃសូត្រនៃសំបកសំបុកដង្កូវនាងវាមានសារៈសំខាន់ណាស់ ព្រោះវាជាសរសៃសូត្រសម្រាប់ស្រាវ យក សូត្រ។ ចំពោះពូជបង្កាត់ជំនាន់ទីមួយ វាមានទម្ងន់ចន្លោះពី០.៤០ ទៅ០.៥០ក្រាម នៅតំបន់ត្រជាក់ និងមានទម្ងន់ពី០.៣០ ទៅ០.៤០ក្រាមនៅតំបន់ត្រូពិច។

### ១១.៥.៧ ភាគរយនៃទម្ងន់សំបកសំបុកដង្កូវនាង

ភាគរយនៃសំបកសំបុកដង្កូវនាង មានសារៈសំខាន់ណាស់ ពីព្រោះវាក៏ដូចជាភាគរយនៃសរសៃសូត្រដែលនឹងត្រូវ ទទួលបានពីការចិញ្ចឹមដង្កូវនាងនេះដែរ។ ចំពោះពូជបង្កាត់នៅជំនាន់ទី១ មានចំនួនពី២២ទៅ២៥% នៅតំបន់ត្រជាក់ និ ងនៅតំបន់ត្រូពិចវាមានចំនួនពី១៨ទៅ២២% ប៉ុន្តែចំពោះ ភាគរយនៃសំបកសំបុកដង្កូវនាងរវាងឈ្មោលនិងញីខុសគ្នាពី២ ទៅ៣%។

### ១១.៥.៨ ប្រវែងនៃសរសៃសូត្រ

ប្រវែងនៃសរសៃសូត្រក្នុងមួយសំបុកដង្កូវនាង ចន្លោះពី១២០០ ទៅ១៥០០ម៉ែត្រ ក្នុងមួយសំបុកដែលជាប្រភេទពូជ បង្កាត់នៅជំនាន់ទី១ រីឯប្រវែងនៃពូជផ្សេងទៀតវាអាស្រ័យទៅលើប្រភេទនៃពូជទាំងនោះ។

### ១១.៥.៩ ទំហំនៃសរសៃសូត្រ

ទំហំនៃសរសៃសូត្របង្កាត់នៅជំនាន់ទី១មានទំហំចន្លោះពី២.៥ទៅ៣.៥ deniers ។

### ១១.៥.១០ ភាគរយនៃសរសៃសូត្រ

ភាគរយនៃសរសៃសូត្រ គឺវាពាក់ព័ន្ធទៅនឹងបរិមាណនៃសំបុកដង្កូវនាងដែលត្រូវស្រាវ។ ភាគរយនៃសរសៃសូត្រ ជាទូទៅមានពី៧៨ទៅ៨៤%នៃសរសៃសូត្រសំបកនៃសំបុកដង្កូវនាង ឬក៏មានពី១៦ទៅ២០%សរសៃសូត្រស្រស់ នៃសំបុក ដង្កូវនាងទាំមូល។

## ឯកសារយោង


១. គង់ សំអឿន, ២០១២.របាយការណ៍វឌ្ឍភាពស្ដីពីលទ្ធផលនៃការអនុវត្តគម្រោងគាំទ្រការស្ដារឡើងវិញវិស័យសូត្រនៅកម្ពុជា

២. គង់ សំអឿន, ២០១០.របាយការណ៍សកម្មភាពអនុវត្តការងារគម្រោងគាំទ្រការស្ដារឡើងវិស័យសូត្រនៅកម្ពុជា

៣. Dr. Kim Kee Young, 2013. Sericultural & Apicultural Materials Division Department of Agricultural Biology, National Academy of Agricultural Science, RDA, Republic of Korea

៤. Dr. Lee Myeong Lyeol, 2013. Sericultural & Apicultural Materials Division Department of Agricultural Biology, National Academy of Agricultural Science, RDA, Republic of Korea

៥. FAO Agricultural Services Bulletin 80,1990. Sericulture training manual

៦. FAO Agricultural Services Bulletin 73/2,1992. Silkworm rearing

៧. FAO Agricultural Services Bulletin 73/3,1992. Silkworm rearing

៨. FAO Agricultural Services Bulletin 73/4,1992. Silkworm rearing

៩. Food and Agriculture Organization of the United Nations Regional Office for Asia and the Pacific Bangkok Thailand ។






# រុក្ខជាតិឱសថកកោះ

## SINDORA SIAMENSIS TEYSM. EX MIQ. VAR SIAMENSIS



ដោយលោក ឃៀង អៀងតិច ការិយាល័យផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈ

ឯកសារយោង៖ សៀវភៅ រុក្ខជាតិឱសថបុរាណខ្មែរ របស់ក្រសួងសុខាភិបាល ភាគ១

កកោះមានឈ្មោះឡាតាំង Sindora wallichii Benth, var siamensis Baker ស្ថិតក្នុងអំបូរ LEGUMINOSAE ។ ជារុក្ខជាតិឈើទំហំមធ្យម មានកម្ពស់ ១៥-២៥ ម៉ែត្រ។ ស្លឹករួមស្លាបគូ រាងពងក្រពើ ដុះទល់គ្នាមានពី ២-៤គូ ស្លឹកវាស្ថិតខាងលើស្លឹកមានរោមតិចៗ ខាងក្រោមមានសរសៃ និងរោមច្រើន ស្លឹកមានប្រវែងពី ៥-១០ស.ម និងទទឹងពី ២,៥-៥,៥ស.ម។ ផ្កាដុះជាចង្កោមធំមានពណ៌លឿង ចេញនៅចុងមែក និងប្រគាបស្លឹក។ ផ្លែវាមានរាងមូលសំប៉ែត មានបន្លាពណ៌បៃតង ផ្លែមួយ មានគ្រាប់មួយ នៅលើទងគ្រាប់ មានក្បាលរាងដូចផ្សិត។ ចេញផ្កានៅខែ៣ ដល់ខែ៦ ផ្លែចេញពីខែ៦ ដល់ខែ២។ រុក្ខជាតិនេះច្រើនដុះដោយខ្លួនឯង នៅតំបន់តំបន់ភ្នំ និងខ្ពង់រាប ឬគេដាំ។ វាបន្តពូជដោយគ្រាប់។



### ការប្រើប្រាស់ជាឱសថ

ផ្នែកប្រើប្រាស់ ៖ សំបក ដើម និង គ្រាប់។

រសជាតិ៖ សំបកមានរស់ជាតិល្វីងចត់។

**ការព្យាបាល ៖**

~ សំបក៖ លាយជាមួយថ្នាំផ្សេង ព្យាបាលរាគ និងរាគមូល។

~ ពកដើម៖ ដាំផឹកព្យាបាលព្រូន រោគស្បែក ដាំឆ្លង់ឲ្យឫសដូងបាតរួញបាត់។

~ គ្រាប់៖ ដុសបិតបូស រោគសើស្បែក។

~ កម្រិត និងរបៀបប្រើ៖ កម្រិតប្រើ ១០-១៥ក្រាម ដាំផឹកក្នុង១ថ្ងៃ។





# រុក្ខជាតិឱសថកញ្ជាន់អាចម៍ជ្រូក

## URENA LOBATA L.



ដោយលោក ឃៀង អៀងតិច ការិយាល័យផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈ

កញ្ជាន់អាចម៍ជ្រូកមានឈ្មោះឡាតាំង Urena lobata L.ស្ថិតក្នុងអំបូរ MALVACEAE។ ជាចុល្លព្រឹក្សខ្នាតតូច មានកម្ពស់ ៥០-១២០ស.ម មានរោម ឫសពណ៌លឿងខ្ចី។ ស្លឹកវាដុះឆ្លាស់គ្នារាងមូលឆែករាក់ៗ ស្រួចចុង ដើមខ្លះឆែកធំៗ មានចង្អូរស្តើងៗ ខាងលើពណ៌បៃតង ខាងក្រោមពណ៌ប្រផេះ មានរោម។ ផ្កាវាពណ៌ផ្កាឈូកមានប្រាំត្របក ដុះមួយទង ឬពីរទង ចេញពីប្រគាបស្លឹក។ ផ្លែវា ជាផ្លែមូលទ្រុឌខាងចុង មានរោមទំពក់ជុំវិញផ្លែ ផ្លែមួយមានប្រាំក្លែប ក្នុង១ ក្លែបមាន១គ្រាប់។ គ្រាប់ទុំរបស់វាដែលមានមានរោមទំពក់ជុំវិញនោះងាយស្អិតតោងជាប់ខោអាវ ពិសេសសក់ ដែលគេឧស្សាហ៍យកមកដាក់លើសក់គ្នាលេង។ រុក្ខជាតិនេះច្រើនដុះដោយខ្លួនឯងតាមចិញ្ចើមផ្លូវ ឬកន្លែងវាល។



### ការប្រើប្រាស់ជាឱសថ

**ផ្នែកប្រើប្រាស់ ៖** រុក្ខជាតិទាំងមូល។

**រសជាតិ៖** ផ្អែមឡៃមៗ ហឹរ មិនក្ដៅ មិនត្រជាក់ (ធាតុស្មើ)។

**ការព្យាបាល ៖**

គ្រុនផ្ដាសាយ ចុកស្រពន់ រាគមួល អាហារមិនរលាយ ហើមទឹក ឈឺឆ្អឹងឆ្អែង រលាកបំពង់ក ឈឺបំពង់ក គ្រុនពោះវៀន គ្រុនចាញ់ ធ្លាក់ស ពស់ចិក រលាកដោះ កើតពិស។

**កម្រិត និងរបៀបប្រើ ៖**

~ រុក្ខជាតិស្ងួតត្រូវប្រើពី១៥-៣០ ក្រាម ក្នុង១ថ្ងៃ

~ រុក្ខជាតិស្រស់ត្រូវប្រើពី៥០-១០០ក្រាម ក្នុង១ថ្ងៃ។

**បញ្ជាក់ ៖** ពស់ចិក និងរលាកដោះ បុកស្រស់បំពោក៕







# ផែនការសកម្មភាពអភិរក្សខ្លាធំ នៅកម្ពុជា



ដោយៈរដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ


## សង្ខេប

ខ្លាធំជាប្រភេទសត្វដែលមានរូបរាងសង្ហា ពណ៌សម្បុរស្រស់ស្អាត និងមានមហិទ្ធិឫទ្ធិខ្លាំងក្លាលើសពពួកសត្វព្រៃទាំងឡាយ។ ទោះជាមានកិច្ចខិតខំប្រឹងប្រែងអភិរក្សក៏ដោយក៏ចំនួនខ្លាធំនៅក្នុងព្រៃបានបន្តធ្លាក់ចុះយ៉ាងខ្លាំង ដោយសារចំនួនខ្លាធំមានតិចតួចស្រាប់ ហើយមានការបរបាញ់ខុសច្បាប់ ការរំខានទីជម្រក និងការថយចុះនូវសត្វរំពាខ្លាធំ។




កម្មវិធីស្រាវជ្រាវខ្លាធំ បានចាប់ផ្តើម ក្នុងឆ្នាំ១៩៩៨ ដោយរដ្ឋបាលព្រៃឈើ ហើយបានកំណត់ តំបន់ទេសភាពដែលជាទីជម្រកសមស្របសម្រាប់អភិរក្សខ្លាធំចំនួន៣កន្លែង រួមមាន៖ តំបន់ជួរភ្នំក្រវាញ តំបន់ខ្ពង់រាបភាគខាងកើត និង តំបន់ខ្ពង់រាបភាគខាងជើង។

នៅឆ្នាំ២០០៤ អង្គការក្រៅរដ្ឋាភិបាលជាច្រើនដែលធ្វើការអភិរក្សខ្លាធំ បានបើកកិច្ចប្រជុំមួយ ដើម្បីពិនិត្យមើលទិន្នន័យខ្លាធំដែលមានទាំងអស់ សម្រាប់ជាមូលដ្ឋានមួយក្នុងការកំណត់តំបន់ទេសភាពអភិរក្សខ្លាធំសកល។ របាយការណ៍ខ្លាធំដែលទទួលបានមកពីវិធីសាស្ត្រសិក្សាស្រាវជ្រាវ ផ្សេងៗគ្នាជាច្រើនត្រូវបានគេវិភាគដែលឈានដល់ការប៉ាន់ស្មានមួយថាមានចំនួនខ្លាធំប្រមាណពី២០ទៅ៥០ក្បាល កំពុងរស់នៅក្នុងប្រទេសកម្ពុជា។

នៅកម្ពុជា ខ្លាធំត្រូវបានការពារយ៉ាងពេញលេញដោយច្បាប់ស្តីពីព្រៃឈើឆ្នាំ ២០០២ ហាមឃាត់ការបរបាញ់ ការសម្លាប់ ការធ្វើពាណិជ្ជកម្ម ឬនាំចេញខ្លាធំ។ ជនណាក៏ដោយដែលជាប់ចោទនូវបទល្មើសបែបនេះ ត្រូវដាក់ទោសឱ្យជាប់ពន្ធនាគារពី៥ ទៅ ១០ឆ្នាំ និង រឹបអូសនូវវត្ថុតាងទាំងអស់។ ផែនការសកម្មភាពអភិរក្ស ខ្លាធំនៅកម្ពុជា ត្រូវបានរៀបចំឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានរដ្ឋបាលព្រៃឈើជាអ្នកអនុវត្តសហការជាមួយក្រសួង បរិស្ថាន ដើម្បីរៀបចំកម្មវិធីស្តារខ្លាធំជាសកលក្នុងគោលបំណងជំរុញបង្កើនចំនួនខ្លាធំឲ្យកើនឡើង២ដង ចាប់ពីពេលបច្ចុប្បន្នរហូតដល់ឆ្នាំ២០២៦។ គោលដៅរយៈពេលវែងនៃផែនការសកម្មភាពអភិរក្សខ្លាធំ នៅកម្ពុជាត្រឹមឆ្នាំ២០២៦ គឺត្រូវស្តារ និងអភិរក្សតំបន់ស្នូលមិនអាចរំលោភបំពានបានក្នុងតំបន់ ព្រៃការពារមណ្ឌលគិរី និងតំបន់ភ្នំក្រវាញ ដែលជាតំបន់អាទិភាពសម្រាប់ស្តារខ្លាធំនៅកម្ពុជា។ ផែនការសកម្មភាពអភិរក្សខ្លាធំនៅកម្ពុជា បានកំណត់យុទ្ធសាស្ត្រចំនួន៥ រួមមាន៖

- យុទ្ធសាស្ត្រទី១៖ បង្កើតដែនជម្រកពូជខ្លាធំនៅក្នុងតំបន់ព្រៃការពារមណ្ឌលគិរី និងតំបន់ ជួរភ្នំក្រវាញ ជាតំបន់ស្តារខ្លាធំ ដោយមានការការពារតឹងរ៉ឹង និងមិនមានការរំខានដល់ទីជម្រកដោយមនុស្ស
- យុទ្ធសាស្ត្រទី២៖ បង្កើនសមត្ថភាពនិងប្រសិទ្ធភាពភ្នាក់ងារអនុវត្តច្បាប់ក្នុងការការពារសត្វព្រៃ និង អភិរក្សទីជម្រក
- យុទ្ធសាស្ត្រទី៣ ៖ បញ្ជ្រាបការគ្រប់គ្រងដែនជម្រករក្សាពូជខ្លាធំទៅក្នុងផែនការអភិរក្ស
- យុទ្ធសាស្ត្រទី៤៖អនុវត្តពិធីសារត្រួតពិនិត្យខ្លាធំ និងសត្វរំពាខ្លាធំជាប្រចាំ
- យុទ្ធសាស្ត្រទី៥ ៖ ពង្រឹងកិច្ចសហការតាមព្រំដែនដើម្បីកាត់បន្ថយ ការប្រមាញ់សត្វព្រៃ ឬ ធ្វើពាណិជ្ជកម្មសត្វ

**សត្វរំពាខ្លាធំ**



ខ្ទីង



ទន្សោង



ជ្រូកព្រៃ



ឈ្លូស

ព្រៃខុសច្បាប់ឆ្លងកាត់ព្រំដែន។

តំបន់សម្រាប់ស្តារខ្លាធំនៃតំបន់ខ្ពង់រាបភាគខាងកើត មានទំហំលើសពី ១២.៥០០គ.ម$^2$ និង តំបន់ជួរភ្នំក្រវាញក៏មានទំហំធំជាង ១២.៥០០គ.ម$^2$ ដែរដែលតភ្ជាប់តំបន់ព្រៃការពារដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងតំបន់ការពារធម្មជាតិ។ ក្រៅពីនេះ តំបន់ទាំងពីរ ក៏មានសត្វរំពាខ្លាធំច្រើនប្រភេទដូចជា ខ្ទីង ទន្សោង ប្រើស រមាំង និងជ្រូកព្រៃជាដើម។ ប៉ុន្តែនៅពេលបច្ចុប្បន្នចំនួនសត្វរំពាទាំងនោះ ត្រូវបានគេធ្វើសេចក្តីសន្និដ្ឋានថានៅមានចំនួនទាបជាងឆ្ងាយសម្រាប់កម្រិតដ៏ចាំបាច់មួយ ដើម្បីរក្សាឲ្យបានឋិតថេរនូវចំនួនខ្លាធំក្នុងតំបន់ដែនជម្រកស្តារខ្លាធំឡើងវិញ។ ដូច្នេះការ ស្តារសត្វរំពាខ្លាធំឡើងវិញ គឺជាមូលដ្ឋាន និងជាគោលដៅលក្ខខណ្ឌមុនគេបង្អស់សម្រាប់ការស្តារចំនួនខ្លាធំឡើងវិញ។លើសពីនេះ ដើម្បីឱ្យមានភាពជោគជ័យក្នុងការស្តារចំនួនខ្លាធំក្នុងតំបន់ដែនជម្រកស្តារខ្លាធំឡើង វិញនោះ ការគ្រប់គ្រងតំបន់ និងការកាត់បន្ថយឱ្យបានច្រើនបំផុត នូវកត្តាគំរាមកំហែង ដោយសារការ បាត់បង់ទីជម្រក និងការបរបាញ់ ក៏ត្រូវធ្វើការពង្រឹងផងដែរ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានរដ្ឋបាលព្រៃឈើ ជាអ្នកអនុវត្ត សហការជាមួយក្រសួង បរិស្ថាន បានសម្រេចដាក់ចេញ នូវផែនការសកម្មភាព អភិរក្សខ្លាធំនៅកម្ពុជា ២០១៦ - ២០២៦ សំដៅផ្តល់នូវ ក្របខ័ណ្ឌគោលនយោបាយ និងយន្តការជាក់លាក់សម្រាប់ ជំរុញការអភិរក្សព្រៃឈើ សត្វព្រៃ ជាពិសេសរៀបចំអនុវត្ត កម្មវិធីស្តារចំនួនខ្លាធំឱ្យកើនឡើង២ដង ចាប់ពីពេលបច្ចុប្បន្នរហូតដល់ឆ្នាំ២០២៦ ស្របតាមកម្មវិធីស្តារខ្លាធំ ជាសកល។

## I- សាវតា

ផែនការសកម្មភាពអភិរក្សខ្លាធំនៅកម្ពុជា គឺជាការអភិរក្សខ្លាធំ មិនឱ្យផុតពូជពីក្នុងព្រៃធម្មជាតិ នៅក្នុងប្រទេសកម្ពុជានឹងបង្កើននូវប្រសិទ្ធភាព សកម្មភាពការងារអភិរក្ស និងគ្រប់គ្រង ដែលអាចបង្កើនចំនួនខ្លាធំ រក្សាពូជបានគង់វង្ស។ ការអភិរក្សខ្លាធំដែលជាប្រភេទបង្គោល( Umbrella species ) និងជួយឱ្យមានលំនឹង នូវប្រព័ន្ធអេកូឡូស៊ីសត្វព្រៃ និងព្រៃឈើ។ លើសពីនេះ ការចូលរួមស្តារ ប្រភេទសត្វព្រៃមិនឲ្យផុតពូជគឺជាកិត្តិយស របស់ប្រទេសកម្ពុជា ដែលបានប្រឹងប្រែងក្នុងការអភិរក្ស សត្វព្រៃនៅក្នុងប្រទេស ក៏ដូចជាការចូលរួមសកម្មភាពអភិរក្សខ្លាធំក្នុងសកលលោកផងដែរ។

### ១-ស្ថានភាពខ្លាធំនៅកម្ពុជា

ខ្លាធំត្រូវមនុស្សភាគច្រើនបានចាត់ទុកជានិមិត្តរូបនៃថាមពល អំណាច ហើយអ្នកវិទ្យាសាស្ត្រកំណត់ថា វត្តមានរបស់វាជាសូចនាករនៃភាពសម្បូរបែបនៃជីវចម្រុះ។ តាមរយៈការសិក្សាស្រាវជ្រាវ របស់អ្នកវិទ្យាសាស្ត្របាន សន្និដ្ឋានថា នៅទសវត្សរ៍ចុងក្រោយនេះចំនួនរបាយខ្លាធំ ជា សកលបានថយចុះពី ១០.០០០ក្បាល មកត្រឹមប្រមាណ ៣.៥០០ក្បាលប៉ុណ្ណោះ ហើយនិន្នាការ នៃការថយចុះនេះ កំពុងតែនៅបន្តទៅទៀត។ តាមតួលេខនៃការធ្លាក់ចុះនេះ គឺជាសញ្ញាណមួយពញ្ញាក់អារម្មណ៍ពិភពលោក ក៏ដូចជាប្រទេសទាំង១៣ ដែលមានវត្តមានខ្លាធំកំពុងរស់នៅក្នុង ព្រៃធម្មជាតិ ថាដល់ពេលត្រូវរួមគ្នារិះរកមធ្យោបាយ និងរៀបចំផែនការក្នុងទិសដៅយូរអង្វែងមួយដើម្បីសង្គ្រោះ ខ្លាធំហើយ។

នៅកម្ពុជាខ្លាធំជាពូជខ្លាឥណ្ឌូចិន Indochinese tiger (Panthera tigris corbetti) ដែលមុនឆ្នាំ១៩៧០ ត្រូវបានគេចាត់ទុកថា ជាប្រភេទសម្បូរបែប ដោយបានអនុញ្ញាតឲ្យធ្វើការប្រមាញ់គ្រប់រដូវកាល។ ប៉ុន្តែបច្ចុប្បន្នចំនួនខ្លាធំបានធ្លាក់ចុះដល់កម្រិតមួយគួរឱ្យព្រួយបារម្ភ ហើយត្រូវបាន ចាត់ទុកជាប្រភេទជិតផុតពូជតាមប្រកាសលេខ០២០ប្រក.កសក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ពីឆ្នាំ១៩៥០ ដល់ ១៩៧០ លោក Charles Wharton បានធ្វើការសិក្សា ជីវសាស្ត្រគោព្រៃនៅផ្នែកខាងជើងនៃប្រទេសកម្ពុជាក្នុង ទសវត្សរ៍ឆ្នាំ១៩៥០ ហើយបានសង្កេតឃើញមានហ្លួង សត្វរមាំង ខ្ទីង ទន្សោង និង ក្របីព្រៃ ក្នុងចំនួនមួយដែលគាត់ធ្វើការប្រៀបធៀបទៅនឹងតំបន់កីឡាប្រមាញ់ នៅតំបន់អាហ្វ្រិកខាងកើត (Wharton.1957)។ ខ្លាធំ និងខ្លារខិន ចាត់ទុកជាប្រភេទសម្បូរបែប។ ក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ប្រទេសកម្ពុជា គឺជាប្រទេសគោលដៅនៃកីឡាប្រមាញ់ កម្សាន្តដ៏ធំមួយដែលល្បីល្បាញ ជាលក្ខណៈអន្តរជាតិ។ ខ្លាធំ និងខ្លារខិនត្រូវបានគេអនុញ្ញាតឱ្យធ្វើការប្រមាញ់ពេញ មួយឆ្នាំ លើកលែងតែ ដំរី ខ្ទីង ទន្សោង និងក្របីព្រៃ បាន អនុញ្ញាតឲ្យបរបាញ់តែក្នុងអំឡុងពេលខែធ្នូដល់ខែឧសភា ប៉ុណ្ណោះ (ក្រសួងព័ត៌មានប្រទេសកម្ពុជា ឆ្នាំ១៩៦០)។

ពីឆ្នាំ១៩៧០ ដល់ ១៩៩០ ចាប់តាំងពីដើមឆ្នាំ១៩៧០ មកកីឡាប្រមាញ់ត្រូវបាន បញ្ចប់ ហើយសត្វព្រៃពុំមានការគ្រប់គ្រងទេដោយសារតែ សង្គ្រាមស៊ីវិល។ ក្នុងរយៈពេលនោះស្ថានភាពខ្លាធំ និង សត្វព្រៃដទៃផ្សេងទៀតមិនត្រូវបានគេសិក្សាស្រាវជ្រាវ និង អភិរក្សឡើយ ហើយតាមការសន្និដ្ឋានសត្វព្រៃភាគច្រើន មិនសូវទទួលការគំរាមកំហែងទេ។

ពីឆ្នាំ១៩៩០ ដល់ ២០០០ ការអភិរក្សបានចាប់ផ្តើមឡើងជាផ្លូវការបន្ទាប់ពី ការិយាល័យការពារសត្វព្រៃនៃនាយកដ្ឋាន រុក្ខា និង ប្រមាញ់ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩២ ហើយនៅឆ្នាំ១៩៩៣ ព្រះបាទសម្តេច ព្រះនរោត្តមសីហនុ ព្រះបរមរតនកោដ្ឋ បានឡាយព្រះហស្ថលេខា លើព្រះរាជក្រឹត្យ ស្តីពីការបង្កើត តំបន់ការពារធម្មជាតិចំនួន ២៣កន្លែង នៅទូទាំងប្រទេស។ ការវាយតម្លៃទូទាំងប្រទេសជាលក្ខណៈប្រព័ន្ធលើកដំបូង ពីស្ថានភាពរបាយខ្លាធំ និងសត្វរំពាខ្លាធំ ត្រូវបានអនុវត្ត ក្នុងឆ្នាំ១៩៩៨ ដោយនាយកដ្ឋានសត្វព្រៃនិងជីវចម្រុះ ក្នុង នោះមានព្រានប្រមាញ់ចំនួន១៥៣នាក់ និង មន្ត្រីមូលដ្ឋាន ចំនួន១៥៦នាក់ នៅក្នុងខេត្តដែលមានព្រៃឈើចំនួន១៣ ខេត្ត ត្រូវបានសម្ភាសន៍ (Weiler et al. 1998 & Nowell etal.1999)។ ការសិក្សាស្រាវជ្រាវ និងសិក្ខាសាលាពី លទ្ធផលខាងលើបានកំណត់ថាតំបន់ទេសភាពអភិរក្សខ្លាធំដែលនៅសេសសល់ល្អបំផុតរួមមាន តំបន់ខ្ពង់រាបភាគខាងកើត តំបន់ខ្ពង់រាបភាគខាងជើង និងតំបន់ជួរភ្នំក្រវាញ ហើយការប្រមាញ់ខ្លាធំក៏មានច្រើនផងដែរ។

ពីឆ្នាំ២០០០ ដល់ ២០១០ កម្មវិធីអភិរក្សខ្លាធំគ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ គាំទ្រដោយ USFWS បានអនុវត្តចាប់ ពីឆ្នាំ២០០០ ដល់ ២០០៦ ដោយក្នុងនោះបានបង្កើតជាព្រៃការពារដែលជា ជម្រកខ្លាធំចំនួន ៣កន្លែង នៅក្នុងខេត្តព្រះវិហារ មណ្ឌលគិរី កោះកុង និងពោធិ៍សាត់។ ដៃគូអភិវឌ្ឍន៍ជាច្រើនធ្វើការងារ ខាងអភិរក្សខ្លាធំ បានបើកកិច្ចប្រជុំមួយដើម្បីពិនិត្យមើល នូវរាល់ទិន្នន័យខ្លាធំទាំងអស់ឡើងវិញសម្រាប់រៀបចំ សេចក្តីព្រាងកំណត់តំបន់អភិរក្សខ្លាធំ។ ជាលទ្ធផលបាន ប៉ាន់ស្មានថា មានចំនួនខ្លាធំពី៥ទៅ២០ក្បាលនៅតំបន់ខ្ពង់ រាបភាគខាងកើត ពី៥ទៅ២០ក្បាល នៅតំបន់ជួរភ្នំក្រវាញ និងពី១ ទៅ ១០ក្បាលនៅតំបន់ខ្ពង់រាបភាគខាងជើង (Weiler et al. 2006)។ ដូច្នេះការប៉ាន់ស្មានមានចំនួនសរុបមានពី២០ទៅ៥០ក្បាលនៅទូទាំងប្រទេស។ ការវាយតម្លៃនេះគឺជាមូលដ្ឋានគ្រឹះមួយសម្រាប់ចុះក្នុងបញ្ជី ក្រហមរបស់អង្គការ IUCN ឆ្នាំ២០១០ និងអនុសញ្ញា CITES ដែល

បានប៉ាន់ប្រមាណ ថាមានខ្លាធំចំនួនពី២០ ទៅ៥០ក្បាលនៅប្រទេសកម្ពុជា។

ពីឆ្នាំ២០១០ ដល់បច្ចុប្បន្ន ការពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពតំបន់អភិរក្ស ខ្លាធំទាំងអស់នៅកម្ពុជា បានផ្តួចផ្តើមគំនិតធ្វើការវិភាគ បន្ថែមទៀត ដោយមានការចូលរួមពីអ្នកជំនាញខាងខ្លាធំ អ្នកជីវសាស្ត្រនៅទីវាល អ្នករៀបចំគោលនយោបាយ និង អង្គការអភិរក្សនានា។ ការវិភាគបានបង្កើតនូវផែនទីចុង ក្រោយមួយកំណត់តំបន់ដែនជម្រកខ្លាធំ និងឯកសារជំរឿន សម្រាប់ការអភិរក្សតំបន់ដែនជម្រកខ្លាធំនៅកម្ពុជា។

ជាលទ្ធផលចុងក្រោយ ការអភិរក្សតំបន់ដែនជម្រក ខ្លាធំដែលត្រូវបានកែសម្រួលឡើងវិញ បានកំណត់យកតំបន់ ខ្ពង់រាបភាគខាងកើត និងតំបន់ជួរភ្នំក្រវាញ។ តំបន់ទាំង នោះគឺជាតំបន់នៅក្នុងប្រទេសកម្ពុជាដែលមានភស្តុតាង បញ្ជាក់ថា ខ្លាធំមួយចំនួននៅមានវត្តមានសេសសល់នៅ ឡើយ។ ប៉ុន្តែការរស់រានមានជីវិតរបស់ពួកវាត្រូវរងការ គំរាម កំហែងយ៉ាងធ្ងន់ធ្ងរពីសំណាក់ការប្រមាញ់សម្រាប់ ពាណិជ្ជកម្ម អន្តរជាតិ ការប្រមាញ់ពពួកសត្វរំពាខ្លាធំ និង ការបាត់បង់ទីជម្រក។ ដោយមើលឃើញនូវភាពចាំបាច់ ក្នុងការការពារសត្វខ្លាធំមិនឱ្យផុតពូជក្នុងព្រៃធម្មជាតិ រដ្ឋបាលព្រៃឈើក៏ បានផ្តួចផ្តើមរៀបចំផែនការសកម្មភាព អភិរក្សខ្លាធំនៅកម្ពុជា នេះឡើង។

### ២-បញ្ហាអាទិភាព

ចំនួនខ្លាធំជាសកលបានថយចុះពី១០.០០០ក្បាលមកត្រឹមប្រមាណ ៣.៥០០ក្បាលប៉ុណ្ណោះ ហើយនិន្នាការ នៃការថយចុះនេះកំពុងតែនៅបន្តទៅទៀត។ ដោយឡែក ចំពោះប្រទេសកម្ពុជាវិញ ចំនួនខ្លាធំមាននៅសេសសល់ តិចតួចមិនលើសពី៥០ក្បាលឡើយ។ បញ្ហាជាចម្បងដែល នាំឱ្យមានការថយចុះនូវចំនួនខ្លាធំមានដូចខាងក្រោម៖

~ ចំនួនខ្លាធំមានតិចតួច ហើយរាយប៉ាយតាមតំបន់ជាច្រើនដែលតំបន់នីមួយៗមិនអាចគាំទ្រដល់ការ រក្សាពូជបន្តបានគង់វង្ស

~ សកម្មភាពប្រមាញ់ខ្លាធំបានកើនឡើងខ្លាំងនៅក្នុងអំឡុងពេលដែលប្រទេសកម្ពុជាជួបនឹងបញ្ហាអសន្តិសុខក្នុងប្រទេស

~ ការប្រមាញ់ ប្រភេទសត្វរំពាខ្លាធំ បាននឹងកំពុងកើតមានឡើងដែលធ្វើឲ្យខ្វះចំណីដល់ខ្លាធំ

~ ការបាត់បង់ដែនជម្រកខ្លាធំធ្វើឲ្យពួកវាបម្លាស់ទីទៅ កាន់តំបន់ផ្សេងៗទៀត ហើយម៉្យាងទៀតសត្វរំពា ខ្លាធំក៏មានការប្រែប្រួល និងមិនអាចគាំទ្រដល់ការ រស់នៅរបស់ខ្លាធំដែរ

~ សកម្មភាពអភិរក្សសត្វព្រៃរបស់ប្រទេសជិតខាងធ្វើឲ្យប៉ះពាល់ដល់ការអភិរក្សសត្វព្រៃនៅក្នុងប្រទេស កម្ពុជា

~ ការអនុវត្តច្បាប់នៅមានកម្រិត ដោយសារខ្វះថវិកា សម្ភារក្នុងការល្បាត ការចំណាយលើការប្រតិបត្តិការបង្ក្រាប និងដឹកជញ្ជូនវត្ថុតាងនានា

~ កង្វះខាតនិរន្តភាពថវិកា សម្រាប់ធ្វើការគ្រប់គ្រងព្រៃការពារ និងតំបន់ការពារធម្មជាតិឱ្យមានប្រសិទ្ធភាព៕

## II- យុទ្ធសាស្ត្រ

គោលដៅរយៈពេលវែងនៃផែនការសកម្មភាពអភិរក្សខ្លាធំនៅកម្ពុជាត្រឹមឆ្នាំ២០២៦ គឺត្រូវស្តារ និងអភិរក្សតំបន់ស្នូលមិនអាចរំលោភបំពានបាន ក្នុងតំបន់ព្រៃការពារ មណ្ឌលគិរី និងតំបន់ជួរភ្នំក្រវាញ ជាតំបន់អាទិភាពសម្រាប់ស្តារខ្លាធំ។ យុទ្ធសាស្ត្រសំខាន់ៗនៃផែនការសកម្មភាពមានចំនួន ៥ដូចខាងក្រោម៖

~ យុទ្ធសាស្ត្រទី១៖ បង្កើតដែនជម្រកពូជខ្លាធំនៅក្នុងតំបន់ព្រៃការពារមណ្ឌលគិរី និងតំបន់ជួរ ភ្នំក្រវាញជាតំបន់ស្តារខ្លាធំ ដោយមានការការពារតឹងរ៉ឹង និងមិន មានការ រំខានដល់ទីជម្រកដោយមនុស្ស

~ យុទ្ធសាស្ត្រទី២៖ បង្កើនសមត្ថភាព និងប្រសិទ្ធភាព ភ្នាក់ងារអនុវត្តច្បាប់ក្នុងការការពារសត្វព្រៃ និងអភិរក្សទីជម្រក

~ យុទ្ធសាស្ត្រទី៣ ៖ បញ្ច្រាប ការគ្រប់គ្រងដែនជម្រក រក្សាពូជខ្លាធំទៅក្នុងផែនការអភិរក្ស

~ យុទ្ធសាស្ត្រទី៤៖ អនុវត្តពិធីសារត្រួតពិនិត្យខ្លាធំ និង សត្វរំពាខ្លាធំជាប្រចាំ

~ យុទ្ធសាស្ត្រទី៥ ៖ ពង្រឹងកិច្ចសហការតាមព្រំដែនដើម្បីកាត់បន្ថយការប្រមាញ់សត្វព្រៃ ឬធ្វើពាណិជ្ជកម្ម សត្វព្រៃខុសច្បាប់ឆ្លងកាត់ព្រំដែន។

## III- ផែនការសកម្មភាព

### ១ ផែនការសកម្មភាពនៃយុទ្ធសាស្ត្រទី១

~ គ្រប់គ្រងឱ្យបានតឹងរ៉ឹង តំបន់សម្រាប់ការដោះលែងខ្លាធំចូលទៅក្នុងព្រៃធម្មជាតិ

~ កំណត់តំបន់ សម្រាប់ការដោះលែងខ្លាធំក្នុងផែនការ គ្រប់គ្រងព្រៃការពារមណ្ឌលគិរី និងតំបន់ជួរភ្នំក្រវាញ

~ កំណត់ព្រំប្រទល់តំបន់ស្ដារខ្លាធំ

~ បង្កើតកន្លែងបង្កាត់ពូជខ្លាធំ និងធ្វើការបង្កាត់ពូជខ្លាធំ ដែលមានសុខភាពល្អ សម្រាប់ដោះលែងក្នុងដែនព្រៃធម្មជាតិ

~ រៀបចំកូនខ្លាធំជំទង់ៗ ដែលបានបង្កាត់ពូជសម្រាប់ជីវិតក្នុងដែនព្រៃធម្មជាតិ។

**លទ្ធផលរំពឹងទុក**

~ ដែនជម្រក រក្សាពូជខ្លាធំ ត្រូវបានបង្កើតឡើង

~ កំណត់ពេលវេលាច្បាស់លាស់សម្រាប់គ្រប់គ្រងតំបន់ស្ដារខ្លាធំ

~ ផែនការគ្រប់គ្រងតំបន់ស្ដារខ្លាធំ

~ កូនខ្លាធំនឹងត្រូវបានដោះលែង ក្នុងដែនជម្រកព្រៃធម្មជាតិ

~ ធានាបានពូជខ្លាធំក្នុងដែនព្រៃធម្មជាតិ។

### ២. ផែនការសកម្មភាពនៃយុទ្ធសាស្ត្រទី២

~ ជ្រើសរើសមន្ត្រីដែលមានសមត្ថភាពខ្ពស់ក្នុងការអនុវត្តច្បាប់ ពិសេសស៊ើបអង្កេតតាមដានបទល្មើស បង្ក្រាប និងចងក្រងសំណុំរឿងទៅតុលាការ

~ បណ្ដុះបណ្ដាលមន្ត្រីអនុវត្តច្បាប់

~ ផ្ដល់នូវសម្ភារចុះធ្វើការក្នុងព្រៃ

~ ផ្ដល់ថវិកាគ្រប់គ្រាន់ ដល់ក្រុមល្បាត និង មន្ត្រីអនុវត្ត ច្បាប់

~ កសាងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រង ឱ្យបានគ្រប់គ្រាន់ និងប៉ម

~ បង្កើនប្រសិទ្ធភាពការដើរល្បាតឱ្យបានញឹកញាប់ជាប្រចាំដើម្បីទប់ស្កាត់សកម្មភាពល្មើសច្បាប់នៅក្នុង តំបន់ព្រៃការពារ និងតំបន់ការពារធម្មជាតិ

~ ត្រួតពិនិត្យប្រតិបត្តិការដោយប្រើប្រព័ន្ធ SMART

~ បង្កើតប្រព័ន្ធព័ត៌មានតំបន់ដែនជម្រកស្ដារខ្លាធំ។

**លទ្ធផលរំពឹងទុក**

~ កាត់បន្ថយបទល្មើសព្រៃឈើ សត្វព្រៃ

~ មន្ត្រីអនុវត្តច្បាប់មានបរិមាណ និងមានសមត្ថភាពគ្រប់គ្រាន់

~ សកម្មភាពល្បាតមានការកើនឡើងនិងមានការត្រួតពិនិត្យច្បាស់លាស់។

### ៣. ផែនការសកម្មភាពនៃយុទ្ធសាស្ត្រទី៣

~ ធ្វើការសិក្សាវាយតម្លៃ លទ្ធភាពស្ដារខ្លាធំក្នុងតំបន់ខ្ពង់រាបភាគខាងកើត និងតំបន់ជួរភ្នំក្រវាញ

~ ទទួលស្គាល់ជាផ្លូវការ នូវការកំណត់តំបន់ដែនជម្រករក្សាពូជខ្លាធំ តាមរយៈផែនការ គ្រប់គ្រងព្រៃការពារ (មណ្ឌលគិរី ជួរភ្នំក្រវាញភាគកណ្ដាល និងជួរភ្នំក្រវាញ ភាគខាងត្បូង)

~ បង្កើតកម្មវិធីលើកកម្ពស់ការយល់ដឹងជាសាធារណៈ អំពីច្បាប់នានាទាក់ទងការអភិរក្សសត្វព្រៃនៅតំបន់ ដែនជម្រកស្ដារខ្លាធំ

~ បង្កើតយន្តការធ្វើសេចក្ដីសម្រេចចិត្តអន្តរស្ថាប័ននៅ ក្នុងតំបន់ដែនជម្រកស្ដារខ្លាធំ

~ បញ្ចូលការអភិរក្សខ្លាធំក្នុងផែនការថ្នាក់ជាតិ និងថ្នាក់ ក្រោមជាតិ។

**លទ្ធផលរំពឹងទុក**

~ គោលបំណង អភិរក្សខ្លាធំ ដោយផ្អែកលើវិទ្យាសាស្ត្រ ត្រូវបានពិចារណា និងបញ្ចូល យ៉ាងពេញលេញ ជាមួយក្រុមការងារធ្វើផែនការអភិរក្ស និងភ្នាក់ងារពាក់ព័ន្ធផ្សេងទៀត

~ ផែនការកំណត់តំបន់ និងគ្រប់គ្រងត្រូវបានអនុម័តយល់ព្រមក្នុងតំបន់ដែនជម្រកស្ដារខ្លាធំក្នុងតំបន់ព្រៃការពារ

~ ផែនការស្ដារដែនជម្រកឡើងវិញត្រូវបានបង្កើតឡើង ដើម្បីថែរក្សាទីជម្រកតភ្ជាប់គ្នា។

### ៤ ផែនការសកម្មភាពនៃយុទ្ធសាស្ត្រទី៤

~ បង្កើត និងបណ្ដុះបណ្ដាលក្រុមស្រាវជ្រាវ និងត្រួត ពិនិត្យខ្លាធំ

~ បង្កើតទិន្នន័យមូលដ្ឋានសម្រាប់ខ្លាធំ និងសត្វរំពាខ្លាធំនៅក្នុងតំបន់ដែនជម្រក និងធ្វើការសិក្សាស្រាវ ជ្រាវជាប្រចាំ ដើម្បីពិនិត្យមើលពីនិន្នាការចំនួនខ្លាធំ និងសត្វរំពាខ្លាធំ

~ បង្កើតពិធីសារត្រួតពិនិត្យខ្លាធំ និងសត្វរំពាខ្លាធំ

~ ធានាឲ្យមានសម្ភារ និងថវិកាគ្រប់គ្រាន់នៅទីវាលសម្រាប់សកម្មភាពសិក្សាស្រាវជ្រាវ។

**លទ្ធផលរំពឹងទុក**

~ មានទិន្នន័យខ្លាធំ និងសត្វរំពាខ្លាធំ

~ មានប្រព័ន្ធទិន្នន័យមូលដ្ឋាន

~ បង្កើតប្រព័ន្ធត្រួតពិនិត្យ ដែលមានលក្ខណៈឯកភាព(ស្តង់ដារ)ទូទាំងប្រទេស។

**៥ ផែនការសកម្មភាពនៃយុទ្ធសាស្ត្រទី៥**

~ បង្កើតយន្តការសហប្រតិបត្តិការ ដើម្បីប្រយុទ្ធប្រឆាំង សកម្មភាពខុសច្បាប់តាមព្រំដែន

~ បង្កើត និងបណ្តុះបណ្តាលក្រុមអនុវត្តច្បាប់ ដើម្បីឆ្លើយ តបចំពោះសកម្មភាពខុសច្បាប់តាមព្រំដែន

~ រៀបចំកិច្ចប្រជុំពិភាក្សាសម្របសម្រួលប្រចាំត្រីមាស សម្រាប់ផ្លាស់ប្តូរបទពិសោធន៍ពីសកម្មភាពល្បាត ដើម្បីពង្រឹងការអនុវត្តច្បាប់។

**លទ្ធផលរំពឹងទុក**

~ បង្កើនចំនួនសកម្មភាពល្បាតដើម្បីទប់ស្កាត់ការប្រមាញ់សត្វព្រៃនៅតាមបណ្តោយព្រំដែនជាមួយ នឹងការកាត់បន្ថយពាណិជ្ជកម្មឈើ និងសត្វព្រៃខុស ច្បាប់តាមបណ្តោយព្រំដែនអន្តរជាតិ

~ បង្កើតទំនាក់ទំនងរវាងស្ថាប័នពាក់ព័ន្ធសំខាន់ៗ នៅក្នុងប្រទេសកម្ពុជា និងប្រទេសជិតខាង ព្រមទាំង អាជ្ញាធរ CITES នគរបាលអន្តរជាតិInterpol និង អង្គការក្រៅរដ្ឋាភិបាលនានា ដែលពាក់ព័ន្ធនឹងការ ទប់ស្កាត់ការជួញដូរសត្វព្រៃល្មើសច្បាប់៕



**៦ឯកសារយោង៖**


1. ច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២។ ព្រះរាជាណាចក្រកម្ពុជា។
2. ប្រកាសលេខ០២០ ប្រក កសក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៧ ស្តីពីចំណាត់ថ្នាក់ និងបញ្ជីឈ្មោះប្រភេទសត្វព្រៃ។
3. Cambodia Minister De L'Information. 1960. Big Game Hunting in Cambodia (brochure).
4. Forestry Administration (FA) and Global Tiger Initiative (GTI). 2010. Draft National Tiger Recovery Program, Cambodia. Phnom Penh, Cambodia.




តំបន់ព្រៃការពារនិងតំបន់ការពារធម្មជាតិនៃប្រទេសកម្ពុជា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

# របាយការណ៍
## ស្តីពី
## សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំនព្វមាស ឆ្នាំ២០១៧ និងទិសដៅអនុវត្តបន្ត

### I- សភាពការណ៍រួម

នៅក្នុងនព្វមាស ឆ្នាំ២០១៧នេះ តាមការកត់សម្គាល់ឃើញថា មកទល់ពេលនេះស្ថានភាពទឹកភ្លៀងបានធ្លាក់រាយប៉ាយពីមធ្យមទៅច្រើននៅតាមបណ្តារាជធានី-ខេត្តទូទាំងប្រទេស។ ការងារបង្កបង្កើនផលស្រូវរដូវវស្សាសម្រេចបាន ១០៤,៥២% នៃផែនការ ២ ៤៥៦ ៧៩០ហ.ត និងមានវឌ្ឍនភាពល្អប្រសើរបើប្រៀបធៀបនឹងឆ្នាំមុន ហើយខេត្តចំនួន ១៦ បានបញ្ចប់ការងារដាំដុះដំណាំស្រូវរដូវវស្សាហើយ។ ការប្រើប្រាស់ដោយគ្រឿងយន្តសម្រាប់ផលិតកម្មកសិកម្មគឺមាននិន្នាការកើនឡើង ៩៣,៧៩% ធៀបនឹងការប្រើប្រាស់ដោយគោ-ក្របីមាន ៦,២១%។ រីឯការចូលរួមទប់ស្កាត់បទល្មើសផ្សេងៗទៀត ជាពិសេសបទល្មើសព្រៃឈើ បទល្មើសផលផល ក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង ព្រមទាំងបទល្មើសចលនាសត្វដោយខុសច្បាប់ ការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្មដែលនាំឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ម្យ៉ាងទៀត ព្រឹត្តិការណ៍សំខាន់ៗក្នុងខែកញ្ញា ឆ្នាំ២០១៧នេះគឺ ក្រសួងបានរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីមហាអនុតំបន់ទន្លេមេគង្គ (GMS) ព្រមទាំងកិច្ចប្រជុំសំខាន់ៗទៀត ការរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេសជាច្រើនផងដែរ។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងនព្វមាស ឆ្នាំ២០១៧នេះ មានដូចតទៅ៖

### II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

#### ១ ផ្នែកដាំដុះរដូវវស្សាឆ្នាំ២០១៧

##### ១.១ ផលិតកម្មដំណាំស្រូវ

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាគិតត្រឹមថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ មានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ២ ៨៩១ ៩៤២ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ១៧៩ ៥៣៥ហ.ត និងដោយគ្រឿងយន្តកសិកម្មមានចំនួន ២ ៧១២ ៤០៧ហ.ត តិចជាងឆ្នាំមុន ៦៤ ០៨៦ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ៤១ ៩១១ហ.ត តិចជាងឆ្នាំមុន ៨ ៦៥៣ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ២ ៦០៩ ៦១៧ហ.ត ស្មើនឹង១០៤,៥២% នៃផែនការ ២ ៤៥៦ ៧៩០ហ.ត លើសឆ្នាំមុនចំនួន ៦២ ៦០៣ហ.ត។

##### ១.២ ល្បឿនការងារប្រមូលផលស្រូវស្រាល

ការងារប្រមូលផលស្រូវស្រាលដើមរដូវរហូតមកដល់ពេលនេះ សម្រេចបានចំនួន ៣៤៨ ៦១៩ហ.ត លើផ្ទៃដីអនុវត្តសរុប ៦៨៦ ២៧០ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ១ ៣៩១ ៥៤៥តោន លើសឆ្នាំមុនចំនួន ៨៥២ ៨១៩តោន។ ទិន្នផលគិតជាមធ្យម ៣,៩៩តោន/ហ.ត តិចជាងឆ្នាំមុន ០៤គីឡូក្រាម/ហ.ត។

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ១
№ 200 Preah Norodom Blvd, Sangkat Tonle Bassak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

### ១.៣ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម

-ដំណាំរួមផ្សំអនុវត្តបានសរុបចំនួន ៧៩១ ៦១៨ហ.ត ស្មើនឹង១១១,៦៤% នៃផែនការ ៧០៩ ០៦០ហ.ត តិចជាងឆ្នាំមុនចំនួន ៣៩ ៥៨៩ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៧៧ ៧៦៥ហ.ត ស្មើនឹង៦៩,៧៨% នៃផែនការ ១១១ ៤៤០ហ.ត តិចជាងឆ្នាំមុនចំនួន ៦ ៣៧៥ហ.ត។

### ១.៤ ការនាំចេញអង្ករ

ក្នុងខែកញ្ញា ឆ្នាំ២០១៧នេះ ការនាំអង្ករចេញតាមរយៈច្រកចេញ-ចូលតែមួយគឺមានបរិមាណសរុបចំនួន ៤៩ ៧៧៦ តោន ដែលមានការកើនឡើងចំនួន ៨ ៣៤៧តោន (+២០,១០%) ធៀបនឹងបរិមាណនាំចេញក្នុងខែកញ្ញា ឆ្នាំ២០១៦។ សរុបរយៈពេល៩ខែដើមឆ្នាំ២០១៧ នាំចេញបានចំនួន ៤២១ ៩៦៦តោន (៩ខែដើមឆ្នាំ២០១៦នាំចេញបានចំនួន ៣៦១ ៥០៥ តោន (+១៦,៧០%)) ទៅកាន់ទិសដៅចំនួន ៦០ប្រទេស ក្នុងនោះប្រទេសចិនឈរលំដាប់ទី១ (១២៤ ៧៦០តោន) ប្រទេសបារាំងឈរលំដាប់ទី២ (៥៣ ៩១០តោន) ប្រទេសប៉ូឡូញឈរលំដាប់ទី៣ (៣៥ ៤៧២តោន) ប្រទេសអង់គ្លេសឈរលំដាប់ទី៤ (២៣ ៧៨១តោន) ប្រទេសនីដឺឡែនឈរលំដាប់ទី៥ (២១ ២៦៣តោន) ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៦ (១៩ ៥២៧តោន) ប្រទេសបែលហ្ស៊ិកឈរលំដាប់ទី៧ (១៥ ៥៥៣តោន) ប្រទេសបង់ក្លាដេសឈរលំដាប់ទី៨ (១៤ ០៧០តោន) ប្រទេសហ្គាបុងឈរលំដាប់ទី៩ (១២ ៦៤៨តោន) និងប្រទេសឆែកឈរលំដាប់ទី១០ (១២ ៥៧៨តោន)។ បច្ចុប្បន្នការនាំចេញអង្ករមានចំនួន ៧៦ក្រុមហ៊ុន។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអភិវឌ្ឍ ផលិតកម្មកៅស៊ូ

#### ២.១.១ ផ្ទៃដីកៅស៊ូ

ផ្ទៃដីកៅស៊ូសរុបមានចំនួន ៤៣២ ០៩៦ហ.ត ដែលក្នុងនោះ៖ ផ្ទៃដីចៀរជ័រមានចំនួន ១៦៣ ១៣០ហ.ត (៣៧,៧៧%) និងផ្ទៃដីថែទាំមានចំនួន ២៦៨ ៩៦៦ ហ.ត (៦២,២៣%)។ ទំហំផ្ទៃដីក្នុងខែកញ្ញានេះពុំមានការប្រែប្រួលទេ បើប្រៀបធៀបនឹងខែសីហា ឆ្នាំ២០១៧

#### ២.១.២ ផលិតកម្ម

ផលិតផលជ័រកៅស៊ូក្នុង៩មាស ឆ្នាំ២០១៧នេះ សរុបចំនួន ១១៥ ៨៤៣តោន បានកើនឡើងចំនួន ២៩ ០០១ តោន ស្មើនឹង៣៣% បើធៀបរយៈពេលដូចគ្នាទៅនឹងឆ្នាំ២០១៦។

#### ២.១.៣ បរិមាណបញ្ចេញលក់ជ័រកៅស៊ូ

បរិមាណបញ្ចេញលក់ជ័រកៅស៊ូក្នុង៩មាស ឆ្នាំ២០១៧នេះ មានចំនួនសរុប ១១៤ ៩៩១តោន បានកើនឡើងចំនួន ២៨ ២៦៨តោន ស្មើនឹង៣៣% បើធៀបរយៈពេលដូចគ្នាទៅនឹងឆ្នាំ២០១៦។ គួរកត់សម្គាល់ថា តម្លៃលក់ជ័រកៅស៊ូមធ្យមក្នុង៩មាស ឆ្នាំ២០១៧នេះ គឺ១ ៦៧២ដុល្លារ/តោន បានកើនឡើង ៥៧៨ដុល្លារ/តោន ស្មើនឹង៥៣% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០១៦។ តម្លៃលក់មធ្យមប្រចាំខែគឺ ១ ៦០២ ដុល្លារ/តោន បានកើនឡើង១០៧ ដុល្លារ/តោន ស្មើនឹង ៧,១៣% ធៀបនឹងខែសីហា ឆ្នាំ២០១៧ និងបានកើនឡើងចំនួន ៣៨៣ ដុល្លារ/តោន ស្មើនឹង៣១% ធៀបនឹងខែកញ្ញា ឆ្នាំ២០១៦ ។

#### ២.២.៣. ការប្រមូលចំណូលថវិកា

ក្នុង៩មាស ឆ្នាំ២០១៧នេះ ការប្រមូលចំណូលថវិកាបានចំនួនសរុប ១ ០៨៦ ៤១៥ ៧៤៦រៀល ពីថ្លៃឈ្នួលដីរបស់ក្រុមហ៊ុនចម្ការកៅស៊ូចម្ការអណ្ដូង មេមត់ ជុប ក្រែក ក្រុមហ៊ុននីហវ័ណកៅស៊ូ ( និងប្រាក់ពិន័យក្រុមហ៊ុនចម្ការកៅស៊ូស្នួល ចម្ការអណ្ដូង ៣មថាំង ឆ្នាំ២០១៦)។ រីឯការប្រមូលចំណូលថវិកាចូលរដ្ឋក្នុងខែកញ្ញាឆ្នាំ២០១៧ បានចំនួន ២៣ ៤២៤ ០៣៦រៀល។

### ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- បានចូលរួមកិច្ចប្រជុំគណៈកម្មការហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៧ របស់ IRRDB នៅប្រទេសម៉ាឡេស៊ី
- បានដាំដុះកូនកៅស៊ូលើកទី២ កៅស៊ូដាំឆ្នាំ២០១៧ ក្លូន MDX 624, FDR 5788 លើផ្ទៃដីទំហំ ១២,៥ហ.ត

២

- បានដាំដុះកូនកៅស៊ូលើថ្នាលបណ្ដុះកូនកៅស៊ូឆ្នាំ២០១៧-២០១៨
- បានថែទាំសម្ភារកម្មពូជដំណាំគម្របដីចំនួន ១៧ប្រភេទ
- បានចុះត្រួតពិនិត្យរោងចក្រកែច្នៃកៅស៊ូ CSR របស់ក្រុមហ៊ុនស៊ីហ្វូ វ៉ាប់ប៊ើរ លីមីតធីត នៅខេត្តរតនគិរី
- បានចុះវាស់ទំហំដើមកូនកៅស៊ូក្នុងឡូត៍ពិសោធន៍ក្លូននៅក្រុមហ៊ុនចម្ការកៅស៊ូ SOCFIN.KCD លើផ្ទៃដីទំហំ ៦,២៧ហ.ត
- បានលាបថ្នាំរំញោចចំនួន ១៥ចម្ការពិសោធន៍
- បានវាស់ទឹកជ័រតាមចម្ការពិសោធន៍នីមួយៗទាំងក្នុងនិងក្រៅស្ថានីយ
- បានវិភាគ DRC ចំនួន ០២ដងលើ ១៤ចម្ការពិសោធន៍ និងវិភាគ LD ចំនួន ០៣ចម្ការពិសោធន៍
- បានបាញ់ថ្នាំការពារ និងព្យាបាលជំងឺផ្កាកុលាបចំនួន ២លើក លើផ្ទៃដីចម្ការចំនួន ១៦២,៥ហ.ត។

## ៣ ផ្នែកកសិ-ឧស្សាហកម្ម

- បានពិនិត្យឡើងវិញនូវឧបករណ៍ពិសោធន៍ GC, HPLC, LC និងឧបករណ៍សម្រាប់វិភាគមីក្រូជីវសាស្ត្រ
- បានចុះយកសំណាក និងវិភាគរកកាកសំណល់ថ្នាំកសិកម្មដែលសេសសល់នៅក្នុងបន្លែដោយប្រើតេស្តឃីត GPO TM1
- បានចូលរួមទស្សនកិច្ចសិក្សាអំពីខ្សែសង្វាក់ផលិតកម្មកសិកម្មតាមកិច្ចសន្យានៅប្រទេសវៀតណាម
- បានរៀបចំ និងផ្ញើគម្រោងទៅ Korea Rural Economic Institute ស្ដីពីការបង្កើនសមត្ថភាពលើការវិភាគរកកាកសំណល់គីមី ថ្នាំកសិកម្ម និងលោហធាតុនៅក្នុងសណ្ដែក ពោត អង្ករ និងម្រេច
- បានរៀបចំសម្ភារ ឧបករណ៍ដើម្បីបណ្ដុះបាក់តេរីរកវត្តមាន E.coli និង Salmonella នៅក្នុងល្បិតអំបោះ ពងមាន់ និងពងទា
- បានចូលរួមសិក្ខាសាលាស្ដីពី ការវាយតម្លៃផលប៉ះពាល់ហិរញ្ញវត្ថុនៃការកែច្នៃជំឡូងមីនិងការកាត់បន្ថយហានិភ័យ និងការគ្រប់គ្រងជំងឺប្លាស់លើដំណាំស្រូវដោយប្រើសារធាតុ Trycyclazole
- បានប្រជុំជាមួយអ្នកជំនាញការចិនស្ដីពីការកែលម្អឡើងវិញលើប្រព័ន្ធបំពង់ខ្យល់លំហូរខ្យល់ក្នុងបន្ទប់ដាក់ឧបករណ៍ទំនើប បន្ទប់រក្សាទុកសំណាក និងកន្លែងទុកកាកសំណល់ពិសោធន៍
- បាននិងកំពុងធ្វើតេស្តវិភាគរកកាកសំណល់ថ្នាំគីមីកសិកម្មដោយប្រើប្រាស់ GPO Test Kits លើបន្លែចំនួន ០៧ប្រភេទ មានត្រសក់ ខ្ទឹ ស្ពៃបូកគោ ស្ពៃចង្កឹះ ស្ពៃតឿ ផ្កាខាត់ណា និងខាត់ណាដើម។

## ៤ ផ្នែកផលិតកម្ម និងបសុពេទ្យ

**៤.១ ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្ដុះបណ្ដាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្ដាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្ដាខេត្ត និងរាជធានីរៀងរាល់សប្ដាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) បន្តចុះអប់រំណែនាំ ផ្សព្វផ្សាយ ការអនុវត្តល្អប្រសើរក្នុងការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅតាមគ្រួសារកសិករចិញ្ចឹមសត្វ (គ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វនិងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើស្មូនដំណាំចំណីសត្វ ការផ្ដល់ពូជស្មៅដល់កសិករនិងភ្នាក់ងារសុខភាពសត្វភូមិ ក្រោមកិច្ចសហការបន្តជាមួយគម្រោង EU-PGAL។

**៤.២ ការងារបសុពេទ្យ**

• លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖ ក្នុងនព្វមាស ឆ្នាំ២០១៧ នេះ រាជធានី-ខេត្តចំនួន២៣ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ៣៨ ២៥២លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។ បទល្មើសសត្វនិង

៣

ផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យនិងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តទូទាំងប្រទេសបានចំនួន ៣៣ករណី ដោយបានកម្ទេចចោលផលិតផលខូចគុណភាពតាមវិធានបសុពេទ្យសរុបចំនួន ៦៥៤គីឡូក្រាម និងផាកពិន័យជាទឹកប្រាក់ចំនួន ៥០លានរៀល ព្រមទាំងបានណែនាំដល់អាជីវករដែលដឹកជញ្ជូនសត្វរស់ឱ្យប្រតិបត្តិជីវសុវត្ថិភាពពេញលេញដើម្បីការពារការឆ្លងរាលដាលនៃជំងឺផ្សេងៗ។

• **ការងារសុខភាពសាធារណៈ៖** ចុះត្រួតពិនិត្យជាប្រចាំលើទីតាំងស្នើសុំបង្កើតនិងបន្តសុពលភាពសត្តឃាតដ្ឋានប្រភេទ «ក» និង«ខ»តាមបណ្តារាជធានី-ខេត្ត។ រហូតមកទល់ពេលនេះសត្តឃាតដ្ឋានទទួលបានគោលការណ៍អនុវត្តចំនួន ១៥៥កន្លែង និងបានចុះត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋានឱ្យស្របតាមលក្ខណៈបច្ចេកទេស ដើម្បីសុខុមាលភាពសាធារណៈ។ ជាមួយនេះអង្គភាពជំនាញបានសហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចុះអន្តរាគមន៍សង្គ្រោះសត្វ និងចាក់ថ្នាំបង្ការជំងឺឆ្លងសត្វនៅតាមបណ្តាខេត្ត។

• **ការងារនីតិកម្មនិងវិវាទ៖** កំពុងបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វទៅតាមលំដាប់អាទិភាពមានជាអាទិ៍៖ សម្រេចបានប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យនិងអង្គភាពចំណុះនាយកដ្ឋាន និងវិទ្យាស្ថាននៃអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ។ សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីកិច្ចសម្របសម្រួលក្នុងការបង្កើតនិងគ្រប់គ្រងសត្តឃាតដ្ឋាន ព្រមទាំងបានរៀបចំកែសម្រួលអនុក្រឹត្យលេខ១០៨អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វឡើងវិញឱ្យស្របតាមច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ និងបានរៀបចំចងក្រងអនុក្រឹត្យនិងប្រកាសមួយចំនួនដើម្បីរៀបចំជាសៀវភៅផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត។

**៤.៣ ការងារស្រាវជ្រាវ៖**

• **ការងារស្រាវជ្រាវបសុព្យាបាល៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺនិងងាប់ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ៣ ៥៦៣វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺជាពិសេសមេរោគជំងឺផ្តាសាយបក្សី។

• **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោ-ក្របីភ្នំតាម៉ៅមានគោសរុបចំនួន ១១៥ក្បាល ក្នុងនោះគោបា ១ក្បាល គោប្រាម៉ាន់កាត់ ៦ក្បាល គោជំទង់ ៣៨ក្បាល គោបៅដោះ ៣០ក្បាល គោកំពែងសែន ៤០ក្បាល គោងាប់ ១៧ក្បាល និងគោកើតថ្មី ១ក្បាល។ ដោយឡែកនៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុប ៣២៩ក្បាល កូនជ្រូកលក់ ២៤០ក្បាល និងជ្រូកងាប់ ២៤ក្បាល។ ការបង្កាត់ពូជតាមបែបសិប្បនិម្មិតនិងធម្មជាតិប្រព្រឹត្តទៅជាប្រក្រតីនិងបានផ្សព្វផ្សាយបច្ចេកទេសបន្តទៅដល់កសិករ។

**៤.៤ ការងារផ្សព្វផ្សាយបច្ចេកទេស៖** ចងក្រងឯកសារការងារផលិតកម្មនិងបសុព្យាបាលសម្រាប់ចុះក្នុងទស្សនាវដ្តី រៀបចំកម្មវិធីផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល ជាពិសេសផ្សព្វផ្សាយដល់ប្រជាជនឱ្យយល់ដឹងពីជំងឺផ្តាសាយបក្សី ជំងឺជ្រូកត្រចៀកខៀវ និងជំងឺផ្សេងៗទៀតដែលអាចកើតឡើងជាយថាហេតុ រួមទាំងពង្រឹងយន្តការផ្សព្វផ្សាយតាមរយៈ ភ្នាក់ងារសុខភាពសត្វភូមិ។

## ៥ វិស័យព្រៃឈើ

### ៥.១ ការងារព្រៃឈើ

- បានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន ២១កន្លែង៖ ខេត្តពោធិ៍សាត់ចំនួន ១២កន្លែងមានផ្ទៃដីទំហំ ៦ ៣៩០ហ.ត ខេត្តស្ទឹងត្រែងចំនួន ៥កន្លែងមានផ្ទៃដីទំហំ ១៥ ៩៤២ហ.ត ខេត្តសៀមរាបចំនួន ៤កន្លែងមានផ្ទៃដីទំហំ ២ ៥៦៩ហ.ត និងខេត្តកំពង់ស្ពឺចំនួន ១៣កន្លែងមានផ្ទៃដីទំហំ ៤ ៦៦៦ហ.ត

- បានបញ្ជូនសេចក្តីព្រាងប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន ៧កន្លែង នៅក្នុងខេត្តព្រះវិហារដែលមានផ្ទៃដីទំហំ ៥ ៨៨១ហ.ត

- បានសម្របសម្រួលការសរសេរផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន ០២គឺ សហគមន៍ព្រៃឈើអូរចុងណា និងសហគមន៍ព្រៃឈើពីងប្រង់ក្លង់ពេសថ្ង នៅរដ្ឋបាលព្រៃឈើមណ្ឌលគិរី

- បានបង្កើតថ្នាលបណ្តុះកូនឈើចំនួន ១កន្លែង នៅព្រៃឈើផែគូសំរោង ស្ថិតនៅឃុំសំរោង ស្រុកភ្នំស្រួច ខេត្តពោធិ៍សាត់

៤

- បានចុះបើកវគ្គផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងការគ្រប់គ្រង និងការអនុវត្តលិខិតបទដ្ឋានច្បាប់សហគមន៍ព្រៃឈើ ផលប្រយោជន៍ព្រៃសហគមន៍ និងនីតិវិធីទប់ស្កាត់បទល្មើសព្រៃសហគមន៍ចំនួន ១៤ វគ្គ ដល់ សហគមន៍ព្រៃឈើចំនួន ១៤ នៅខេត្តចំនួន ៧ រួមមាន ខេត្តមណ្ឌលគិរី ស្វាយរៀង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ ក្រចេះ និងខេត្តព្រះវិហារ ដែលមានអ្នកចូលរួមសរុបចំនួន ៥៩៣ នាក់ ក្នុងនោះមានស្ត្រីចំនួន ២៤៣ នាក់។

### ៥.២ ការអភិរក្សសត្វព្រៃ

- បានចុះអន្តរាគមន៍ទប់ស្កាត់ និងបង្ក្រាបការជួញដូរសត្វព្រៃចំនួន ៦លើក នៅខេត្តព្រះវិហារ ស្ទឹងត្រែង រតនគិរី ខេត្តមណ្ឌលគិរី និងខេត្តកំពង់ធំ ដោយចាប់ឃាត់បាន នូវអន្ទាក់មងសម្រាប់ចាប់សត្វស្លាបបានចំនួន ៣ខ្សែ ដកហូតសត្វក្រកូតរស់បានចំនួន ២ក្បាល កាំបិត ៦ថ្លៃ អប់រំណែនាំអ្នកលក់សាច់សត្វព្រៃបានចំនួន ៤ករណី និងបានអប់រំផ្សព្វផ្សាយដល់ប្រជាជនឲ្យមានការយល់ដឹងច្បាប់ស្តីពីព្រៃឈើបានចំនួន ៦លើក

- បានចុះសិក្សាស្រាវជ្រាវ និងប្រមូលទិន្នន័យសត្វព្រៃចំនួន ៦លើក នៅខេត្តឧត្តរមានជ័យ ព្រះវិហារ បាត់ដំបង កំពត ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង ដោយបានកត់ត្រាប្រភេទសត្វព្រៃសរុបចំនួន ១៦៥ប្រភេទ ក្នុងនោះថនិកសត្វមានចំនួន ៣៤ប្រភេទ សត្វស្លាបមានចំនួន ១០៨ប្រភេទ និងសត្វល្មូនមានចំនួន ២៣ប្រភេទ

- បានចុះសិក្សាទីតាំងរោងចក្រកែច្នៃរោមនិងស្បែកសត្វរបស់ក្រុមហ៊ុន ស៊ីកែល (ខេមបូឌា) និងក្រុមហ៊ុនសាន់ជូហ្វៀប្រូសេស៊ីង (ខេមបូឌា) ដែលស្នើសុំនាំចូលរោម និងស្បែកសត្វជាប់រោម នៅខណ្ឌដង្កោ រាជធានីភ្នំពេញ

- បានចុះសិក្សាស្វែងយល់ និងប្រមូលទិន្នន័យការចិញ្ចឹមសត្វព្រៃជាលក្ខណៈគ្រួសារ និងកសិដ្ឋានចំនួន ២២ នៅខេត្តកំពង់ចាម ពោធិ៍សាត់ កំពង់ធំ កំពង់ឆ្នាំង កំពង់ស្ពឺ កោះកុង ព្រះសីហនុ និងខេត្តកំពត។

### ៥.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជសត្វព្រៃ និងការសង្គ្រោះសត្វព្រៃ

- សម្រាប់នព្វមាស ឆ្នាំ២០១៧ នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ២៩៣ ក្បាល (បក្សីចំនួន ៤៩ ប្រភេទ ថនិកសត្វចំនួន ៤២ ប្រភេទ និងល្មូនចំនួន ១២ ប្រភេទ) សង្គ្រោះសត្វថ្មីចំនួន ១ ៣០០ក្បាល ព្យាបាលសត្វព្រៃរបួសឈឺចំនួន ៣១៣ក្បាល ស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញនូវសត្វព្រៃគ្រប់ប្រភេទចំនួន ១ ១៧៥ក្បាល ដោយខ្សែកគម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិ៖ ក្រុមល្បាតសហគមន៍ចំនួន ៣០នាក់ បានដើរល្បាតនៅតំបន់ជម្រកក្រពើសំខាន់ៗចំនួន ៥រួមមាន នៅអារ៉ែង ឆាយាប តំបន់ស្តារក្រពើស្ទឹងជាច់ ស្ទឹងខ្មៅ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់) និងសហការជាមួយនឹងអង្គការព្រាហ្មវិហារធម៌ ដោយបង្រៀនបច្ចេកទេសកសិកម្មដល់កសិករចំនួន ១១៧នាក់ និងបច្ចេកទេសចិញ្ចឹមសត្វមានចំនួន ២០នាក់ នៅក្នុងតំបន់ជែនជម្រកក្រពើឆាយាប ក្នុងភូមិពោធិ៍បឹង ស្រុកស្រែអំបិល ខេត្តកោះកុង និងស្រុកវាលវែង ខេត្តពោធិ៍សាត់ និងបានចែកពូជស្រូវចំនួន ១៥០គីឡូក្រាម

- បានសហការជាមួយនឹងអ្នកជំនាញក្រពើពីសហរដ្ឋអាមេរិកបង្រៀនពីវិធីសាស្ត្រ បច្ចេកទេសចាប់ក្រពើ និងការភ្ជាស់ពងដល់មន្ត្រីអភិរក្សក្រពើចំនួន ៥នាក់ និងមន្ត្រីជាប់កិច្ចសន្យារបស់ឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅចំនួន ៦នាក់

- បានជួសជុលផ្លូវលុបសំបុកមាន់ដែលក្រាលក្រួសក្រហមប្រវែង ១០គីឡូម៉ែត្រ កាប់ឆ្ការអនាម័យព្រៃទំហំ ២៧ ហ.ត ជួសជុលទ្រុងសត្វ និងសំណង់ផ្សេងៗបានទំហំ ៥៦២ម៉ែត្រការ៉េ។

### ៥.៤ ការងារដាំដើមឈើ

- បានចុះស្រាវជ្រាវ និងសិក្សាទីតាំងសម្រាប់ការដាំឈើ

- បានចុះពង្រឹងការងារដាំឈើ និងការបណ្តុះកូនឈើនៅតាមបណ្តាស្ថានីយ ថ្នាលបណ្តុះកូនឈើរបស់រដ្ឋ និងក្រុមហ៊ុនឯកជន

- បានផ្សព្វផ្សាយ និងពិគ្រោះយោបល់ស្តីពីការលើកកម្ពស់ការអនុវត្តបច្ចេកទេសគ្រប់គ្រងថ្នាលបណ្តុះកូនឈើ

- បានធ្វើបច្ចុប្បន្នភាពផ្ទៃដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ

- បានចុះតាមដានត្រួតពិនិត្យ និងវាយតម្លៃការងារដាំឈើដោយសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានពីកប្រឡាយការពារតំបន់ចម្ការឈើដាំនៃស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើក្រសាំង (ខេត្តស្វាយរៀង) និងអូរបឹងរូង (ខេត្តកំពង់ធំ)

- បានស្នើសុំចុះបញ្ជីដីរដ្ឋពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ លើផ្ទៃដីស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើចំនួន ២១កន្លែងដែលទើបបានបង្កើតថ្មីមានផ្ទៃដីទំហំ ១០២ ៨៦៣ហ.ត ស្ថិតក្នុងខេត្តចំនួន ៤៖ ខេត្តក្រចេះ ស្ទឹងត្រែង សៀមរាប និងខេត្តព្រះវិហារ

- បានចុះពង្រឹងការងារដាំឈើ និងការបណ្ដុះកូនឈើនៅតាមបណ្ដាស្ថានីយថ្នាលបណ្ដុះកូនឈើរបស់រដ្ឋ និង ក្រុមហ៊ុនឯកជនស៊ុងបាយអូរថេក ចំនួន ១លើក ក្រុមហ៊ុនបានសម្អាតដីចំនួន ៣៦០ហ.ត និងបានត្រៀមដាំឈើក្នុងពេលខាងមុខ។

### ៥.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- បានចុះពិនិត្យដល់ទីតាំងជាក់ស្ដែងតាមលក្ខណៈបច្ចេកទេសដើម្បីពិនិត្យសម្រេចចំពោះក្រុមហ៊ុនចំនួន ២៨ដែលស្នើសុំបន្តសុពលភាពរោងម៉ាស៊ីនអារ កែច្នៃឈើ និងក្រុមហ៊ុនចំនួន ៨ ដែលបានស្នើសុំបង្កើតរោងសិប្បកម្មកែច្នៃឈើចំនួន ១១កន្លែង

- ក្រុមហ៊ុនចំនួន ៩ បាននាំចេញផលិតផលរានទេវតា និងឈើកែច្នៃ ៧ ០៩៥ម៣

- ផ្ដល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុន ចំនួន ១១ មានបរិមាណឈើកែច្នៃ ចំនួន ៨ ៨៥៦ម៣ ជ័រទឹក ចំនួន ៤៥៥តោន និងឬងអាកាស្យាចំនួន ២៧តោន

- ផ្ដល់ទិដ្ឋាការជូនក្រុមហ៊ុនចំនួន ០៤ នាំចូលឈើ Plywood Paticle Board Radiata MDF Chanfuta Umbila និង Wood Panel មានបរិមាណសរុបចំនួន ៤ ២១០ម៣ ពីប្រទេសចិន កូរ៉េ វៀតណាម ជប៉ុន សហរដ្ឋអាមេរិក នីហ្សេរីយ៉ា ញូហ្ស៊ីលែន និងប្រទេសម៉ូហ្សំប៊ិក

- ផ្ដល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលចំនួន ៤ក្រុមហ៊ុន មានបរិមាណឈើកែច្នៃចំនួន ៥ ៣៥៩ ម៣ ។

### ៥.៦ ការងារចំណូលព្រៃឈើ

- សម្រាប់នព្វមាស ឆ្នាំ២០១៧នេះ ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើសរុបចំនួន ២១ ៣៨៩ ៩០៣ ៨៦៦រៀល និងចំណូលពីសេវាសាធារណៈចំនួន ៤ ២៦៧ ៨៣៩ ៧០៣រៀល និង១៤៤ ៤៨៨,៩៤ដុល្លារអាមេរិក។

### ៥.៧ ការងារនីតិកម្មនិងវិវាទ

- សម្រាប់នព្វមាស ឆ្នាំ២០១៧នេះ សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃសរុបចំនួន ៩៦៣ ករណី ដោយពិន័យអន្តរការណ៍ចំនួន ៤២៧ ករណី និងបញ្ជូនទៅតុលាការមានចំនួន ៥៣៦ករណី

- ដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន ៣៧៩ម៣ ឈើអារចំនួន ២ ២៥១ម៣ ឈើគ្រាក់គ្រញូងចំនួន ៣៣ម៣ និង ១ ៩៧៥គីឡូក្រាម សត្វព្រៃចម្រុះប្រភេទចំនួន ៣ ៨៣០ក្បាល និង១ ៦៩៦គីឡូក្រាម និងអនុផលព្រៃឈើព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត

- សំណុំរឿងបទល្មើសកាប់រានដីព្រៃចំនួន ២០ករណី មានផ្ទៃដីព្រៃកាប់រានចំនួន ៥០៤ហ.ត ត្រូវបានបញ្ជូនទៅតុលាការ និងដកហូតរណាយន្តបានចំនួន ៤៧គ្រឿង

- បានចុះពង្រឹងការអនុវត្តច្បាប់ចំនួន ៦៨ លើក

- បន្តដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ (Case Tracking System-CTS) ដើម្បីរៀបចំឱ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប។

## ៦ វិស័យជលផល

### ៦.១ ផលិតកម្មនេសាទ

#### ៦.១.១ នេសាទទឹកសាប

- នេសាទគ្រួសារក្នុងដែននេសាទ អនុវត្តបានចំនួន ១៩២ ៦៥០តោន ស្មើនឹង៥៦,០០% នៃផែនការ ៣៤៤ ០០០ តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ ថយចុះចំនួន ១៣ ៣៥០តោន

- នេសាទគ្រួសារតាមវាលស្រែ អនុវត្តបានចំនួន ៧៥ ៦០០តោន ស្មើនឹង៥២,៥០% នៃផែនការ ១៤៤ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៤ ០០០តោន។

### ៦.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ៨៦ ៨២៥តោន ស្មើនឹង៧៨,៩៣% នៃផែនការ ១១០ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ១ ៤២៥តោន។

### ៦.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គា អនុវត្តបានចំនួន ១៦៧ ៤៦៣តោន ស្មើនឹង៩៦,៩១% នៃផែនការ ១៧២ ៨០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ២៤ ១១៣តោន

- ការចិញ្ចឹមក្រពើ អនុវត្តបានចំនួន ២៣៨ ៣០០ក្បាល ស្មើនឹង៩៥,៣២% នៃផែនការ ២៥០ ០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ១ ៣០០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ១៥១ ៥០០ ០០០កូន ស្មើនឹង៨៤,១៧% នៃផែនការ ២០០ ០០០ ០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួនប្រមាណ ២ ៥០០ ០០០កូន។

### ៦.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទ អនុវត្តបានចំនួន ៤១ ៣០០តោន ស្មើនឹង៥០,៣៧% នៃផែនការ ៨២ ០០០ តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ ថយចុះចំនួន ៥ ៤០០តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ៨ ៣៤០តោន ស្មើនឹង១០៤,២៥% នៃផែនការ ៨ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ១៥តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ៤៤ ៨០០ ០០០លីត្រ ស្មើនឹង៨៩,៦០% នៃផែនការ ៥០ ០០០ ០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៣០០ ០០០លីត្រ។

### ៦.៤ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់ អនុវត្តបានចំនួន ៦ ៩៥០តោន ស្មើនឹង៤៦,៣៣% នៃផែនការ ១៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ១៥០តោន

- ផលនេសាទកែច្នៃ អនុវត្តបានចំនួន ៣ ៨៨០តោន ស្មើនឹង៧៧,៦០% នៃផែនការ ៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ១៨០តោន។

### ៦.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល

- សម្រាប់នព្វមាស ឆ្នាំ២០១៧នេះ សំណុំរឿងបទល្មើសជលផលមានចំនួន ២ ៨៧០ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ២ ៦៨៧ករណី និងសមុទ្រចំនួន ១៨៣ករណី

- ចុះរុះរើនិងបំផ្លាញចោលវត្ថុតាងបទល្មើសជលផលរួមមាន៖ របាំងស្នែស្បមុងនិងសាច់អួនប្រវែង ១ ២៤១ ៨១៦ម៉ែត្រ បង្គោល/ចម្រឹងចំនួន ៦២៦ ០១២ដើម លូស្នែស្បមុងនិងសាច់អួនចំនួន ១៧ ២៨១មាត់ របាំងព្រួលឫស្សីប្រវែង ៤ ២៤៨ម៉ែត្រ សម្រាស់ទំហំ ៣៧ ៧១៨ម៉ែត្រក្រឡា ឧបករណ៍ឆក់ត្រីចំនួន ៣៧២គ្រឿង និងលែងត្រីចម្រុះចូលក្នុងបឹងធម្មជាតិចំនួន ៦០ ៣៩៤គ.ក្រ និងពិន័យអន្តរការណ៍ចំនួន ៦២ករណី ស្មើនឹងទឹកប្រាក់ចំនួន ២០១ ៧៥០ ០០០រៀល

- បានផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានក្រោមច្បាប់ពាក់ព័ន្ធចំនួន ១៧៨វគ្គ ដោយមានអ្នកចូលរួមចំនួន ៦ ៦១៩នាក់។

### ៦.៦ ការប្រមូលថវិកា

- ចំណូលពីវិស័យជលផលក្នុងនព្វមាស ឆ្នាំ២០១៧ ចំនួន ២ ៥៧៧ ១១១ ១៨៣រៀល ស្មើនឹង៨៥,៩០% នៃផែនការ ៣ ០០០ ០០០ ០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៩៩២ ៦៨៥ ៥៤៣រៀល។

## ៧ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ចុះពិនិត្យ និងវាយតម្លៃពិសោធន៍នានាក្នុងរដូវវស្សានៅតាមបណ្តាខេត្តគោលដៅ
- បន្តអភិរក្សពូជស្រូវ ចេក និងដំណាំផ្សេងៗនៅក្នុងវិទ្យាស្ថាន
- រៀបចំពិធីការ និងសម្ភារសម្រាប់ពិសោធន៍រដូវវស្សាឆ្នាំ២០១៧
- បន្តរៀបចំ និងបោះពុម្ពអត្ថបទព័ត៌មាន ព្រឹត្តិបត្រស្រាវជ្រាវ និងទស្សនាវដ្តីកសិកម្មកម្ពុជារបស់វិទ្យាស្ថាន
- បានប្រារព្ធពិធីប្រកាសដាក់ឱ្យប្រើប្រាស់សៀវភៅលទ្ធផលស្រាវជ្រាវចំនួន៣គឺ (១)សៀវភៅសមិទ្ធផលនៃការស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យា (១៩៩៩-២០១៧) (២)សៀវភៅ Catalog ពូជស្រូវសម្រាប់កម្ពុជាទី៤ និង (៣)សៀវភៅ

ពូជដំណាំដែលបានបញ្ចេញ និង ខួបទី១៨ឆ្នាំរបស់វិទ្យាស្ថាន ដែលមានអ្នកចូលរួមប្រមាណ១៥០រូប និងបានបែងចែកសៀវភៅទាំង៣ក្បាលនេះសរុបចំនួន៦០០ក្បាលជូនដល់ថ្នាក់ដឹកនាំនិងអ្នកពាក់ព័ន្ធទាំងអស់

- បាននិងកំពុងធ្វើពិសោធន៍ចំនួន៥៧ប្រភេទ លើប្រមាណ ៤០០កន្លែង នៅវិទ្យាស្ថាននិងតាមបណ្តាខេត្តនានា

- បានចែកគ្រាប់ពូជស្រូវជូនដល់កសិករចំនួន ៥៨៣គ្រួសារ សម្រាប់ផលិតទុកពូជបន្ត ដែលក្នុងមួយគ្រួសារចំនួន ០៥គ.ក្រ សរុបចំនួន ២ ៩១៥គ.ក្រ និងបានយកអង្ករពូជស្រូវដំណើបស្បៃមង្គលទៅចែកជូនដល់សហគមន៍ក្រឡានថ្មីត្រែ ខេត្តក្រចេះឲ្យដុតក្រឡានដោយពួកគាត់បានទទួលស្គាល់ថាក្រឡានអង្ករដំណើបស្បៃមង្គលថាមានរសជាតិឆ្ងាញ់និងល្អហើយ បានចែកពូជស្រូវដំណើបស្បៃមង្គលដល់សហគមន៍ចំនួន១០០គីឡូក្រាម

- លទ្ធផលពិសោធន៍តាមដានរកពូជស្រូវធន់ទៅនឹងជំងឺខ្វារអំបោះខ្មៅតក្នុងលក្ខខណ្ឌផ្ទះសំណាញ់ បានបង្ហាញថា ពូជស្រូវដំណើបស្បៃមង្គល និងពូជស្រូវខា១៤ មានការធន់ទ្រាំនឹងជំងឺខ្វារអំបោះខ្មៅត

- បានចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតក្រៅប្រទេសចំនួន១៨លើក ដែលមានថ្នាក់ដឹកនាំនិងមន្ត្រីវិទ្យាស្ថានចូលរួមចំនួន២៨នាក់។ មន្ត្រីចំនួន ០២រូប បានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតនៅប្រទេសកូរ៉េ និងនៅប្រទេសអូស្ត្រាលី ០១រូប បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅប្រទេសថៃ និងមន្ត្រីសរុបចំនួន ០៥រូបទៀតបាននិងកំពុងបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងថ្នាក់បណ្ឌិតនៅក្រៅប្រទេស។

## ៨ ផ្នែកនីតិកម្មកសិកម្ម (ត្រឹមខែកញ្ញា ឆ្នាំ២០១៧)

### ៨.១ ការងារអាជីវកម្មសម្ភារកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាសម្ភារកសិកម្មបានចំនួន ១៤ក្រុមហ៊ុន សរុបចំនួន ១៩២មុខ
- ផ្តល់លិខិតអនុញ្ញាតនាំចូលសម្ភារកសិកម្មចំនួន ១៩ក្រុមហ៊ុន
- ចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ០៥ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ០៨ក្រុមហ៊ុន។

### ៨.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគសារធាតុលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំចុះបញ្ជិកាចំនួន ០៦ក្រុមហ៊ុនសរុបចំនួន ៣០សំណាក។

### ៨.៣ ការងារបណ្តុះបណ្តាល អប់រំ និងលើកកម្ពស់ការយល់ដឹង

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្តីពី បទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសក្នុងការគ្រប់គ្រង និងការធ្វើអាជីវកម្មសម្ភារកសិកម្មនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកណ្តាល ប៉ៃលិន បាត់ដំបង ពោធិ៍សាត់ រតនគិរី មណ្ឌលគិរី និងខេត្តក្រចេះ។

### ៨.៤ ការងារអនុវត្តច្បាប់

- បានធ្វើប្រតិវេទន៍ដល់ក្រុមហ៊ុនចំនួន ០៦ក្រុមហ៊ុន

- ពិន័យអន្តរការណ៍ជាប្រាក់ចំនួន ២៩ ២០០ ០០០រៀល ពីក្រុមហ៊ុនចំនួន ០១ និងអាជីវករលក់ដុំ លក់រាយចំនួន ១៥ដេប៉ូ។

## ៩ ផ្នែករដ្ឋបាល

- ក្នុងនព្វមាស ឆ្នាំ២០១៧នេះ បានទទួលលិខិតពីក្រសួង-ស្ថាប័ននានាចំនួន ២ ៧៨៥ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ២ ៩៩៤ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១ ២២៧ច្បាប់ និងចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តរដ្ឋបាល

- បញ្ជូនឯកសារនិងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ៨ ៥០១ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ៥៤៣ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទចំនួន ២០០ច្បាប់

- បានចេញប្រកាសព័ត៌មានស្តីពីការទប់ស្កាត់ការនាំចូលជ្រូកពីក្រៅប្រទេសមកកាន់ព្រះរាជាណាចក្រកម្ពុជា ដែលធ្វើឱ្យប៉ះពាល់ដល់ការចិញ្ចឹមជ្រូកក្នុងស្រុក

- បានចេញសេចក្តីជូនដំណឹងស្តីពីការនាំចូលសត្វរស់ សាច់សត្វ និងផលិតផលសត្វដើម្បីផ្គត់ផ្គង់បំពេញតម្រូវការសាច់នៅរាជធានីភ្នំពេញ និងបណ្តាខេត្ត ដើម្បីពង្រឹងការគ្រប់គ្រងហានិភ័យនៃការឆ្លងរាលដាលនៃជំងឺសត្វ ការលើកកម្ពស់គុណភាពសាច់សត្វ និងការពារសុខុមាលភាពសាធារណៈប្រកបដោយសុវត្ថិភាព

៨

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំ ពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម) ។

## ១០ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៦ ៧៥១នាក់ ក្នុងនោះនារីចំនួន ១ ៥២៧នាក់ ស្មើនឹង ២២% រួមមាន៖
    + អង្គភាពថ្នាក់កណ្តាលចំនួន ២ ៧៦១នាក់ ក្នុងនោះនារីចំនួន ៧៨២នាក់ ស្មើនឹង ២៨%
    + អង្គភាពថ្នាក់ក្រោមជាតិចំនួន ៣ ៣៩០នាក់ ក្នុងនោះនារីចំនួន ៧៤៥នាក់ ស្មើនឹង ២១%
- បានតែងតាំង ដំឡើងឋានៈ និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការសរុបមានចំនួន ៣៣៤នាក់ ក្នុងនោះនារីចំនួន ៨៦នាក់
- បានចេញប្រកាសលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌមានចំនួន ២៦នាក់ ក្នុងនោះបោះបង់ចោលការងារមានចំនួន ០៥នាក់ សុំលាឈប់ពីការងារមានចំនួន ០៩នាក់ និងទទួលមរណភាពមានចំនួន ១២នាក់
- បានចេញប្រកាសផ្ទេរមន្ត្រីរាជការក្រៅក្រសួងមានចំនួន ២១នាក់ក្នុងនោះ ផ្ទេរចេញមានចំនួន ១២នាក់ និងផ្ទេរចូលមានចំនួន ០៩នាក់ ផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងមានចំនួន ៩៧នាក់
- បានចុះបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីកសិកម្ម អង្គភាពថ្នាក់កណ្តាល និងថ្នាក់ក្រោមជាតិ លើការងាររដ្ឋបាល និងបុគ្គលិកបាន ០២តំបន់
- បានចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកពីការងារមានចំនួន ៨៧នាក់ ក្នុងនោះមាន៖ ច្បាប់ឈប់សម្រាកប្រចាំឆ្នាំមានចំនួន ៤៤នាក់ ច្បាប់ព្យាបាលជំងឺមានចំនួន ១៣នាក់ និងច្បាប់សម្រាកមាតុភាពមានចំនួន ៣០នាក់
- បន្តរៀបចំធ្វើប័ណ្ណសម្គាល់ខ្លួនរបស់មន្ត្រីកសិកម្ម ដល់អង្គភាពថ្នាក់កណ្តាល និងថ្នាក់ក្រោមជាតិ
- បានពិនិត្យ កែតម្រូវលើការប្រែប្រួលស្ថានភាពរដ្ឋបាលពីខែមករា ដល់ខែតុលា ឆ្នាំ២០១៧
- បានចេញប្រកាសដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សមានចំនួន ៨៨នាក់ ក្នុងនោះនារីចំនួន ១៧នាក់
- បានចេញប្រកាសឲ្យមន្ត្រីរាជការ ចូលបម្រើការងារនៅអង្គភាពដើមវិញមានចំនួន ៥៨នាក់ ក្នុងនោះនារីចំនួន ១៣នាក់
- បានចេញប្រកាសដាក់មន្ត្រីឲ្យចូលនិវត្តន៍ និងបាត់បង់សម្បទាវិជ្ជាជីវៈមានចំនួន ១១៥នាក់ ក្នុងនោះនារីចំនួន ០៣នាក់
- បានបែងចែកមន្ត្រីជាប់កិច្ចសន្យាសម្រាប់ប្រើប្រាស់ឆ្នាំ២០១៧ នៅអង្គភាពថ្នាក់កណ្តាល និងថ្នាក់ក្រោមជាតិចំនួន១ ០២៤នាក់
- ត្រៀមរៀបចំប្រឡងជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មី ដែលក្រសួងមុខងារសាធារណៈបែងចែកឲ្យមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានចំនួន ១៨៤នាក់
- មន្ត្រីរាជការបានចូលរួមការងារបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេសសរុបមានចំនួន ១ ១៤២នាក់ ក្នុងនោះនារីចំនួន ៣០៦នាក់។

## ១១ ការធ្វើសវនកម្មផ្ទៃក្នុង

- បានចុះធ្វើសវនកម្មចំនួន ៣៨អង្គភាព ស្មើនឹង៨២,៦០% នៃផែនការ៤៦អង្គភាព
- បានធ្វើតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះឆ្នាំ២០១៦
- បានធ្វើផែនការសកម្មភាពលម្អិត និងផែនការថវិកាឆ្នាំ២០១៧ ដើម្បីអនុវត្តសកម្មភាពរួមដំណាក់កាលទី៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានធ្វើរបាយការណ៍តាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីប្រចាំត្រីមាសទី១ ឆ្នាំ២០១៧
- បានធ្វើផែនការយុទ្ធសាស្ត្រថវិកាកម្មវិធីឆ្នាំ២០១៨-២០២០
- បានធ្វើការស្នើសុំរៀបចំផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុងឆ្នាំ២០១៨-២០២០ និងគម្រោងផែនការថវិកាកម្មវិធីសម្រាប់ឆ្នាំ២១០៨ ទម្រង់ P4

- បានធ្វើការស្នើសុំការអនុញ្ញាតរៀបចំបើកវគ្គបណ្តុះបណ្តាលស្តីពី "បច្ចេកទេសសវនកម្មលើគម្រោងឥណទានក្រៅប្រទេស" ដល់មន្ត្រីនាយកដ្ឋានសវនកម្មផ្ទៃក្នុង

- បានរៀបចំកិច្ចប្រជុំជាមួយប្រតិភូសវនកម្មផ្ទៃក្នុងក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ ដើម្បីចុះពិនិត្យប្រសិទ្ធភាពលើមុខងារសវនកម្មផ្ទៃក្នុង

- បានបញ្ជូនរបាយការណ៍តាមដាននិងវាយតម្លៃការអនុវត្តថវិកាកម្មវិធីតាមទម្រង់M1 និងរបាយការណ៍សមិទ្ធកម្មតាមដានការអនុវត្តថវិកាកម្មវិធីប្រចាំឆមាសទី១ ឆ្នាំ២០១៧

- បានធ្វើសំណើសុំតែងតាំងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់អង្គភាព

- បានធ្វើផែនការផ្ទទេយ្យបុរេប្រទានថវិកាកម្មវិធីឆ្នាំ២០១៨។

## ១២ មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- បានប្រជុំ និងទទួលការបណ្តុះបណ្តាលអំពីការប្រើប្រាស់ និងគ្រប់គ្រងគេហទំព័រថ្មី

- បានរៀបចំរបាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំ និងលទ្ធផលនៃការបណ្តុះបណ្តាល

- បានធ្វើការរៀបចំ (Configure) គេហទំព័ររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តមណ្ឌលគិរី

- បានធ្វើការតាមដានការកែសម្រួលគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមកដល់ពេលនេះសម្រេចបាន ៩០%

- បានធ្វើការជ្រើសរើសកសិករគំរូដើម្បីចុះថត

- រៀបចំកម្រងសំណួរចម្លើយដើម្បីយកព័ត៌មានពីកសិករ

- បានតាមដានព័ត៌មានរបស់សារព័ត៌មានជារៀងរាល់ថ្ងៃទាក់ទងវិស័យកសិកម្ម និងរាយការណ៍បន្តជូនថ្នាក់ដឹកនាំ។

## ១៣ ការងារអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១៣.១ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំសិក្សា២០១៦-២០១៧ សរុបមានចំនួន ៣ ៦៣៥នាក់ ចែកចេញជា ១០មហាវិទ្យាល័យគឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញារង និងថ្នាក់បរិញ្ញាវិទ្យាសាស្ត្រ និងសាលាក្រោយឧត្តមសម្រាប់ការបណ្តុះបណ្តាលលើកម្មវិធីបរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិត

- បានធ្វើពិធីសម្ពោធ ឧទ្យានបច្ចេកវិទ្យា របស់មជ្ឈមណ្ឌល CE SAIN នៅខេត្តបាត់ដំបង

- បានធ្វើពិធីចម្ការបង្ហាញដំណាំដំឡូងបារាំងនៅខេត្តមណ្ឌលគិរី

- បានធ្វើពិធីសម្ពោធអគារមន្ទីរពេទ្យសត្វ១ខ្នងជាអំណោយរបស់ KOPIA

- គ្រប់មហាវិទ្យាល័យបានធ្វើសិក្ខាសាលា រៀបចំផែនការស្រាវជ្រាវលើជំនាញរបស់ខ្លួន សម្រាប់រយៈពេល៥ឆ្នាំ

- បានធ្វើពិធីសំណេះសំណាលជាមួយនិស្សិតដែលត្រូវចេញទៅបំពេញកម្មសិក្សានៅប្រទេសអ៊ីស្រាអែលចំនួន ២១០នាក់

- បានធ្វើសិក្ខាសាលាពិគ្រោះយោបល់ស្តីពីផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ និងផែនការស្រាវជ្រាវរបស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម និងសិក្ខាសាលាស្តីពីការអភិវឌ្ឍន៍កម្មវិធីសិក្សាថ្នាក់បរិញ្ញាជាន់ខ្ពស់លើជំនាញ វិទ្យាសាស្ត្រកសិកម្ម កសិឧស្សាហកម្ម និង វិទ្យាសាស្ត្រសត្វ សម្រាប់អនុវត្តចាប់ពីឆ្នាំសិក្សាថ្មី២០១៧-២០១៨តទៅ

- បានទទួលស្វាគមន៍និស្សិតបញ្ចប់កម្មសិក្សារយៈពេល១១ខែ ពីប្រទេសអ៊ីស្រាអែលចំនួន១៦០នាក់ និងបានបញ្ជូននិស្សិតក្រុមថ្មីចំនួន២១០នាក់ទៅបំពេញកម្មសិក្សានៅប្រទេសអ៊ីស្រាអែលវិញផងដែរ

- បានបញ្ជូនមន្ត្រីសាស្ត្រាចារ្យចូលរួមកម្មវិធីសិក្ខាសាលា និងសន្និសីទផ្សេងៗនៅបរទេសបានចំនួន៦រូប និងបានបញ្ជូននិស្សិតចំនួន១០រូបចូលរួមកម្មវិធីប្រកួតប្រជែងពានរង្វាន់អ្នកវិទ្យាសាស្ត្រនិងវិស្វករវ័យក្មេង របស់ ក្រុមហ៊ុន ហុងដា Y-E-S ផងដែរ។

### ១៣.២ សាលាជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៦-២០១៧ សរុបចំនួន ៥១៣នាក់ (ស្រ្តី ១៨១នាក់) ក្នុងនោះ និស្សិតថ្នាក់បរិញ្ញាបត្រចំនួន ៤១៣នាក់(ស្រ្តី ១៤២នាក់) និងនិស្សិតថ្នាក់បរិញ្ញាបត្ររងចំនួន ១០០នាក់(ស្រ្តី ៣៩នាក់) លើជំនាញ៖ កសិកម្ម ផលផល ព្រៃឈើ វិទ្យាសាស្រ្តនិងវេជ្ជសាស្រ្តសត្វ សាកវប្បកម្ម ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិ-ឧស្សាហកម្ម និងសុរិយោដី
- បានបើកសិក្ខាសាលាពិគ្រោះយោបល់ស្តីពីកម្មវិធីសិក្សាគំរូតាមប្រព័ន្ធអេឡិចត្រូនិចលើការអប់រំ និងផ្សព្វផ្សាយកសិកម្ម
- បានបើកវគ្គបណ្តុះបណ្តាលកម្មវិធីផ្សព្វផ្សាយកសិកម្មជាមួយគម្រោង ASPIRE
- បានចុះសិក្សាទីផ្សារកសិកម្ម ដំណាំឧស្សាហកម្ម ដំណាំស្បៀង និងការអភិវឌ្ឍន៍ការប្រើប្រាស់ដីកសិកម្ម
- បានបើកកម្មវិធីការពារសារណាដោយជោគជ័យ និងរៀបចំការប្រឡងបញ្ចប់ថ្នាក់បរិញ្ញាបត្ររងឆ្នាំ២០១៧
- កំពុងជួសជុលអគារស្ថានីយផលិតកម្ម និងស្រាវជ្រាវ
- បានចុះពិនិត្យ និងតាមដានការងារនៅស្ថានីយពិសោធន៍នៅស្រុកត្រាំកក់ ខេត្តតាកែវ
- បានបន្តដឹកនាំនិស្សិតពិសោធន៍លើការចិញ្ចឹមសត្វ និងការដាំដំណាំ
- បានជួសជុលអគារស្ថានីយផលិតកម្ម និងស្រាវជ្រាវចំនួន ០១ខ្នង
- បាននិងកំពុងផលិតពូជសាគូពងពស់ដើម្បីចែកជូនប្រជាជនដាំពិសោធនៅខេត្តកំពង់ឆ្នាំង។

### ១៣.៣ សាលាជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០១៦-២០១៧ សរុបមានចំនួន ៧៨៦នាក់(ស្រ្តី ៣១៨នាក់) រួមមាន៖ និស្សិតអាហារូបករណ៍សរុប ៥៧៧នាក់ (ស្រ្តី ២៧១នាក់) និស្សិតសិក្សាបង់ថ្លៃចំនួន ២០៩នាក់ (ស្រ្តី ៤៧នាក់) លើជំនាញវិទ្យាសាស្រ្តកសិកម្ម វិទ្យាសាស្រ្តនិងវេជ្ជសាស្រ្តសត្វ វិទ្យាសាស្រ្តផលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ
- បានបន្តសហការជាមួយ DTRA (Defence Threat Reduction Agency) បើកវគ្គបណ្តុះបណ្តាលនិស្សិតជំនាញវិទ្យាសាស្រ្ត និងវេជ្ជសាស្រ្តសត្វ
- បានបណ្តុះបណ្តាលមន្រ្តីលើការគ្រប់គ្រងមន្ទីរពិសោធន៍ និងវិភាគបាក់តេរី
- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហម
- បន្តការងារមន្ទីរពិសោធន៍ចិញ្ចឹមនិងក្លាស់ជង្រូវនាងព្រៃ និងបានចែកជូនជង្រូវនាងឱ្យសហគមន៍កសិកម្មចិញ្ចឹមចំនួន ១០គ្រួសារ
- បានជួបពិភាក្សាជាមួយប្រតិភូមកពីសាកលវិទ្យាល័យ វ៉ាស៊ីនតោន ស្តីពីការរៀបចំសិក្សាគម្រោងចិញ្ចឹមគោយកទឹកដោះ
- បានបើកវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធព័ត៌មានវិទ្យាដល់ប្រធានសហគមន៍កសិកម្មខេត្តកំពង់ចាមចំនួន ២៥នាក់
- បានសហការជាមួយសាកលវិទ្យាល័យ កាង វុង សាធារណរដ្ឋកូរ៉េ ដើម្បីសិក្សារៀបចំបង្កើតមន្ទីរពិសោធន៍សត្វជង្រូវនាង និងល្អិត។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលដំណាំស្រូវវស្សាសម្រេចបានចំនួន ២ ៦០៩ ៦១៧ហ.ត ស្មើនឹង១០៤,៥២% នៃផែនការ ២ ៤៩៦ ៧៩០ហ.ត និងខេត្តចំនួន ១៦ ត្រូវបានបញ្ចប់ការងារដាំដុះដំណាំស្រូវរដូវវស្សាហើយ។ ជាមួយនឹងការខិតខំប្រមូលផលដំណាំរដូវវស្សាយ៉ាងសស្រាក់សស្រាំរបស់បងប្អូនកសិករ ក្រសួងក៏បានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តឱ្យយកចិត្តទុកដាក់តិតគូរទៅលើយន្តការនិងបទដ្ឋានបច្ចេកទេសគន្លឹះសំខាន់ៗតាមការចាំបាច់និងសហការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការតាមដានវាយតម្លៃអំពីការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ គ្រោះរាំងស្ងួត ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំ

ណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗដោយថាហេតុ ព្រមទាំងសហការជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយក្នុងការដោះស្រាយពូជស្រូវ និងពូជបន្លែមួយចំនួនតាមលទ្ធភាពជាក់ស្តែង សម្រាប់ចែកជូនដល់ប្រជាកសិករដែលទទួលរងគ្រោះដើម្បីស្តារការខូតខាតឡើងវិញឱ្យបានទាន់ផ្ទួរកាលដាំដុះ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ដូចជាការជំរុញឱ្យចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វ បទល្មើសព្រៃឈើនិងជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយផ្តោតជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងក៏បានបន្តជំរុញគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ ព្រមទាំងពង្រឹងស្មារតីទទួលខុសត្រូវក្នុងការឆ្លើយតបឱ្យបានទាន់ពេលវេលាលើមូលបញ្ហាទាំងឡាយដែលបានលើកឡើងក្នុងសារព័ត៌មាននិងបណ្តាញសង្គមផ្សេងៗ។ ទន្ទឹមនឹងនេះ ផ្នែកសវនកម្មដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រ គោលនយោបាយតាមអនុវិស័យសំខាន់ៗ និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរថ្នាក់ក្រោមជាតិ។

ជារួម ដោយមានការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជម្នះដោះស្រាយនូវរាល់ការលំបាកផ្សេងៗដែលរួមមានកត្តាអវិជ្ជមាននៃធម្មជាតិ ពិសេសគ្រោះទឹកជំនន់ កង្វះទឹកក្នុងការងារបង្កបង្កើនផល និងការបំផ្លាញដោយសត្វល្អិតចង្រៃដែលតែងតែកើតមានជារៀងរាល់ឆ្នាំ។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ :

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវរដូវវស្សា និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណនិងគុណភាពតាមផែនការកំណត់ក្នុងឆ្នាំ២០១៧-២០១៨ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង

- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំរួមផ្សំផ្សេងទៀតដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ និងកាត់បន្ថយការចំណាយថ្លៃដើមឱ្យបានច្រើនដើម្បីជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ និងកាត់បន្ថយការប្រើប្រាស់សារធាតុគីមី

- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយដោយថាហេតុ ការទប់ទល់ជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្មសម្រាប់ការងារបង្កបង្កើនផលរដូវវស្សានេះ

- បន្តណែនាំដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់សហការជាមួយអាជ្ញាធរមូលដ្ឋានចុះធ្វើអន្តរាគមន៍ ដើម្បីស្វែងរកដំណោះស្រាយទប់ស្កាត់ការធ្លាក់ចុះថ្លៃកសិផលផ្សេងៗដោយថាហេតុ ការងារសម្របសម្រួលថ្នាក់តំបន់ និងថ្នាក់ខេត្ត ដើម្បីជួយដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការងារស្រូវអង្ករនៅមូលដ្ឋានក៏ដូចជាទីផ្សារកសិផលផ្សេងៗទៀតផងដែរ

- យកចិត្តទុកដាក់គិតគូរផ្សព្វផ្សាយអំពីការប្រើប្រាស់ជីកសិកម្ម ថ្នាំកសិកម្ម និងសារធាតុគីមីផ្សេងៗទៅលើផលិតផលកសិកម្មដែលនាំឱ្យប៉ះពាល់សុខុមាលភាពសាធារណៈ និងការនាំចេញកសិផលទៅក្រៅប្រទេស

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្ដាមន្ទីរពិសោធន៍យថាប្រភេទ និងរោងចក្រកែច្នៃកៅស៊ូ

- បន្តជំរុញឲ្យអង្គភាពជំនាញចុះធ្វើការអប់រំផ្សព្វផ្សាយបច្ចេកទេសដល់កសិករដាំកៅស៊ូឲ្យបានទូលំទូលាយ ធ្វើការវិភាគសេដ្ឋកិច្ចក៏ដូចជាការបញ្ជ្រាបអំពីតម្លៃកៅស៊ូនៅលើទីផ្សារក្នុងកាលៈទេសៈបច្ចុប្បន្ននេះផងដែរ។

**២ ផ្នែកផលិតកម្មនិងបសុព្យាបាល** :

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទរួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- បន្តរិះរកគ្រប់មធ្យោបាយដើម្បីចូលរួមដោះស្រាយនូវរាល់បញ្ហាប្រឈមទាំងឡាយដែលបានលើកឡើងក្នុងក្របខ័ណ្ឌនៃកិច្ចប្រជុំក្រុមការងារកសិកម្ម និងកសិ-ឧស្សាហកម្ម

- រៀបចំគម្រោងបណ្ដុះបណ្ដាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តាខេត្ត-រាជធានី និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្វគ្រប់ប្រភេទនៅក្នុងស្រុកឱ្យបានទូលំទូលាយ ជាពិសេសការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមតំបន់ដែលខ្សត់ទឹក

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងជំណាំចំណីសត្វនៅទូទាំងប្រទេស ព្រមទាំងជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកគ្រុនក្តៅខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- បន្តចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី-ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានការបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឱ្យបានសមស្របតាមនីតិវិធី

- បន្តពង្រឹងកិច្ចសហការក្នុងក្របខ័ណ្ឌត្រួតពិនិត្យអនាម័យសត្វ និងផលិតកម្មសត្វក្នុងក្របខ័ណ្ឌទ្វេភាគី តំបន់ និងអន្តរជាតិ ព្រមទាំងចូលរួមក្នុងការប្រឹងប្រែងរៀបចំកិច្ចព្រមព្រៀងទទួលស្គាល់ជំនាញបសុព្យាបាលនៅក្នុងក្របខ័ណ្ឌ ASEAN ដើម្បីសម្រួលដល់ការធ្វើសមាហរណកម្ម ជំនាញបសុព្យាបាលក្នុងចំណោមប្រទេសសមាជិក ASEAN។

**៣ ផ្នែកព្រៃឈើ** :

- បន្តជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការ និងតាមការពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឱ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តការដាំកូនឈើ និងដាំឈើឱ្យបានទូលំទូលាយតាមផែនការដែលបានគ្រោងទុក

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរឹលឱ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើសំខាន់ៗ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយក្រសួង ស្ថាប័ន សមត្ថកិច្ចជំនាញ សហគមន៍ព្រៃឈើ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាព រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ ព្រមទាំងការចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃផងដែរ

- ពង្រឹងការអនុវត្តច្បាប់ស្ដីពីព្រៃឈើនិងបទបញ្ជាលេខ០១ និង០២ របស់រាជរដ្ឋាភិបាល និងចូលរួមអនុវត្តសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើប្រកបដោយប្រសិទ្ធភាព។

**៤ ផ្នែកជលផល:**

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្ដីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្ដីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តស្រាវជ្រាវជីកប្រឡាយ និងបោះបង្គោលដីព្រៃលិចទឹកដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ព្រមទាំងគិតគូរអំពីមធ្យោបាយសង្គ្រោះធនធានមច្ឆជាតិនៅពេលឡើងកម្ដៅខ្លាំងបណ្ដាលមកពីការប្រែប្រួលអាកាសធាតុ

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឱ្យបានគ្រប់ឃុំ

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៧ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី កង្កែប បង្គាក្ដាម ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការគ្រប់គ្រងលើការចិញ្ចឹមត្រីរស់ ត្រីឆ្លាត់ឱ្យបានសមស្របតាមវិធានបច្ចេកទេស ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ

- បន្តកិច្ចសហការក្នុងការរៀបចំធ្វើវិសោធនកម្មច្បាប់ស្ដីពីជលផល។

**៥ ផ្នែកពាក់ព័ន្ធផ្សេងៗ :**

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម ដើម្បីសុខុមាលភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្ដាអង្គភាពក្រោមឱវាទនិងបណ្ដាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- ធ្វើការកែលម្អសេវាសាធារណៈច្រកចេញចូលតែមួយរបស់អង្គភាពពាក់ព័ន្ធក្រោមឱវាទប្រកបដោយតម្លាភាពនិងទាន់ពេលវេលា ការផ្ទេរមុខងារទៅថ្នាក់ក្រោមជាតិតាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលបង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឱ្យបានទូលំទូលាយ ព្រមទាំងការបញ្ចូលសកម្មភាពយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់ៗតាមផ្នែកនីមួយៗផងដែរ

- ត្រៀមរៀបចំទិវាស្បៀងអាហារពិភពលោកនាខែតុលាខាងមុខ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្ដាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្ដែង រួមទាំងការរៀបចំវគ្គបណ្ដុះបណ្ដាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ឱ្យបានសមស្របទៅតាមច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្ដុះបណ្ដាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេស

- បន្តសហការជាមួយក្រសួងមុខងារសាធារណៈក្នុងការប្រឡងជ្រើសរើសក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលសម្រាប់ឆ្នាំ២០១៧នេះ

- បន្តសហការរៀបចំច្បាប់ផ្សេងៗទៀត លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងក្របខ័ណ្ឌកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់តាមបែបវិមជ្ឈការនិងវិសហមជ្ឈការនៅតាមអង្គភាពក្រោមឱវាទតាមការចាំបាច់ និងលំដាប់អាទិភាព

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា រួមចំណែកអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាពីកសិកម្មបែបវិបុលវប្បកម្មមានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្មមានផលិតភាពខ្ពស់ ការធ្វើកសិកម្មសមស្របដោយគិតគូរជាចម្បងទៅលើការប្រែប្រួលធាតុអាកាស ស្តង់ដារ ពិសេសការបង្កើនផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**



# សកម្មភាពថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលជួបពិភាក្សាការងារជាមួយលោក Li Haibing ជំនួយការអ្នកគ្រប់គ្រងទូទៅ នៃក្រុមហ៊ុន China Contruction Third Engineering Bureau Group Co., Ltd



ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុញ្ញាតឱ្យ សាស្ត្រាចារ្យ Fumio Isoda នៃសាកលវិទ្យាល័យ ណាហ្គូយ៉ា(ប្រទេសជប៉ុន) ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ



ការអញ្ជើញជាអធិបតីភាពក្នុងពិធីបិទវគ្គបណ្ដុះបណ្ដាលស្ដីពីការកែលម្អការគ្រប់គ្រងទឹក និងប្រព័ន្ធស្រោចស្រពកសិកម្មឱ្យមានប្រសិទ្ធភាពនៅប្រទេសកម្ពុជានៅសណ្ឋាគារកាបូ..



ការអញ្ជើញជាអធិបតីភាព បិទវគ្គបណ្ដុះបណ្ដាលស្ដីពីការធ្វើអធិការកិច្ចលើការគ្រប់គ្រងចំណូល-ចំណាយថវិការដ្ឋ និងក្រមសីលធម៌មន្ត្រីរាជការអធិការកិច្ច




ការអញ្ជើញចូលរួមក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីកសិកម្ម និងព្រៃឈើអាស៊ាន បូកបី លើកទី១៧ ដែលបានប្រព្រឹត្តទៅឡើងនៅសណ្ឋាគារ Le Meridien ទីក្រុងឈៀងម៉ៃ



សកម្មភាពចុះពិនិត្យកសិដ្ឋានដាំដុះបន្លែសរីរាង្គ របស់ក្រុមហ៊ុន Happy & Co Farm នៅឃុំសរសរស្ដម ស្រុកពួក ខេត្តសៀមរាប



សកម្មភាពពិនិត្យការងារបង្កបង្កើនផលរបស់ប្រជាកសិករ ប្រើដោយឧបករណ៍ព្រោះ កែច្នៃដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅឃុំខ្ពបរុន ស្រុកជុំគីរី



សកម្មភាពពិនិត្យមជ្ឈមណ្ឌលឧត្តមភាពប្រពលវប្បកម្ម កសិកម្មនិរន្តរភាព និងអាហាររូបត្ថម្ភឧទ្យានបច្ចេកវិទ្យាកសិកម្ម ស្រុកសង្កែ ខេត្តបាត់ដំបង



ការអញ្ជើញជាអធិបតីភាព ក្នុងទិវាស្បៀងអាហារពិភពលោក ឆ្នាំ២០១៧ ក្រោមប្រធានបទ ផ្លាស់ប្ដូរអនាគតនៃការធ្វើចំណាកស្រុកតាមរយៈការវិនិយោគ..នៅខេត្តត្បូងឃ្មុំ



សកម្មភាពជួបសំណេះសំណាល ជាមួយបណ្ដាញកសិករ ប្រកបរបរភ្ញាស់កូនត្រីពូជ(ឆ្ពិន ទីឡាព្យ៉ា អណ្ដែងនិងត្រីប្រា នៅភូមិចក សង្កាត់រកាក្នុង ក្រុងដូនកែវ



ឯកឧត្ដម **យុទ្ធ ភូថង** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីភាព ក្នុងកិច្ចប្រជុំពិភាក្សាស្ដីអំពីការបង្កើតគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម នៅសណ្ឋាគារ Sofitel ..



ឯកឧត្ដម **ឌិម គឹមសា** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជួបសំណេះសំណាល ជាមួយប្រជាកសិករ បង្កបង្កើនផលស្រូវ នៅឃុំទឹកហូត ស្រុករលាប្អៀ ខេត្តកំពង់ឆ្នាំង




ឯកឧត្តមបណ្ឌិត **ទី សុគន្ធ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីភាព ក្នុងពិធីប្រកាសដាក់ឱ្យដំណើរការនូវគម្រោង កម្ពុជាហារ៉េស II ដើម្បីជំរុញកំណើនសាកវប្បកម្មពាណិជ្ជកម្ម



លោកជំទាវ **ហោ ម៉ាលីន** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញនាំយកអំណោយមកចែកជូនបងប្អូនកងកម្លាំងក្នុងតំបន់ប្រតិបត្តិការណ៍សឹករងវរះ៣០២ ការពារព្រំដែន នៅស្រុកកំពង់ត្រាច ខេត្តកំពត



ឯកឧត្តម **ហាស់ សារ៉េត** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញ ចុះទៅសាកសួរសុខទុក្ខនិងនាំយកអំណោយឧបត្ថម្ភ ដល់កងទ័ពសេនាតូច ការពារព្រំដែន គោក លេខ ៣០១ ខេត្តតាកែវ



ឯកឧត្តម **ណៅ ធូក** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញពិនិត្យការភ្ញាស់កូនត្រី កូនបង្កងនៅមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្មទឹកសាប ក្នុងស្រុកពាមរក៍ ខេត្តព្រៃវែង



ឯកឧត្តម **ម៉ម អំណាត់** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំអន្តរគម្រោងរៀបចំផែនទីបង្ហាញផ្លូវ គម្រោងអភិវឌ្ឍន៍កសិកម្ម និងជំរុញកំណើនសេដ្ឋកិច្ច និងកម្មវិធី ASPIRE



ឯកឧត្តម **សាន វណ្ណទី** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដឹកនាំកិច្ចប្រជុំស្តីពីវិធានការគ្រប់គ្រង និងត្រួតពិនិត្យការអនុវត្តគម្រោងសកម្មភាពរបស់អង្គការ(NGOs)



ឯកឧត្ដម **ចាន់ សុវ្ណ្ឌ** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញពិនិត្យចម្ការអំពៅរបស់ក្រុមហ៊ុនចិនផលិតស្ករស នៅខេត្តព្រះវិហារ



ឯកឧត្ដម **គង់ ចាន់** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញចូលរួមក្នុងទិវាចម្ការបង្ហាញផលិតកម្ម ដំឡូងបារាំង នៅខេត្តមណ្ឌលគិរី



ឯកឧត្ដម **នុត ច័ន្ទសុខា** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញចូលរួមកិច្ចប្រជុំ នៅទីស្ដីការគណៈរដ្ឋមន្ត្រី



ឯកឧត្ដម **កៅ ផល** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញក្នុងកិច្ចប្រជុំ ស្ដីពីការគ្រប់គ្រងសត្តឃាតដ្ឋាន និងដោះស្រាយបញ្ហាប្រឈម នៅខេត្តព្រះវិហារ



លោកជំទាវ **ម៉ុម ថានី** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញចូលរួមវគ្គបណ្ដុះបណ្ដាលការបញ្ច្រាបយេនឌ័រក្នុងខ្សែរចង្វាក់ផលិតកម្មកសិកម្ម



ឯកឧត្ដម **ឡោ រស្មី** អគ្គលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញ ជាអធិបតីភាពក្នុងកិច្ចប្រជុំត្រួតពិនិត្យលើការអនុវត្តការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា



សិល្បៈកំណាព្យ

# សំណោករុក្ខា

*បទពាក្យ ៧*

*និពន្ធដោយ ៖ លោក អ៊ូ វណ្ណារ៉េត*

**បន្តពីទស្សនាវដ្ដីសមិទ្ធផលកសិកម្មប្រចាំឆមាសទី១ ឆ្នាំ២០១៧**

ធ្វើជាសាឡុងគ្រែទូតាំង  ម៉ូតចិនបារាំងល្អអស្ចារ្យ
ហើយចុះកុំគិតរឿងសោកា  គិតពីអាត្មាឯងវិញម្ដង ។
កកោះឡេះឡោះស្រែកឡូឡា  ដៀលដេរស្ដីថាដើមសម្រង
មិនគិតជួយដល់នាងនួនផង  ព្រោះគ្នាសៅហ្មងយំហើមភ្នែក ។
សម្រងស្រដីទៅវិញថា  ជួបរឿងទុក្ខាមិនមែនប្លែក
រុក្ខាឈើយើងច្រើនអនេក  ត្រូវមនុស្សប្រើដែកកាត់កាប់ចាំង ។
ឈ្មោះដើមសម្រងឈើយកផ្លែ  មនុស្សតែងតែកាប់រាល់ឆ្នាំ
កាប់ដើមយកផ្លែជាប្រចាំ  មានផ្លែរង់ចាំតែគេកាប់ ។
ខ្ញុំត្រូវចុកចាប់ឈឺយ៉ាងណា  ពេលមានផល្លាចិត្តសែនយ៉ាប់
រស់នៅរង់ចាំតែថ្ងៃស្លាប់  ខ្ញុំគួរតែប្រាប់ដល់បងប្អូន ។
សម្រងជាដើមឈើកម្សត់  មានផ្លែកាប់ហ្មត់ខ្សត់ទាំងកូន
ថ្ងៃក្រោយនឹងជួបរឿងសោះសូន្យ  គ្មានញាត្តិបងប្អូនដាច់ពូជធា ។
ឈើទាលឈរស្ដាប់រឿងសម្រង  កម្សត់កន្លងយំដាក់គ្នា
លំបាកលំបិនគ្មានគណនា  យើងរស់មិនជាឈើរហូត ។
ដូចយ៉ាងរូបខ្ញុំដើមឈើទាល  អ្នកណាដំនៀលដៀលចារមក
គេចាំងរួចដុតគល់រហូត  ដើម្បីដងបូតយកជ័រប្រើ ។
ខ្ញុំសែនចុកចាប់ក្ដៅក្រហាយ  ក្រហាលក្នុងកាយឫសប្រឹងរើ
អត់ទ្រាំខ្លាំងដីក្រែងប្រសើរ  ទោះខំប្រឹងដើររើដោះដៃ ។
ដើមបេងឈរជ្រែងថ្លែងវាចា  ថាយើងរុក្ខារស់លើដី
គ្មានសិទ្ធិតវ៉ាឡើងក្ដាំក្ដី  ត្បិតជាឈើព្រៃគ្មានចលនា ។

**សូមរង់ចាំអានបន្តនៅទស្សនាវដ្ដីកសិកម្មប្រចាំត្រីមាសទី៤ ឆ្នាំ២០១៧**

